**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECOMONICS

# សារណាបញ្ចប់ការសិក្សា

# បត្យាប័ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


សិក្សាស្រាវជ្រាវដោយ

និស្សិតឈ្មោះៈ**១.កញ្ញា ស៊ុន លីម៉ាទីន**

**២.លោក ព្រឹម វាសនា**

**សាស្ត្រាចារ្យណែនាំៈ តែ វិជ្ជតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីររូប នាងខ្ញុំឈ្មោះ **ស៊ុន លីម៉ាឌីន** និង ខ្ញុំបាទឈ្មោះ **ព្រឹម វាសនា** ជានិស្សិត **ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២២** នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានជ្រើសរើសប្រធានបទ"**បត្យាប័ន**"យើងខ្ញុំទាំងពីររូប បានសរសេរសារណាបញ្ចប់ឆ្នាំសិក្សា ២០២១-២០២២។

## សូមសម្តែងនូវការគោរពដឹងគុណ យ៉ាងជ្រាលជ្រៅជូន

១.លោកឪពុកឈ្មោះ **ស៊ុន សុវណ្ណា** និងអ្នកម្តាយឈ្មោះ **នី សុគន្ធ**

២.លោកឪពុកឈ្មោះ **នូ ជិនសេរី** និងអ្នកម្តាយឈ្មោះ **យូ សាម៉េត**

កូនមិនអាចភ្លេចឡើយនូវគុណ នៃលោកទាំងទ្វេ ដែលបានផ្តល់កំណើតដល់យើងខ្ញុំ និងបានចិញ្ចឹមបីបាច់ ថែរក្សាអប់រំ កូនឲ្យក្លាយជាធនធានមនុស្សសម្រាប់គ្រួសារនិងសង្គមជាតិ។ កូនសូមសម្តែងនូវការគោរពដឹងគុណដ៏ ជ្រាលជ្រៅជូនចំពោះលោកទាំងទ្វេ តាមរយៈការប្រណម្យដៃទាំងដប់ សំពះដឹងគុណដល់លោកទាំងទ្វេ។ លើសពីនេះទៅទៀតលោកទាំងទ្វេបានលះបង់ ទាំងកម្លាំងកាយ កម្លាំងចិត្តក្នុងការចិញ្ចឹមបីបាច់តាំងពីថ្ងៃចាប់កំណើត រហូតមកទល់បច្ចុប្បន្ន។ នៅពេលកូនបានចាប់កំណើត លោកទាំងពីររឹតតែពិបាកក្នុងការខិតខំពុះពារគ្រប់បែបយ៉ាង ទោះបីជាការងារទាំងអស់នោះអាចបង្កគ្រោះថ្នាក់ដល់ជីវិត ក៏លោកទាំងទ្វេមិនដែលខ្លាចញញើត ព្រោះដើម្បីចិញ្ចឹមជីវិតកូនឲ្យរស់នៅបានសុខស្រួលនិងផ្គត់ផ្គង់ ឲ្យកូនបានសិក្សារៀនសូត្រ មានចំណេះដឹង ដើម្បីក្លាយជា កូនល្អ ពលរដ្ឋល្អក្នុងសង្គមជាតិ។

គុណូបការៈយ៉ាងធំអណេកនិងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងទ្វេដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំ សម្រាប់កូនៗគ្រប់រូប គឺមានទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងទ្វេដែលបានលះបង់សម្រាប់កូនៗ កូននិងចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបានហើយនឹងស្ថិតនៅក្នុងដួងព្រលឹងរបស់កូនៗ ជាដរាបគ្មានថ្ងៃសូន្យនោះឡើយ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ានីហ៊ុនសែន** រួមទាំងសេនាលិខាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងអស់គ្រប់ជាន់ថ្នាក់ដែលបានមានឆន្ទះក្នុងការដឹកនាំសង្គមឲ្យមានកាលានុវត្តដ៏គាប់ប្រសើរ និងជម្រុញឲ្យសង្គមមានការអភិវឌ្ឍន៍លើគ្រប់វិស័យដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រោមការដឹកនាំយុទ្ធសាស្ត្រឈ្នះៗ និងខិតខំបង្រួបបង្រួមជាតិរបស់សម្តេច បានធ្វើអោយប្រទេសកម្ពុជាទទួលបានការរក្សាសណ្តាប់ធ្នាប់ក្នុងសង្គម

និងសុខសុវត្ថិភាព ស្ថេរភាព ជាពិសេសនៅក្នុងអំឡុងពេលប្រទេសកំពុងមានជម្ងឺរាតត្បាត លោកខិតខំប្រឹងប្រែង លះបង់អស់ពីកម្លាំងកាយចិត្តដើម្បីស្តារប្រទេសអោយគេចផុតពីជម្ងឺដ៏កាចសាហាវកូវីដ-១៩ មួយនេះអោយបានលឿនបំផុត ដើម្បីជួយដល់ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។

**ឯកឧត្តម លុយ ចណ្ណា សាកលវិទ្យាធិការសាកលវិទ្យាធិការរង និងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗ យ៉ាងពិតប្រាកដសម្រាប់ជាប្រទីបបំភ្លឺជីវិតយើងខ្ញុំ នៅក្នុងថ្នាក់បរិញ្ញាបត្រនេះ។

**លោកស្រីសាស្ត្រាចារ្យ នៃ ទិដ្ឋតា** ដែលជាសាស្ត្រចារ្យណែនាំនៅក្នុងប្រធានបទ "**បត្យាប័ន**" នេះ ដើម្បីធ្វើអោយមាននូវការដំណើរការនៃការតាក់តែងសារណាបញ្ចប់ឆ្នាំនេះ ឡើងដោយប្រកបដោយជោគជ័យ។ ជាពិសេសលោកស្រីសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ កម្លាំងកាយកម្លាំងចិត្ត ក្នុងការខិតខំប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចរាល់ខ្វះខាតទាំងឡាយធ្វើយ៉ាងណាឲ្យប្រធានបទរបស់យើងខ្ញុំទទួលបាននូវលទ្ធផលល្អ និងប្រកបដោយជោគជ័យ និងគុណភាព។

មុនឈានដល់ការបញ្ចប់ យើងខ្ញុំទាំងពីរអ្នក សូមធ្វើការសម្តែងការដឹងគុណដល់អ្នកទាំងអស់គ្នា ដែលបានរៀបរាប់ខាងលើ អោយជួបប្រទះភាពសុខដមរមនា និងមានសុខភាពបរិបូរណ៍ព្រមទាំងប្រកបការងារអ្វីៗឲ្យបានជោគជ័យប្រកបដោយឧត្តមភាព និងភាពថ្កុំថ្កើនជានិរន្តន៍។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមធ្វើការអនុញ្ញាតដើម្បីបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង និងប្រសិទ្ធិពរជ័យសិរីបវរជូនទៅដល់ លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យលោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់ សូមបានប្រកបតែនូវនឹងពុទ្ធិពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមយើងខ្ញុំទាំងពីរនាក់ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តឆ្នាំទី៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** អស់រយៈពេល ៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទទួលបាននូវពុទ្ធិក៏ដូចជាទ្រឹស្ដី បទពិសោធន៍ជាច្រើន ទាក់ទងទៅនឹងវិស័យច្បាប់ និងចំណេះដឹងទូទៅផ្សេងៗមួយចំនួនទៀត។ យើងខ្ញុំទាំងពីរនាក់បានចាត់ទុកសាលាជាទីកន្លែងកំណើតបង្កើតនូវចំណេះដឹង និងគំនិតពីព្រោះសាលាមិនត្រឹមតែផ្ដល់ចំណេះដឹងតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្ដល់ជាគុណធម៌ សីលធម៌ និងកតញ្ញូតាធម៌ដល់យើងខ្ញុំ ហើយធ្វើអោយយើងខ្ញុំប្រកាន់ខ្ជាប់ខ្លួនជានិច្ចនូវវិន័យ។

ដោយសារតែយើងខ្ញុំជានិសិត្សផ្នែកនីតិសាស្រ្ត ស្របពេលដែលប្រទេសកម្ពុជាយើងកំពុងមានវត្តមានជនបរទេសច្រើនចូលមក ជាហេតុដែលធ្វើឲ្យយើងខ្ញុំទាំងពីរនាក់ចាប់អារម្មណ៍យ៉ាងខ្លាំងទាក់ទងទៅការផ្ទេរជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយនៅពេល ដែលមានបទល្មើសបានកើតឡើង នៅលើដីនៃប្រទេសណាមួយ។ ដូចនេះហើយទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសយកប្រធានបទស្ដីពី "**បត្យាប័ន**" ។

មូលហេតុដែលយើងខ្ញុំជ្រើសយកប្រធានបទនេះទៀតសោត គឺដោយសារតែនាបច្ចុប្បន្ននេះ បទល្មើសកំពុងមានការរីករាលដាល ពីមួយថ្ងៃទៅមួយថ្ងៃនៅពាសពេញផ្ទៃប្រទេសក៏ដូចជាដទៃទៀតដែរ។ ជាក់ស្ដែងក្នុងនោះ ក៏មានជនខិលខូចមួយចំនួនដែរបានប្រព្រឹត្តិបទល្មើសរួចតែងតែរត់គេចខ្លួន ទៅកាន់ប្រទេសដទៃ ដើម្បីរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់។

កាលពីដើមការចាប់ខ្លួនជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសបានរត់ខ្លួនទៅកាន់ប្រទេសដទៃ គឺមានការលំបាកណាស់ដោយសារតែពីមុនប្រទេសកម្ពុជាពុំទាន់មានសន្ធិសញ្ញាបត្យាប័នជាមួយ និងបណ្ដាប្រទេសដទៃនៅលើសាកលលោក។ ដោយហេតុតែមានការលំបាកជាច្រើន នៅក្នុងការចាប់ខ្លួនជនល្មើសដែលរត់គេចខ្លួនទៅប្រទេសដទៃយកមកផ្ដន្ទាទោសមួយចំនួនដូចជា៖ ប្រទេសថៃ ប្រទេសចិន ប្រទេសឡាវ ប្រទេសបារាំង ប្រទេសកូរ៉េខាងត្បូង និងប្រទេសវៀតណាម ។ ក្រៅពីការចុះសន្ធិសញ្ញាទាំងប្រាំមួយខាងលើ កម្ពុជាក៏បានចុះកិច្ចព្រមព្រៀងជួយគ្នាទៅវិញទៅមក ជាមួយប្រទេសមួយចំនួនទៀតផងដែរ ក្នុងនោះមានដូចជា៖ ប្រទេសអាមេរិកប្រទេសអូស្ត្រាលី ប្រទេសរុស្ស៊ី ប្រទេសឥណ្ឌា និងប្រទេសបារាំងជាដើម ដែលទាក់ទងទៅនិងការផ្ទេរទណ្ឌិត និងជាជំនួយផ្នែកច្បាប់។

មិនតែប៉ុណ្ណោះដោយសារតែការធ្វើបត្យប័នបានផ្ដល់អត្ថប្រយោជន៍ យ៉ាងខ្លាំងដល់ប្រទេសនីមួយៗនៅក្នុងពិភពលោក ក្នុងការជួយគ្នាទៅវិញទៅមកតាមរយៈសន្ធិសញ្ញា ក៏ដូចជាកិច្ចព្រមព្រៀង ដើម្បីទប់ស្កាត់ ឬកាត់

បន្លយបទល្មើសឆ្លងដែន និងបញ្ជូនជនខិលខូច ដែលបានរត់គេចខ្លួននោះមកផ្តន្ទាទោសតាមច្បាប់នៃប្រទេសសាមី ទើបធ្វើអោយប្រទេសនីមួយៗព្យាយាមបង្កើតទំនាក់ទំនងដើម្បីបង្កើតសន្ធិសញ្ញាបត្យាប័នឡើង។

ក្រុមយើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ចំពោះលោកស្រីសាស្ត្រាចារ្យ **នៃ ទិដ្ឋា** ដែលបង្រៀននូវមុខវិជ្ជា៖ **នីតិព្រហ្មទណ្ឌ** ដែរបានធ្វើជាសាស្ត្រាចារ្យណែនាំដល់ក្រុមយើងខ្ញុំទាំងពីរនាក់។ ជាចុងក្រោយនេះក្រុមយើងខ្ញុំទាំងអស់គ្នាសូមអធ្យាស្រ័យ ចំពោះកំហុសដែរបានខុសឆ្គងត្រង់ប្រការ ណាមួយដែលបានកើតឡើងដោយចេតនា ឬអចេតនាក្តីដែលក្រុមយើងខ្ញុំមិនបានដឹងឬក៏មានការខ្វះខាតចំពោះការបកស្រាយនូវប្រធានបទមួយនេះមិនបានល្អគ្រប់គ្រាន់ និងការប្រើពាក្យពេចន៍ ឬអក្ខរាវិរុទ្ធមិនបានត្រឹមត្រូវត្រង់កន្លែងណាមួយដែរជាការរំពឹងទុករបស់លោកគ្រូអ្នកគ្រូនិងមិត្តនិស្សិតទាំងអស់។ ក្រុមយើងខ្ញុំទាំងអស់ស្វាគមន៍នូវការរាល់មតិរិះគន់ទាំងឡាយពីសំណាក់សាស្ត្រាចារ្យ លោកលោកស្រី មិត្តនិស្សិត និងប្រិយមិត្តអ្នកអានទាំងអស់ដើម្បីធ្វើអោយកិច្ចការស្រាវជ្រាវមួយនេះកាន់ល្អតែប្រសើរឡើង និងកែប្រែនូវចំណុចដែរខ្វះខាតអោយកាន់តែច្បាស់បន្ថែមជាងនេះទៅទៀត។

លើសពីនេះទៅទៀត ក្រុមយើងខ្ញុំ សូមគោរពជូនពរទៅដល់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់ អោយជួបប្រទះតែសេចក្តីសុខ និងប្រកបដោយសុខសុវត្ថិភាព និង **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................ ១

## ជំពូកទី១. សញ្ញាណទូទៅនៃបត្យាប័ន

**ផ្នែកទី១. ការកើតនៃបត្យាប័ន** ........................................................ ៤

**១.និយមន័យ** ........................................................ ៤

**២.ឋានានុក្រមនៃច្បាប់អនុវត្តលើបត្យាប័ន** ........................................................ ៥

**៣. លក្ខខណ្ឌអនុញ្ញាតនៃបត្យាប័ន** ........................................................ ៥

ក. លក្ខខណ្ឌទាក់ទងនិងអំពើ ឬ ទិ្វកភាពនៃបទល្មើស ........................................................ ៥

ខ. លក្ខខណ្ឌទាក់ទងនិងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ........................................................ ៦

គ. លក្ខខណ្ឌទាក់ទងនិងទីកន្លែងប្រព្រឹត្តបទល្មើស ........................................................ ៧

ឃ. លក្ខខណ្ឌទាក់ទងនិងទោសពន្ធនាគារ ........................................................ ៧

ង. លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងនិងពាក្យសុំឲ្យធ្វើបត្យាប័ន ........................................................ ៧

**៤. លក្ខខណ្ឌហាមឃាត់ ឬបដិសេធ** ........................................................ ៨

ក អំពើមានលក្ខណៈនយោបាយ ........................................................ ៨

ខ អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី ........................................................ ៨

គ បុគ្គលដែលគេទាមទារមានសញ្ជាតិខ្មែរ ........................................................ ៨

ឃ ផ្សេងៗ ........................................................ ៩

**ផ្នែកទី២. ភាតព្វកិច្ចក្នុងការធ្វើបត្យាប័ន** ........................................................ ១០

**១. ការធ្វើបត្យាប័ន** ........................................................ ១០

**២. បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា** ........................................................ ១២

**៣. ក្របខណ្ឌច្បាប់ក្នុងការធ្វើបត្យាប័ន** ........................................................ ១៣

**៤. តម្លៃរវាងបត្យាប័ន និង ដីកាចាប់ខ្លួន** ........................................................ ១៤

**៥. ការហាមឃាត់ក្នុងការធ្វើបត្យាប័ន** ........................................................ ១៥

## ជំពូកទី២. លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ

**ផ្នែកទី១. បត្យាប័នផ្អែកតាមសន្ធិសញ្ញា** ............ ១៩
**១.១. សន្ធិសញ្ញាទ្វេភាគី** ............ ១៩
ក. អនុសញ្ញាទ្វេភាគីជាមួយប្រទេសបារាំង ............ ២០
ខ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសចិន ............ ២០
គ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសឡាវ ............ ២១
ឃ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសថៃ ............ ២១
ង. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសវៀតណាម ............ ២១
ច. សន្ធិសញ្ញាទ្វេភាគីជាមួយសហព័ន្ធរុស្ស៊ី ............ ២១
ឆ. កិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកូរ៉េ ............ ២២
ជ. កិច្ចព្រមព្រៀងស្តីពីផ្ទេរទណ្ឌិតជាមួយប្រទេសឥណ្ឌា ............ ២២
**១.២. សន្ធិសញ្ញាពហុភាគី** ............ ២២
**ផ្នែកទី២. បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា** ............ ២៣

## ជំពូកទី៣. នីតិវិធីក្នុងការធ្វើបត្យាប័ន និងការស្នើធ្វើបត្យាប័ន ដោយរដ្ឋកម្ពុជាចំពោះរដ្ឋបរទេស

**ផ្នែកទី១. នីតិវិធីនៃការធ្វើបត្យាប័ន** ............ ២៧
**១. សមត្ថកិច្ចទទួលបន្ទុកទទួល និង បញ្ជូនពាក្យសុំឲ្យធ្វើបត្យាប័ន** ............ ២៧
**១.១. ករណីពិសេសចំពោះពាក្យសុំឲ្យចាប់ខ្លួនបណ្តោះអាសន្ន** ............ ២៧
**១.២. សមត្ថកិច្ចធ្វើពាក្យបណ្តឹងសុំឲ្យធ្វើបត្យាប័ន** ............ ២៨
**១.៣. សមត្ថកិច្ចសម្រេចបត្យាប័ន** ............ ២៩
**១.៤. នីតិវិធីចំពោះមុខសភាស៊ើបសួរ** ............ ២៩
ក. សិទ្ធិ និង កាតព្វកិច្ចបុគ្គលដែលគេទាមទារ ............ ២៩
ខ. ការសម្រេចបត្យាប័ន និងយោបល់ដោយសភាស៊ើបសួរ ............ ៣០
គ. អានុភាពនៃយោបល់របស់សភាស៊ើបសួរ ............ ៣០
**ផ្នែកទី២. បត្យាប័នស្នើដោយប្រទេសកម្ពុជាចំពោះរដ្ឋបរទេស** ............ ៣១
**១. សិទ្ធិធ្វើបណ្តឹងមោឃភាពនៃបត្យាប័ន** ............ ៣១
**២. នីតិវិធីចំពោះមុខសភាស៊ើបសួរ** ............ ៣១

៣. អានុភាពនៃមោឃភាពបត្យាប័ន ........................................................................ ៣២
៣.១. អានុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព ....................................................... ៣២
៣.២. អានុភាពនៃមោឃកម្មចំពោះបត្យាប័ន ........................................................... ៣២
៤. ការយល់ព្រមរបស់រដ្ឋដែលបានផ្តល់អាណិកជនបរទេសដល់ប្រទេសកម្ពុជា ....... ៣៣
សេចក្តីសន្និដ្ឋាន ........................................................................................ ៣៤
អនុសាសន៍ ................................................................................................. ៣៦
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

នៅក្នុងប្រទេសមួយ ឬ រដ្ឋមួយចាំបាច់ណាស់ត្រូវតែមានច្បាប់សម្រាប់គ្រប់គ្រងប្រទេស ឬ រដ្ឋនោះ បើពុំដូច្នោះទេ ភាពចលាចល សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គម ពិតជាកើតឡើងឥតឈប់ឈរ ហេតុនេះហើយប្រទេសឬរដ្ឋនោះត្រូវតែមានច្បាប់សម្រាប់បង្ការទប់ស្កាត់និងអនុវត្តច្បាប់ចំពោះជនដែលប្រព្រឹត្តបទល្មើស។

ជាក់ស្តែងនៅក្នុងយុគសម័យដែល ការធ្វើដំណើរមានភាពងាយស្រួល ឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទល្មើសក្នុងប្រទេស ឬរដ្ឋណាមួយហើយអាចគេចពី សំណាញ់ច្បាប់និងរត់ទៅជ្រកកោនក្នុងប្រទេសមួយទៀតបានយ៉ាងងាយស្រួល។ បត្យាប័នជាយន្តការតាមរយៈនេះ រដ្ឋធ្វើសំណើអាចស្នើសុំរដ្ឋទទួលសំណើបញ្ជូនឧក្រិដ្ឋជនមកទទួលការកាត់ទោស ឬ ទទួលការអនុវត្តទោស។ នៅក្នុងន័យនេះ បត្យាប័ន ខុសពីការបណ្តេញចេញដែលសំដៅលើការដេញជនបរទេសដែលអស់អតិដ្ឋាការសម្រាប់ស្នាក់នៅ។ វាក៏ខុសអំពីការបញ្ជូនដោយរដ្ឋទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ នូវជនល្មើសដោយរដ្ឋជាសមាជិកតុលាការ ដែលមានកាតព្វកិច្ចបញ្ជូន។ ដោយសារបត្យាប័នឆ្លងកាត់នីតិវិធីស្មុគស្មាញរដ្ឋខ្លះបានប្រើនីតិវិធីក្រៅផ្លូវការដើម្បីទទួលបានឧក្រិដ្ឋជន។

តើការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជានេះ ត្រូវធ្វើឡើងតាមនីតិវិធី និងទម្រង់លក្ខខណ្ឌណាខ្លះ?

ជាពិសេសនិងមានក្របខណ្ឌច្បាប់អ្វីខ្លះសម្រាប់ការធ្វើបត្យាប័ន?

ជាការពិតណាស់នៅក្នុងសង្គមយើងបច្ចុប្បន្ននេះ មានមនុស្សមួយចំនួនមិនទាន់យល់ច្បាស់អំពីការធ្វើបត្យាប័នឡើយ។ ក្នុងការធ្វើបត្យាប័ននេះ នាសតវត្សទី១៩ប្រទេសជាច្រើនបានខិតខំ ប្រឹងប្រែងសហការ ក្នុងការនាំយកជនល្មើសមកផ្តន្ទាទោសទៅតាមច្បាប់នៃប្រទេសរបស់ខ្លួន ដែលបានបង្កើតជានីតិវិធីមួយជាក់លាក់តាមរយៈការចុះសន្ធិសញ្ញារវាងរដ្ឋនិងរដ្ឋស្តីពីបត្យាប័ន។ តាមរយៈការធ្វើសន្ធិសញ្ញានេះ ហើយដែលធ្វើការអនុញ្ញាតឲ្យរដ្ឋមួយដែលហៅថារដ្ឋដាក់សំណើ អាចធ្វើការស្នើសុំទៅរដ្ឋមួយទៀតដែលហៅថារដ្ឋទទួលសំណើ ក្នុងករណីដែលមានជនណាម្នាក់បានប្រព្រឹត្តបទល្មើសនៅប្រទេសដទៃ ដែលមិនមែនជាប្រទេសរបស់ខ្លួន។

ជាក់ស្តែងការស្នើសុំជនល្មើសរបស់រដ្ឋបរទេស ឬជារដ្ឋធ្វើសំណើដើម្បីស្នើសុំយកជនល្មើស ទៅធ្វើការចោទប្រកាន់និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់របស់ខ្លួន។ បុគ្គលដែលទាមទារ គឺជាអាណិកជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់របស់ប្រទេសដែលបានស្នើសុំ ឬជាកម្មវត្ថុនៃពាក្យស្នើសុំធ្វើបត្យាប័ន(មាត្រា៥៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ហេតុនេះហើយប្រទេសឬរដ្ឋនោះ ត្រូវតែមានច្បាប់សម្រាប់បង្ការទប់ស្កាត់ និងអនុវត្តច្បាប់ចំពោះជនដែលប្រព្រឹត្តិបទល្មើស បើពុំដូច្នោះទេអាចនិងមានភាពចលាចលអសន្តិសុខគ្មានសណ្តាប់ធ្នាប់ក្នុងសង្គមពិតជាកើតឡើងឥតឈប់ឈរ។

សម្រាប់ព័ត៌មាននេះ ដែលបានផ្តល់សេចក្តីសង្ខេបអំពីស្ថានភាពនៃការអនុវត្តការធ្វើបត្យាប័ន នាពេលបច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់មានលក្ខណៈជាក់លាក់នូវឡើយទេ នៅត្រង់ចំណុចមួយចំនួន និងមានភាពខ្វះចន្លោះនូវសិទ្ធិមនុស្សនិងដោយភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍ច្បាប់។

ចំពោះសលាកប័ត្រតាក់តែងដោយ **មជ្ឈមណ្ឌលសិទ្ធិមនុស្ស (ម.ស.ម.ក)** ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ទន្ទឹមនិងការកកើតនៃបត្យាប័នបច្ចុប្បន្ន ប្រទេសកម្ពុជាបានចុះសន្ធិសញ្ញាបត្យាប័នជាមួយនិងប្រទេសមួយចំនួន ដែលនៅក្នុងនោះរួមមាន៖

- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងព្រះរាជាណាចក្រថៃ ដែលបានអនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតចិន ដែលបានអនុម័តនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងសាធារណរដ្ឋប្រជាមានិតឡាវ ដែលបានអនុម័តនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងប្រទេសវៀតណាម ដែលបានអនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ដែលអនុម័តថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨
- អនុសញ្ញាស្តីពីបត្យាប័នរវាងរដ្ឋាភិបាលនៃប្រទេសកម្ពុជា ជាមួយនិងរដ្ឋាភិបាលសាធារណរដ្ឋបារាំង ដែលអនុម័តនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥
- កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលត្រូវបានអនុម័តនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។
- កិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសឥណ្ឌា អនុម័តនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩

បច្ចុប្បន្ននេះ នៅលើពិភពលោកយើង ជៀសមិនផុតពីការកើតមានឡើងបទល្មើសជាបន្តបន្ទាប់ ដែលបទល្មើសអាចត្រូវបានប្រព្រឹត្តដោយ ប្រជាជននៃប្រទេសនោះ ឬអាចបង្កដោយជនបរទេសដែលធ្វើដំណើរមកកាន់ប្រទេសនោះ ហើយបានរត់គេចខ្លួនទៅកាន់ប្រទេសដទៃ។ ដើម្បីជាការធានាបាននូវ សុខសុវត្ថិភាព និង

សណ្តាប់ធ្នាប់ក្នុងសង្គមជាតិព្រមទាំងការអភិវឌ្ឍន៍ ដែលជាហេតុនាំឲ្យគ្រប់បណ្តាប្រទេស ទាំងអស់ត្រូវតែខិតខំផ្សាភ្ជាប់នូវទំនាក់ទំនងគ្នាទៅវិញទៅមក។

ចំពោះប្រធានបទនេះមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រទេសកម្ពុជាយើងដែលប្រជាពលរដ្ឋយើងគួរតែយល់ដឹងអំពីការធ្វើបត្យាប័ននេះ។ ទាំងអស់នេះហើយដែលជាហេតុ នាំឲ្យយើងខ្ញុំទាំងពីរអ្នកជ្រើសរើសប្រធានបទស្តីពី "**បត្យាប័ន**" យកមកបកស្រាយ ក្នុងគោលបំណងស្វែងយល់ពីបញ្ហានេះអោយកាន់តែច្បាស់ថែមទៀត និងបានបន្សល់ទុកឯកសារនេះសម្រាប់ចែករំលែកដល់មិត្តៗដែលជាអ្នកនិយមស្រាវជ្រាវទាំងឡាយដែលមានបំណងចង់ស្វែងយល់បន្ថែមអំពីបត្យាប័នថែមទៀតផង។

លើសពីនេះទៅទៀតដើម្បីងាយស្រួលដល់ការសិក្សាស្រាវជ្រាវ និងដើម្បីអោយកាន់ច្បាស់លាស់ទៀតនោះយើងខ្ញុំទាំងពីរបានលើកយកចំណុចសំខាន់ៗមានបត្យាប័ន ផ្អែកតាមសន្ធិសញ្ញា, នីតិវិធីក្នុងការធ្វើបត្យាប័ន និងបត្យាប័នស្នើដោយរដ្ឋបរទេសចំពោះប្រទេសកម្ពុជា ដែលជាការសិក្សាស្រាវជ្រាវលើប្រធានបទមួយ អោយកាន់តែច្បាស់អំពីការធ្វើបត្យាប័នរវាងប្រទេសកម្ពុជា និងបណ្តាប្រទេសមួយចំនួនថែមទៀត។

យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងស្វែងយល់ទៅលើចំណុចដែលទាក់ទងទៅនិងប្រធានបទ ហើយបានបែងចែកជាឯកសារនិងបានចងក្រង ជាប្លង់សារណា និងបានដាក់ជូនលោកស្រីសាស្ត្រាចារ្យដើម្បីធ្វើការពិនិត្យនិងកែសម្រួល។ នៅពេលពិនិត្យនិងកែសម្រួលបានចប់សព្វគ្រប់រួចយើងខ្ញុំទទួលបានប្លង់ដែលបែងចែកជា បីជំពូកមានដូចជា៖

**ជំពូកទី១ សញ្ញាណទូទៅនៃបត្យាប័ន**

ផ្នែកទី១. ការកកើតនៃបត្យាប័ន

ផ្នែកទី២. កាតព្វកិច្ចក្នុងការធ្វើបត្យាប័ន

**ជំពូកទី២ លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋនិងរដ្ឋ**

ផ្នែកទី១. បត្យាប័នផ្អែកតាមសន្ធិសញ្ញា

ផ្នែកទី២. បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា

**ជំពូកទី៣ នីតិវិធីក្នុងការធ្វើបត្យាប័ន និងការស្នើធ្វើបត្យាប័នដោយប្រទេសកម្ពុជាចំពោះរដ្ឋបរទេស**

ផ្នែកទី១. នីតិវិធីក្នុងការធ្វើបត្យាប័ន

ផ្នែកទី២. ការស្នើធ្វើបត្យាប័នដោយប្រទេសកម្ពុជាចំពោះបរទេស

# ជំពូកទី ១

# សញ្ញាណទូទៅនៃបត្យាប័ន

# ជំពូកទី១
# សញ្ញាណទូទៅនៃបត្យាប័ន

## ផ្នែកទី១. ការកកើតនៃបត្យាប័ន

ការកកើតនៃបត្យាប័ន នៅពេលរដ្ឋបរទេសបានដាក់សំណើស្នើសុំអោយព្រះរាជាណាចក្រកម្ពុជា ប្រគល់អាណិកជនបរទេសណាមួយ ឬកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា ដើម្បីយកបុគ្គលដែលទាមទារនោះមកធ្វើការចោទប្រកាន់តាមផ្លូវតុលាការ ឬ ផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋដែលបានស្នើសុំនោះ។ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ពិនិត្យមើលនិយ័តភាព នៃការស្នើសុំធ្វើបត្យាប័ន រួចសម្រេចប្រគល់អាណិកជនបរទេសនោះឲ្យរដ្ឋស្នើសុំពេលនោះកកើតមាននូវការធ្វើបត្យាប័ន ហើយបុគ្គលដែលរដ្ឋបរទេសទាមទារ គឺជាកម្មវត្ថុនៃការធ្វើបត្យាប័ន[1]។

### ១. និយមន័យ

ជាដំបូងមុននិងឈានទៅដល់ឋានានុក្រមនៃច្បាប់អនុវត្តលើបត្យាប័ន និងចំណុចសំខាន់ដែលទាក់ទង និងកាតព្វកិច្ចក្នុងការធ្វើបត្យាប័ន យើងគួរគប្បីយល់នូវពាក្យគន្លឹះមួយចំនួនជាមុនសិន ដែលមានដូចជាៈ បត្យាប័ន, រដ្ឋធ្វើសំណើ, បុគ្គលទាមទារ និងអាណិកជន។

- **បត្យាប័ន**

បត្យាប័ន គឺជានីតិវិធីមួយនៃការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយទៀត ឬជានីតិវិធីមួយដែលរដ្ឋធ្វើសំណើ សុំជនណាម្នាក់ទៅរដ្ឋមួយទៀត ដើម្បីយកជននោះមកធ្វើជាការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះមកអនុវត្តទោស នៅក្នុងប្រទេសរបស់ខ្លួន។ តាមន័យនេះអាចបញ្ជាក់ថាបត្យាប័នគឺ មិនមែនសុទ្ធតែអាចធ្វើបានចំពោះគ្រប់បទល្មើសទាំងអស់នោះទេ។

ជាឧទាហរណ៍ៈ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាហាមមិនអោយធ្វើបត្យាប័នចំពោះបទល្មើស ដែលមានលក្ខណៈនយោបាយឡើយ។

- **រដ្ឋធ្វើសំណើ**

រដ្ឋធ្វើសំណើ គឺជារដ្ឋបរទេសដែលស្នើសុំឲ្យធ្វើបត្យាប័នអាណិកជនបរទេស[2]។ រដ្ឋបរទេសមានកាតព្វកិច្ចក្នុងការធ្វើសំណើស្នើទៅប្រទេសបុគ្គលមានសញ្ជាតិរបស់ខ្លួន បានទៅស្នាក់អាស្រ័យ ក៏ដូចជាប្រកបមុខរបរនៅក្នុងប្រទេសដទៃ បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសនោះ ក្នុងគោលបំណងដើម្បី

[1]អត្ថបទស្តីពី បត្យាប័នរៀបរៀងដោយ លោក ជុំ គីរី

[2]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៦៨

យកបុគ្គលនោះមកផ្តន្ទាទោស នៅក្នុងប្រទេសរបស់ខ្លួនវិញ ទៅតាមច្បាប់ដែលបានចែងក្នុងរដ្ឋដែលបានធ្វើសំណើនោះ។

- **បុគ្គលទាមទារ**

បុគ្គលទាមទារ គឺជាអាណិកជនបរទេសដែលបានស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការចោទប្រកាន់ ឬការផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់របស់ប្រទេស ដែលបានស្នើសុំឬជាកម្មវត្ថុនៃពាក្យស្នើសុំធ្វើបត្យាប័ន។

- **អាណិកជន**

អាណិកជន គឺជនជាតិនានាដែលនៅអាស្រ័យទៅនិងប្រកបរបរក្នុងប្រទេសដទៃ[3]។ អាណិកជនត្រូវគោរព និងអនុវត្តទៅតាមច្បាប់របស់រដ្ឋដែលខ្លួនបានមករស់នៅ ទោះបីជាខ្លួនទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ។

## ២. ឋានានុក្រមនៃច្បាប់អនុវត្តលើបត្យាប័ន

- បទដ្ឋានគតិយុត្តអន្តរជាតិ អនុសញ្ញាអន្តរជាតិដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា ត្រូវយកទៅគ្រប់គ្រងលើនីតិវិធីនៃការធ្វើបត្យាប័នអាណិកជនដែលត្រូវចាប់ខ្លួនលើដែនដីនៃប្រទេសកម្ពុជា។
- ច្បាប់ជាតិប៉ុន្តែប្រសិនបើគ្មានអនុសញ្ញាអន្តរជាតិដែលត្រូវ ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាទេ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧នៃកម្ពុជា ត្រូវយកទៅអនុវត្ត។ ផ្ទុយទៅវិញក្រមនេះមិនត្រូវយកទៅអនុវត្តឡើយ ប្រសិនបើនីតិវិធីនៃការធ្វើបត្យាប័នត្រូវអនុវត្តតាមច្បាប់ដោយឡែក។

## ៣. លក្ខខណ្ឌអនុញ្ញាតនៃបត្យាប័ន

### ក. លក្ខខណ្ឌទាក់ទងនិងអំពើ ឬ ទិកនភាពនៃបទល្មើស

លក្ខខណ្ឌនេះ សំដៅទៅដល់អំពើដែលត្រូវបានគេចោទប្រកាន់លើបុគ្គលដែលគេទាមទារ គឺជាបទល្មើសដែលមានចែងក្នុងច្បាប់របស់ប្រទេសកម្ពុជា និងរដ្ឋធ្វើសំណើ (រដ្ឋភាគីនៃបត្យាប័ន) ហើយបើទោះបីជា៖

- អំពើដែលជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសស្មើគ្នាក្តី ប្រភេទបទល្មើស បទល្មើសសាមញ្ញ បទល្មើសឃោធា បទល្មើសគ្រឿងញៀន ។
- ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬ និយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី (ឧទាហរណ៍ឈ្មោះបទល្មើស ឃាតកម្ម និង មនុស្សឃាតដោយចេតនា) ឬ

[3] សម្តេចសង្ឃ ជួន ណាត, វចនានុក្រម

- ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋផ្ញើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលមានចែងក្នុងច្បាប់កម្ពុជាក៏ដោយប្រសិនបើពិចារណាទៅលើចំនួនសរុប នៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋផ្ញើសំណើ គឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា[4]។

បន្ថែមពីនេះ ក្នុងករណីអំពើដែលត្រូវបានចោទប្រកាន់តាមច្បាប់ នៃរដ្ឋផ្ញើសំណើ គ្រាន់តែជាការប៉ុនប៉ង ឬជាការសមគំនិត នោះអាចធ្វើបត្យាប័នលុះត្រាតែ ការប៉ុនប៉ង និងសមគំនិតនោះ ត្រូវបានផ្តន្ទាទោសតាមច្បាប់កម្ពុជា[5]។ ជាឧទាហរណ៍ ប្រសិនបើការប៉ុនប៉ង ក្នុងការប្រព្រឹត្តអំពើទទួលផលចោរកម្ម ត្រូវបានច្បាប់នៃរដ្ឋផ្ញើសំណើ កំណត់ថាជាបទល្មើស និងត្រូវផ្តន្ទាទោសតាមច្បាប់របស់ប្រទេសនោះ ក៏ប៉ុន្តែតាមក្រមព្រហ្មទណ្ឌកម្ពុជាមិនបានកំណត់ថា ការប៉ុនប៉ងក្នុងបទល្មើសនេះ ត្រូវបានផ្តន្ទាទោសឡើយ ដូច្នេះទោះបីកម្ពុជា មិនអាចបញ្ជូនបុគ្គលដែលគេទាមទារ តាមរយៈបត្យាប័ន ឲ្យទៅរដ្ឋនោះដែរ។

សរុបសេចក្តីមក ការស្នើសុំបត្យាប័នត្រូវបានអនុញ្ញាតផងដែរ កាលណាការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការសមគំនិត (អ្នកសមគំនិត) មានចែងក្នុងច្បាប់កម្ពុជា និងរដ្ឋផ្ញើសំណើ។

## ខ. លក្ខខណ្ឌទាក់ទងនិងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា

មាត្រា ៥៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា "បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋផ្ញើសំណើ"។ កាលណាអំពើដែលត្រូវបានចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យាប័នមិនអាចធ្វើបានទេ ក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានរលត់តាមច្បាប់កម្ពុជា។ ដោយយោងតាមអត្ថន័យនៃមាត្រាខាងលើ អាចទាញចេញជាពីរសម្មតិកម្មៈ

- សម្មតិកម្មទី១៖ បត្យាប័នអាចធ្វើបាន

– ប្រសិនបើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមិនទាន់រលត់តាមច្បាប់រដ្ឋភាគីនៃបត្យាប័ន (ប្រទេសកម្ពុជានិងរដ្ឋផ្ញើសំណើ)។

– ប្រសិនបើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា មិនទាន់រលត់តាមច្បាប់ផ្ញើសំណើ ទោះបីអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាបានរលត់តាមច្បាប់ប្រទេសកម្ពុជាក៏ដោយ ក្នុងករណីអំពើដែលត្រូវចោទប្រកាន់ប្រព្រឹត្តក្រៅដែនដីនៃប្រទេសកម្ពុជា។

- សម្មតិកម្មទី២៖ បត្យាប័នមិនអាចធ្វើបាន

– ប្រសិនបើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់តាមច្បាប់កម្ពុជាក្នុងករណីអំពើដែលត្រូវចោទប្រកាន់ប្រព្រឹត្តលើដែនដីប្រទេសទោះបីជាអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមិនទាន់រលត់តាមច្បាប់រដ្ឋផ្ញើសំណើក៏ដោយ។

[4]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៦៩

[5]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៧០

### គ. លក្ខខណ្ឌទាក់ទងនិងទីកន្លែងប្រព្រឹត្តបទល្មើស

ក្នុងលក្ខខណ្ឌបត្យាប័នទាក់ទងនឹងទីកន្លែងប្រព្រឹត្តបទល្មើស គឺសំដៅទៅដល់បទល្មើសដែលត្រូវបានប្រព្រឹត្តលើដែនដីនៃរដ្ឋផ្ញើសំណើ។ ដោយផ្អែកតាមមាត្រា ៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចចែកចេញជាពីរករណីដូចខាងក្រោម៖

- ករណីបទល្មើសប្រព្រឹត្តលើដែនដីនៃរដ្ឋផ្ញើសំណើ៖ អាចធ្វើបត្យាប័នបុគ្គលដែលគេទាមទារដែលមាន នឹងគ្មានសញ្ជាតិ របស់រដ្ឋផ្ញើសំណើ។
- ករណីបទល្មើសប្រព្រឹត្តក្រៅដែនដីនៃរដ្ឋផ្ញើសំណើ៖ អាចធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារដែលមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើតែប៉ុណ្ណោះ។

បន្ថែមពីនេះ គឺរាល់បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋសំណើទោះបីជនល្មើសមិនមានសញ្ជាតិនៃរដ្ឋដាក់សំណើក៏ដោយ ឬ ជនល្មើសមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើ ទោះបីបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋសំណើក៏ដោយ ។

### ឃ. លក្ខខណ្ឌទាក់ទងនិងទោសពន្ធនាគារ

បត្យាប័នអាចធ្វើបានចំពោះតែបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ដែលមិនមែនជាការពិន័យជាប្រាក់ឡើយតាមច្បាប់នៃរដ្ឋផ្ញើសំណើ។ បន្ថែមពីនេះទោសដាក់ពន្ធនាគារ ទាមទារឲ្យកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារយ៉ាងតិចចាប់ពី២(ពីរ)ឆ្នាំឡើងទៅចំពោះបុគ្គលដែលគេទាមទារតាមច្បាប់របស់រដ្ឋផ្ញើសំណើ។

ប៉ុន្តែជាករណីលើកលែង បត្យាប័នអាចធ្វើបានប្រសិន បើតុលាការរបស់រដ្ឋផ្ញើសំណើផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនិង៦(ប្រាំមួយ)ខែហើយសេចក្តីសម្រេចផ្តន្ទាទោសនោះបានចូលជាស្ថាពរហើយ[6]។

លើសពីនេះទៅទៀត បើជនបរទេសណាម្នាក់ បានប្រព្រឹត្តបទល្មើស នៅលើដែនដីនៃរដ្ឋផ្ញើសំណើ ហើយជននោះបានរត់គេចខ្លួនមកលើទឹកដីកម្ពុជា ប្រទេសកម្ពុជា ក៏អាចធ្វើបត្យាប័នតាមការស្នើសុំដែរ។ ផ្ទុយទៅវិញ ឲ្យតែបុគ្គលដែលគេទាមទារ មានសញ្ជាតិរដ្ឋផ្ញើសំណើ ទោះបីជននោះ មិនបានប្រព្រឹត្តបទល្មើសលើដែនដីនៃរដ្ឋនោះក៏ដោយ ក៏កម្ពុជាអាចធ្វើបត្យាប័នបានដែរ។

### ង. លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងនិងពាក្យសុំឲ្យធ្វើបត្យាប័ន

លក្ខខណ្ឌនេះ គឺទាមទារឲ្យរដ្ឋផ្ញើសំណើសន្យាថា និងមិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលខ្លួនបានស្នើសុំក្នុងពាក្យសុំឲ្យធ្វើបត្យាប័ន ដែលបានដាក់ជូនរដ្ឋាភិបាលកម្ពុជាហើយនោះទេ។ ប៉ុន្តែ រដ្ឋផ្ញើសំណើអាចចោទប្រកាន់បទល្មើសណាមួយផ្សេងបន្ថែមទៀត ឬ បទល្មើសណាមួយផ្សេងក្រៅពី

[6]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៧១

បទល្មើសដែលបានចែងក្នុងពាក្យសុំឲ្យ ធ្វើបត្យាប័នបានប្រសិនបើប្រទេសកម្ពុជា យល់ព្រមប៉ុន្តែតម្រូវឲ្យរដ្ឋធ្វើសំណើជូនពាក្យស្នើសុំបន្ថែមមករដ្ឋាភិបាលកម្ពុជា[7]។

សរុបសេចក្តីមក កម្ពុជាអាចផ្តល់បត្យាប័នជូនជនដែលស្នើសុំបត្យាប័ន លុះត្រាតែរដ្ឋបរទេសនោះសន្យាថាមិនចោទប្រកាន់បទល្មើសផ្សេងទៀត ទៅលើបុគ្គលនេះទេលើកលែង តែមានការយល់ព្រមពីរដ្ឋកម្ពុជា (មាត្រា ៥៧៧ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

## ៤. លក្ខខណ្ឌហាមឃាត់ ឬបដិសេធ

### ក. អំពើមានលក្ខណៈនយោបាយ

តាមក្រមនីតិវិធីព្រហ្មទណ្ឌ បត្យាប័នមិនត្រូវបានអនុញ្ញាត ចំពោះបទល្មើសមានលក្ខណៈនយោបាយទេ។ លើសពីនេះ តាមច្បាប់សារធាតុក៏គ្មានចែងអំពីបទល្មើសនយោបាយនោះដែរ។ ហេតុនេះ វាជាការសមហេតុផលចំពោះអំពើដែលត្រូវ ចោទប្រកាន់មានលក្ខណៈនយោបាយ មិនត្រូវបានអនុញ្ញាតឲ្យធ្វើបត្យាប័នទេ។ ប៉ុន្តែអំពើហិង្សា ដែលធ្វើឲ្យគ្រោះថ្នាក់ដល់អាយុជីវិត ដល់បូរណភាពរូបកាយ ឬដល់សេរីភាពបុគ្គលមិនមែនជាបទល្មើសនយោបាយទេ ក្នុងករណីនេះបត្យាប័នត្រូវតែអនុញ្ញាត[8]។ នៅក្នុងករណីនេះអាចនឹងតម្រូវឲ្យរដ្ឋធ្វើសំណើផ្តល់ភស្តុតាងផ្ទុយយ៉ាងណាដើម្បីបញ្ជាក់ថា អំពើដែលត្រូវបានចោទប្រកាន់ មិនមែនជាបទល្មើសមានលក្ខណៈនយោបាយនោះទេតែជាបទល្មើសនៃនីតិរួមដើម្បីឲ្យកម្ពុជាអាចធ្វើបត្យាប័នឲ្យបាន។

### ខ. អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី

អំពើដែលត្រូវបានចោទប្រកាន់បានប្រព្រឹត្តលើដែនដីកម្ពុជា និងត្រូវបានជំនុំជម្រះស្ថាពររួចហើយនៅក្នុងប្រទេសកម្ពុជា គឺកម្ពុជាមិនអាចធ្វើបត្យាប័នតាមសំណើរបស់រដ្ឋធ្វើសំណើបានទេ តែត្រូវអនុវត្តដាក់ទោសលើបុគ្គលដែលគេទាមទារតាមអំណាចសេចក្តីសម្រេច (សាលក្រម ឬសាលដីកា) ស្ថាពររបស់តុលាការកម្ពុជាតែម្តង[9]។

### គ. បុគ្គលដែលគេទាមទារមានសញ្ជាតិខ្មែរ

ប្រទេសកម្ពុជាមិនអាចធ្វើបត្យាប័នពលរដ្ឋខ្មែរ ឲ្យទៅរដ្ឋបរទេសណាមួយបានឡើយ នេះដោយយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានបញ្ញត្តិក្នុងមាត្រា៣៣ ថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបាន

[7]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៧៧

[8]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៧៣

[9]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៧៤

ដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក"[10]។

ឧទាហរណ៍៖ ប្រសិនបើប្រជាពលរដ្ឋកម្ពុជាបានប្រព្រឹត្តបទល្មើសនៅលើទឹកដីប្រទេសវៀតណាមផ្ទាល់ ដែលជាក់ស្តែងនៅប្រទេសវៀតណាមបានបញ្ញត្តិពីស្ថានទម្ងន់ទោសទៅតាមច្បាប់នៃប្រទេសគេយ៉ាងច្បាស់ បើក្នុងករណីបុគ្គលខ្មែរយើងដែលប្រព្រឹត្តបទល្មើសនៅឯប្រទេសវៀតណាមនោះ អាចឈានទៅដល់ការប្រហារជីវិត ដូច្នេះ យើងត្រូវរៀបពាក្យស្នើសុំការប្រគល់ជនល្មើសនោះ មកកាត់ទោសតាមច្បាប់ជាតិរបស់យើងវិញ។ ពីព្រោះកម្ពុជា បានសម្រេចលុបចោលទោសប្រហារជីវិតនៅក្នុងឆ្នាំ១៩៨៩ ពោល គឺនៅក្នុងសម័យកាលគ្រប់គ្រង និងដឹកនាំដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជានេះ ត្រូវបានបង្កើតឡើងដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលបានរួមគ្នា ជាមួយនិងកងទ័ពវៀតណាមវាយផ្តួលរលំរបបខ្មែរក្រហម។ ការលុបចោលទោសប្រហារជីវិតនេះ ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ៣២។ មាត្រានេះ បានចែងថា៖ «ពលរដ្ឋទាំងអស់ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសុវត្ថិភាពផ្ទាល់ខ្លួន ដោយគ្មានទោសប្រហារជីវិតឡើយ»។ ទោសប្រហារជីវិត នេះ ត្រូវបានជំនួសដោយទោសជាប់ពន្ធនាគារមួយជីវិតវិញ។[11]

### ឃ. ផ្សេងៗ

ក្នុងផ្នែកនេះ អាចមានករណីច្រើនទៅតាមស្ថានភាពនីមួយៗ ដែលកម្ពុជាអាចបដិសេធសំណើសុំធ្វើបត្យាប័នរបស់រដ្ឋបរទេសណាមួយបាន។ ជាឧទាហរណ៍ ប្រសិនក្រឡេកមើលទៅលើការដាក់ទោសទណ្ឌតាមច្បាប់ប្រទេសមួយចំនួនលើសកលលោក ឃើញថាទណ្ឌកម្មតាមច្បាប់ព្រហ្មទណ្ឌរបស់ពួកគេមានលក្ខណៈកាចសាហាវ ឃោឃៅ និង ព្រៃផ្សៃ ដូចជាទោសប្រហារជីវិត (ចងក ដុតសម្លាប់មនុស្សទាំងរស់ ឲ្យធ្វើអត្តឃាតដោយខ្លួនឯង) ឬទារុណកម្ម (ដោយការវាយដំយ៉ាងធ្ងន់ធ្ងរ) ជាដើម។ ដោយឡែក តាមច្បាប់នៃប្រទេសកម្ពុជាវិញ ទោះបីជាមុខងារចម្បងនីតិវិធីព្រហ្មទណ្ឌ គឺដើម្បីបង្ក្រាបរាល់បទល្មើស (មុខងារបង្ក្រាប) និង បង្ការបទល្មើស (មុខងារបង្ការ) ទៅលើទណ្ឌិត ឬបុគ្គលដទៃផ្សេងទៀតក៏ដោយ[12]ប៉ុន្តែចំពោះទណ្ឌកម្មវិញ ពុំមានលក្ខណៈកាចសាហាវដូចទោសរបស់ប្រទេសមួយចំនួន ដែលបានរៀបរាប់នៅខាងលើឡើយ។ ដោយផ្អែកតាមគោលការណ៍មនុស្សធម៌ (សណ្តោស) នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការដាក់ទោសទណ្ឌទៅលើជនល្មើស គឺពុំមានគោលបំណងបង្កឲ្យមានការឈឺចាប់លើរូបរាងកាយលើបុគ្គល ឬបន្ទាបបន្ថោកកេរ្តិ៍ឈ្មោះ ឬ កិត្តិយសរបស់ជនល្មើស

---

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា៣៣

[11] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា ៣២

[12] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារឆ្នាំ២០១៧ ទំព័រទី១

ឡើយ។ផ្ទុយទៅវិញការដាក់ទោសទណ្ឌិត គឺក្នុងគោលបំណងដើម្បីអប់រំ ជនល្មើសឲ្យប្រែក្លាយជាពលរដ្ឋល្អ ជាសមាជិកបរិសុទ្ធដែលធ្វើអោយប្រយោជន៍ដល់សង្គមជាតិវិញ[13]។ ជាក់ស្តែងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នៃកម្ពុជាដែលជាច្បាប់សារធាតុ ព្រមទាំងច្បាប់ដោយឡែកផ្សេងទៀត ពុំមានចែងអំពីទោសប្រហារជីវិតនោះទេ គឺមានតែទោសដាក់ពន្ធនាគារ (កំណត់កាល និង មួយជីវិត) និង ពិន័យជាប្រាក់តែប៉ុណ្ណោះ។

ហេតុដូច្នេះ ក្នុងករណីដែលរដ្ឋបរទេសណាមួយ បានស្នើសុំឲ្យប្រទេសកម្ពុជាធ្វើបត្យាប័នបុគ្គលដែលគេទាមទាមណាមួយដើម្បីយកទៅប្រហារជីវិតតាមច្បាប់នៃរដ្ឋធ្វើសំណើជាដើម នោះប្រទេសកម្ពុជាអាចបដិសេធនូវសំណើសុំធ្វើបត្យាប័នរបស់រដ្ឋបរទេសនោះបាន។

## ផ្នែកទី២. កាតព្វកិច្ចក្នុងការធ្វើបត្យាប័ន

កាតព្វកិច្ចក្នុងការធ្វើបត្យាប័ន មានក្នុងទម្រង់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ សន្ធិសញ្ញា ពហុភាគី ឬទ្វេភាគី ដូចជាសន្ធិសញ្ញារវាងកម្ពុជា និងរដ្ឋបរទេសមួយចំនួន។ ប្រទេសខ្លះព្រមធ្វើបត្យាប័ន ដោយមិនចាំបាច់មានកិច្ចព្រមព្រៀងទេតាមគោលការណ៍បដិការណ៍។ នេះប្រកាន់យកភាគច្រើនដោយរដ្ឋនៃប្រព័ន្ធស៊ីវិលឡ។ រដ្ឋក្រុមនេះ ជាទូទៅមិនធ្វើបត្យាប័នជនជាតិខ្លួនឯងទេ ដែលតម្រូវឲ្យមានយុត្តាធិការទូលាយ សម្រាប់ជាការកាត់ទោសប្រជាពលរដ្ឋខ្លួន ដែលប្រព្រឹត្តបទល្មើសនៅក្រៅប្រទេស តាមគោលការណ៍ Active National Principle ក្នុងដំណើរការបត្យាប័ន រដ្ឋនៃប្រព័ន្ធស៊ីវិលឡ ទាមទារតែឯកសារគាំទ្រមួយចំនួនខុសគ្នានឹងប្រទេសនៃប្រព័ន្ធច្បាប់កុំមុនឡ (Common Law) ដែលទាមទារនូវកម្រិតភស្តុតាងបង្ហាញថា បុគ្គលដែលគេចង់បាននោះ បានប្រព្រឹត្តបទល្មើសពិតមែន។ បន្ថែមលើនេះប្រទេសកុំមុនឡ (Common Law) ប្រកាន់យកយុត្តាធិការចង្អៀតមានសមត្ថកិច្ចកាត់ទោសតែបទល្មើសកើតក្នុងដែនដីខ្លួន។ ដូចនេះហើយការធ្វើបត្យាប័នអាចទៅរួច ជាទូទៅលុះត្រាមានកិច្ចព្រមព្រៀងទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចបត្យាប័ន ទោះបីក្នុងសន្ធិសញ្ញាពហុភាគី ឬ ទ្វេភាគី ក្តី គឺមិនមានភាពដាច់ខាតទេ។ អនុសញ្ញា ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម មាត្រា ៧ ចែងថា រដ្ឋបើមិនធ្វើបត្យាប័ន ត្រូវកាត់ទោសជនល្មើសដោយតុលាការខ្លួនឯង។

### ១. ការធ្វើបត្យាប័ន

ការធ្វើបត្យាប័នអាចត្រូវបានកំណត់និយមន័យថាជា ការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ ("រដ្ឋដែលត្រូវបានស្នើសុំ") ទៅអោយអាជ្ញាធររបស់រដ្ឋមួយទៀត ("រដ្ឋដែលបានធ្វើការស្នើសុំ") ក្នុងគោលបំណងផ្តន្ទាទោសព្រហ្មទណ្ឌ ឬជាការអនុវត្តន៍ការកាត់ទោស។ ទោះបីជាការធ្វើបត្យាប័នមិនមែនជាទស្សនៈថ្មីក៏ដោយ សកល

[13]លោកសាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌ, ទំព័រទី០៦

ភារូបនីយកម្ម និងការធ្វើដំណើររបស់ប្រជាជន ឆ្លងកាត់ព្រំដែន និងយុត្តាធិការរដ្ឋ បានធ្វើឲ្យគោលការណ៍ណែនាំជាក់លាក់សម្រាប់ការធ្វើបត្យាប័ន ឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់នោះ និងត្រូវផ្តន្ទាទោសក្លាយទៅជាភាពចាំបាច់បំផុត។[14]

***ការធ្វើបត្យាប័ននៅប្រទេសកម្ពុជា**

ការធ្វើបត្យាប័នប្រជាពលរដ្ឋខ្មែរ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ដែលបានចែងក្នុងមាត្រា៣៣ ថា **"ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀង ជាមួយគ្នាទៅវិញទៅមក"**។ ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានចែងថា អំពីសន្ធិសញ្ញាអន្តរជាតិដែលមានកម្មវិធីជាភាគី ត្រូវដាក់បញ្ចូនក្នុងច្បាប់ជាតិ។ កម្ពុជាគឺជាប្រទេសដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាបែបនេះជាច្រើន ដែលមានបំណងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលហេតុនេះហើយ ប្រទេសកម្ពុជាត្រូវអនុវត្តតាមសន្ធិសញ្ញានេះ នៅពេលធ្វើសេចក្តីសម្រេចធ្វើបត្យាប័ន។[15]

ការធ្វើបត្យាប័នត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧("ក្រម")។ ក្រមនេះអាចយកមកអនុវត្តក្នុងការស្នើសុំ ការធ្វើបត្យាប័ន នៅពេលអនុវត្តមានសន្ធិសញ្ញានៃការធ្វើបត្យាប័ន រវាងប្រទេសកម្ពុជា និងរដ្ឋដែលបានស្នើសុំការធ្វើបត្យាប័ន។ ក្រមនេះបានរៀបរាប់យ៉ាងលម្អិត អំពីដែនកំណត់នៃការធ្វើបត្យាប័ន និងមូលហេតុដែលការធ្វើបត្យាប័នអាចត្រូវបានបដិសេធ ព្រមទាំងបានរួមបញ្ចូលបទបញ្ញាដែលមានការទទួលស្គាល់ ក្នុងសន្ធិសញ្ញាអន្តរជាតិ។ ក្រមនេះក៏បានរៀបរាប់ អំពីនីតិវិធីនៃការស្នើសុំការធ្វើបត្យាប័នផងដែរ។ ទោះបីជាប្រទេសកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាធ្វើបត្យាប័ន ជាមួយប្រទេសតែបី (ចិន ថៃ និងឡាវ) ក៏ដោយ បទបញ្ញត្តិនៃការធ្វើបត្យាប័ន ដែលមាននៅក្នុងក្រមនេះ បានផ្តល់គោលការណ៍ណែនាំដែលមានសារៈសំខាន់បំផុត អំពីនីតិវិធីធ្វើបត្យាប័ននៅប្រទេសកម្ពុជា។

ការធ្វើបត្យាប័ន ទាមទារនូវការគោរពគោលការណ៍ចម្បងមួយចំនួន ដូចជា តម្រូវថា បទល្មើសទោះមានឈ្មោះខុសគ្នាក្តី ត្រូវតែជាបទល្មើសចែងក្នុងច្បាប់របស់ប្រទេសទាំងពីរ ដែលមានទោសយ៉ាងតិច ១ឆ្នាំ ឬ ទោសដែលត្រូវបានអនុវត្តក្នុងពន្ធនាគារនៅសល់ ៦ខែ (វាប្រែប្រួលតាមការកំណត់ច្បាប់ ឬសន្ធិសញ្ញានីមួយៗតម្រូវ)។ ទោះបីជាយ៉ាងនេះក្តី បទល្មើសមួយចំនួន មិនត្រូវបានចាត់ថាជាបទល្មើសអាចបត្យាប័នបានទេ ដែលពីមុន បទល្មើសទាំងនេះមានច្រើនតែមកដល់ពេលនេះ នៅសល់ចំនួនតិចតួចណាស់ មានដូចជាបទល្មើសយោធា ឬនយោបាយ មិនមែននិយមន័យនៃបទល្មើសនយោបាយជាក់លាក់ទេ។

[14]កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់របស់ ម.ស.ម.ស វគ្គ៧"ច្បាប់ស្តីពីការធ្វើបត្យាប័ន" ឆ្នាំ២០១២

[15]កម្រងឯកសារស្តីពីការធ្វើចំណាត់ថ្នាក់របស់ ម.ស.ម.ស វគ្គ៧"ច្បាប់ស្តីពីការធ្វើបត្យាប័ន" ឆ្នាំ២០១២

ឧទាហរណ៍៖ ការសម្លាប់ប្រមុខរដ្ឋ មិនមែនជាបទល្មើសនយោបាយទេ។ ប្រទេសមួយចំនួនដែលបាន អភិវឌ្ឍន៍នូវលក្ខណៈវិនិច្ឆ័យ សម្រាប់ក្នុងការកំណត់ថា អ្វីជាបទល្មើសនយោបាយដោយផ្តោតសំខាន់ទៅលើ គោលបំណងនៃសកម្មភាព គឺការផ្លាស់ប្តូររបបដឹកនាំនយោបាយ។

ដូចបញ្ជាក់ខាងលើ កាតព្វកិច្ចធ្វើក្នុងការធ្វើបត្យាប័នមិនមានភាពដាច់ខាតនោះទេ។ វាមានកម្រិត ដែល អាចនាំឲ្យមានការបដិសេធបាន។ មូលដ្ឋានបដិសេធមានចំនួនពីរ គឺដាច់ខាត និងមិនដាច់ខាត។

- ទីមួយ រាល់បញ្ចូលនូវការហួសថេរវេលានៃការចោទប្រកាន់ និង
- ទីពីរ រាល់បញ្ចូល ការវិនិច្ឆ័យសេចក្តីនៅក្នុងរដ្ឋស្នើសុំ ដោយគ្មានវត្តមានរបស់ជនល្មើស។

មូលហេតុមួយចំនួន ទទួលឥទ្ធិពលពីការលើកកម្ពស់ ឬការពារសិទ្ធិមនុស្ស។ ដូចករណី បញ្ជូនទៅរងនូវ ទោសប្រហារជីវិត សន្ធិសញ្ញា ទាមទារឲ្យមានការសុំការធានាបានការកុំឲ្យទោសប្រហារជីវិត ត្រូវបានអនុវត្ត ដោយសារ ស្ថានភាពមុនសម្លាប់ ឬវិធីសម្លាប់ អាចជាអំពើអមនុស្សធម៌ បំពានមាត្រាសិទ្ធិមនុស្ស។ អនុសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម មាត្រា ៣ ហាមមិនឲ្យធ្វើបត្យាប័ន ប្រសិនបើជននោះនឹងទទួលរងនូវគ្រោះ ដោយសារអំពើទារុណកម្ម ក្រោយពេលបញ្ជូនទៅ។[16]

ទាក់ទងទៅក្នុងដំណើរការធ្វើបត្យាប័ន វាក៏ទាមទារនូវការគោរពសិទ្ធិមនុស្ស នឹងអធិបតេយ្យភាពរបស់ រដ្ឋផងដែរ។ ក្នុងន័យនេះ គោលការណ៍ពិសេស ត្រូវបានចែងក្នុងសន្ធិសញ្ញាបត្យាប័ន និង ទាមទារឲ្យគោរព។ រដ្ឋ ទទួលមិនត្រូវចោទប្រកាន់ជនល្មើស ក្រៅពីបទល្មើស មានចែងក្នុងសំណើបត្យាប័ន ហើយបើចង់ធ្វើត្រូវសុំការ អនុញ្ញាតរួចទើបបញ្ជូន។

## ២. បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា

មានភាពមិនស៊ីសង្វាក់គ្នាមួយចំនួនរវាងសន្ធិសញ្ញាគំរូរបស់ **អ.ស.ប** និងបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការ ធ្វើបត្យាប័នរបស់កម្ពុជា ដូចជារយៈពេលនៃការឃុំខ្លួនជនសង្ស័យដែលត្រូវបានអនុញ្ញាត នៅពេលពិចារណាលើ សំណើធ្វើបត្យាប័ន ៖ ខណៈពេលដែលសន្ធិសញ្ញាគំរូរបស់ **អ.ស.ប** អនុញ្ញាតឲ្យមានរយៈពេលត្រឹម៤០ថ្ងៃ ក្រម នេះអនុញ្ញតឲ្យមានរយៈពេល៦០ថ្ងៃ។ ជាងនេះទៅទៀត ក្រមនេះមិនបានចែងអំពីបញ្ហាសិទ្ធិមនុស្សសំខាន់ៗ ឡើយ។ ដោយខុសប្លែកពីសន្ធិសញ្ញាគំរូរបស់ **អ.ស.ប** ក្រមនេះមិនបានចែងថា ការដាក់ទណ្ឌកម្មគឺជាមូលហេតុ ចាំបាច់ ឬមានលក្ខណៈខុសប្លែក ដើម្បីបដិសេធការស្នើសុំការធ្វើបត្យាប័នឡើយ។ ស្រដៀងគ្នានេះដែរ ក្រមនេះ មិនបានចែងឲ្យបានច្បាស់ថា ការធ្វើបត្យាប័នត្រូវបានបដិសេធ នៅពេលដែលបុគ្គលដែលគេធ្វើបត្យាប័ន ត្រូវ កាត់ទោសប្រហារជីវិតនៅក្នុងប្រទេសដែលស្នើសុំការធ្វើបត្យាប័នឡើយ។ ដោយហេតុថាក្រមនេះចូលជាធរមាន

[16] អនុសញ្ញាស្តីពីការ ប្រឆាំងនិងទាអំពើរុណកម្ម មាត្រា៣

ចំពោះការស្នើសុំការធ្វើបត្យាប័ន នៅពេលមិនមានសន្ធិសញ្ញាដែលពាក់ព័ន្ធ និងទោះបីជាប្រទេសកម្ពុជាមានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងធ្វើបត្យាប័នតិចតួចក៏ដោយ ភាពខ្វះចន្លោះនេះគឺជាបញ្ហាដែលគួរឲ្យបារម្ភ។[17]

ករណីទើបនិងកើតឡើងថ្មីៗរបស់អ្នកជំនួញជនជាតិរុស្ស៊ី អាឡិចហ្សេនដឺ ត្រូហ្វីមូវ ប្រធានក្រុមវិនិយោគដែលដំណើរការនៅប្រទេសកម្ពុជា គឺជាឧទាហរណ៍នៃភាពខ្វះចន្លោះ ក្នុងក្របខណ្ឌច្បាប់នៃការធ្វើបត្យាប័ន នៅប្រទេសកម្ពុជា។ ត្រូហ្វីមូវ ត្រូវបានលើកលែងទោសនៅខែធ្នូឆ្នាំ២០១១ ទោះបីជាមានការកាត់ឲ្យជាប់ទោសរយៈពេលបួនឆ្នាំ ជាជាងប្រាំបីឆ្នាំ ដោយការបំពានលើកុមារមិនទាន់ពេញវ័យ និងទោះបីជាមានការស្នើសុំពីប្រទេសរុស្ស៊ី ឲ្យធ្វើបត្យាប័នគាត់ ពីបទឧក្រិដ្ឋប្រហាក់ប្រហែលគ្នាដែលគាត់បានប្រព្រឹត្តនៅទីនោះ។ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនម្តងទៀតនៅប្រទេសកម្ពុជានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ជាថ្មីម្តងទៀត រដ្ឋាភិបាលកម្ពុជាជ្រើសរើសមិនពិចារណាចំពោះសំណើធ្វើបត្យាប័ន ហើយបន្ទាប់មក បែរជាបញ្ជូនគាត់ទៅប្រទេសកូរ៉េខាងត្បូងយ៉ាងឆាប់រហ័ស។ ការបដិសេធជាញឹកញាប់ របស់រាជរដ្ឋាភិបាលកម្ពុជា (រ.ជ.ក) ក្នុងការធ្វើបត្យាប័ន ត្រូហ្វីមូវ បង្ហាញអំពីបំណងរបស់ រ.ជ.ក ដើម្បីចៀសផុតពីច្បាប់ស្តីពីការធ្វើបត្យាប័ន។

## ៣. ក្របខណ្ឌច្បាប់ក្នុងការធ្វើបត្យាប័ន

ក្របខណ្ឌក្នុងការធ្វើបត្យាប័ន អាចធ្វើទៅបានក្នុងក្របខណ្ឌចំនួន ៣ (បី) គឺៈ

- ក្របខណ្ឌនៃបត្យាប័នពិសេសៈ ត្រូវបានអនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័ន ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ប្រសិនបើមានសន្ធិសញ្ញា គឺសន្ធិសញ្ញានេះបានចែងអំពីនីតិវិធីលម្អិតអំពីការធ្វើបត្យាប័នហើយបត្យាប័ននេះត្រូវអនុវត្តតាមសន្ធិសញ្ញានោះ។ ជាឧទាហរណ៍ៈ សព្វថ្ងៃកម្ពុជាបានផ្តល់សច្ចាប័នយល់ព្រមទៅលើសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយថៃ វៀតណាម ឡាវ ចិន កូរ៉េខាងត្បូង សហព័ន្ធរុស្ស៊ី ប្រសិនបើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌនៃសន្ធិសញ្ញានេះ។
- ក្របខណ្ឌនៃបត្យាប័នតាមក្របខណ្ឌនីតិវិធីព្រហ្មទណ្ឌៈ ជាទូទៅនៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋស្នើសុំឲ្យធ្វើបត្យាប័នទេ ជាគោលការណ៍ត្រូវអនុវត្តតាមនីតិវិធីរួមស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូចនេះប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយកម្ពុជា បើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងនីតិវិធីព្រហ្មទណ្ឌ។
- ក្របខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិពិសេសៈ ក្នុងករណីដែលមានច្បាប់ពិសេសស្តីពីបត្យាប័នគឺត្រូវអនុវត្តតាមនីតិវិធីនៃបត្យាប័នទៅតាមច្បាប់ពិសេសនោះ។[18]

---

[17]កម្រងឯកសារស្តីពីការធ្វើចំណាក់ថ្នាក់របស់ ម. ស. ម. ស វគ្គ៧"ច្បាប់ស្តីពីការធ្វើបត្យាប័ន" ឆ្នាំ២០១២

[18]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៥៦៧

## ៤. តម្លៃរវាងបត្យាប័ន និង ដីកាចាប់ខ្លួន

- ប្រសិនបើផ្តល់អត្ថន័យចំពោះ "ដីកាចាប់ខ្លួន" នោះគឺជាវិធានការបង្ខំមួយ ដែលចេញដោយអាជ្ញាធរតុលាការ ដើម្បីបង្គាប់ឲ្យមន្ត្រីមានសមត្ថកិច្ចស្វែងរក និងចាប់ខ្លួនជនត្រូវចោទមកឲ្យអនុវត្តតាមច្បាប់។
- ចំណែកពាក្យថា បត្យាប័ន គឺជានីតិវិធីនៃការស្នើសុំ និងការប្រគល់ជនដែលប្រព្រឹត្តបទល្មើសពីរដ្ឋ ដែលជននោះកំពុងស្នាក់នៅទៅរដ្ឋដែលធ្វើសំណើ។

សរុបសេចក្តីមកតម្លៃនៃបត្យាប័ន មិនមានតម្លៃដូចដីកាចាប់ខ្លួនទេ។ ដូចបានបញ្ជាក់នូវចំណុចខាងលើរួចមកយើងអាចកត់សម្គាល់ឃើញថា ដីកាចាប់ខ្លួនគឺជាវិធានការបង្ខំ មួយដែលចេញដោយអាជ្ញាធរតុលាការដើម្បីបង្គាប់ឲ្យមន្ត្រីមានសមត្ថកិច្ចស្វែងរក និងចាប់ខ្លួនជនត្រូវចោទ។ ចំណែកឯ បត្យាប័នវិញគឺជានីតិវិធីនៃការស្នើសុំ និងការប្រគល់ជនប្រព្រឹត្តបទល្មើសពីរដ្ឋដែលជននោះកំពុងស្នាក់នៅទៅរដ្ឋដែលធ្វើសំណើ។

## ៥. ការហាមឃាត់ក្នុងការធ្វើបត្យាប័ន

ទន្ទឹមនិងការធ្វើបត្យាប័នបានតាមការចែងពីក្រមនីតិវិធីព្រហ្មទណ្ឌក៏មានករណីមួយចំនួនដែលមិនអាចអោយដំណើរការធ្វើបត្យាប័នផងដែរ។ ដែលករណីក្នុងការហាមឃាត់មិនឲ្យធ្វើបត្យាប័នបាននោះមានដូចជា៖

- ករណីដែលជនជាកម្មវត្ថុនៃការធ្វើបត្យាប័ន ត្រូវបានតុលាការ នៃប្រទេសស្នើសុំផ្តន្ទាទោសជាស្ថាពររួចហើយ ឬកំពុងស្ថិតនៅក្នុងនីតិវិធីនៃច្បាប់។
- ករណីដែលបណ្តឹងអាជ្ញាបានរលត់ (តាមច្បាប់កម្ពុជា) ដូចជា៖

➢ **មរណភាពនៃជនល្មើស** បណ្តឹងអាជ្ញានឹងត្រូវរលត់ នៅពេលដែល ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ បានទទួលមរណភាព ។ បើផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ដែលសំដៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ពោលគឺបុគ្គលណាជាអ្នកប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវទោសព្រហ្មទណ្ឌ ដោយមិនអាចឱ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលទោសជំនួសបានឡើយ ។ ដូចនេះដំណាក់កាលនីតិវិធីទាំងអស់នៃសំណុំរឿងព្រហ្មទណ្ឌនឹងត្រូវបញ្ចប់ ប្រសិនបើជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ បានទទួលមរណៈភាព ដោយសារតែបណ្តឹងអាជ្ញាត្រូវបានរលត់។

➢ **ការផុតអាជ្ញាយុកាល** អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលដែលកំណត់ដោយច្បាប់ ដែលក្នុងករណីដែលផុតរយៈពេលកំណត់នេះ នោះព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ។ រយៈពេលនៃអាជ្ញាយុកាលត្រូវប្រែប្រួលទៅតាមប្រភេទនៃបទល្មើសនីមួយៗពោលគឺ ១(មួយ) ឆ្នាំ ចំពោះបទលហុ ៥ (ប្រាំ)

ឆ្នាំ ចំពោះបទមជ្ឈិម និង ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ ហើយត្រូវរាប់គិតចាប់ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

➢ **ការលើកលែងទោសទូទៅ** ការលើកលែងទោសទូទៅត្រង់មាត្រា ៧ នេះមិនសំដៅទៅលើការលើកលែងទោសដោយជារាជានុសិទ្ធិរបស់ព្រះមហាក្សត្រ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗនោះទេ ។ ការលើកលែងទោសទូទៅដែលធ្វើឱ្យបណ្តឹងអាជ្ញាមួយរលត់ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភា សម្រាប់លើកលែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីត្រូវរលត់ ។

➢ **និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ** ដូចបានបញ្ជាក់ជូនខាងលើ ស្ថាប័នអយ្យការអាចធ្វើការចោទប្រកាន់ទៅលើអំពើដែលត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌបាន តាមរយៈបណ្តឹងអាជ្ញា ប៉ុន្តែទោះបីជាមានការចោទប្រកាន់ក៏ដោយ ក៏បណ្តឹងអាជ្ញាអាចនឹងត្រូវបានរលត់ផងដែរ ប្រសិនបើបទល្មើសនោះត្រូវបាននិរាករណ៍ ពោលគឺ អំពើដែលបានប្រព្រឹត្តដោយជនល្មើសនោះ លែងត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌតទៅទៀត។

➢ **អាជ្ញាអស់ជំនុំ** ប្រសិនបើជនជាប់ចោទត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរតាមរយៈសាលក្រម ឬសាលដីកាណាមួយហើយ ជនជាប់ចោទនោះមិនអាចត្រូវបានចោទប្រកាន់ចំពោះអំពើដដែលទៀតនោះទេ ទោះបីជាមានការចោទប្រកាន់នោះក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។[19]

- បើយល់ឃើញថាការបញ្ជូនជននោះទៅត្រូវបានតុលាការនៃប្រទេសស្នើសុំផ្តន្ទាទោសប្រហារជីវិត
- បើយល់ឃើញថាការបញ្ជូនជននោះទៅត្រូវបានជំនុំជម្រះដោយតុលាការពិសេសនៃប្រទេសដាក់សំណើ

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៧

# ជំពូកទី ២

# លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមកិច្ចព្រមព្រៀងរវាងរដ្ឋនិងរដ្ឋ

# ជំពូកទី២

# លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ

បត្យាប័ន គឺជាការបញ្ជូនជនល្មើសពីប្រទេសមួយទៅប្រទេសមួយទៀត ហើយបត្យាប័ននេះកើតមានឡើងបានលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ។ ទន្ទឹមនឹងនេះ ការព្រមព្រៀងនេះគឺពឹងផ្អែកទៅលើឆន្ទៈរដ្ឋទទួលសំណើ ក្នុងការផ្ទេរជនល្មើសឲ្យទៅរដ្ឋដាក់សំណើ។ ការធ្វើបត្យាប័នកើតមានឡើងនៅពេលដែលមួយរដ្ឋមួយដែលជាអ្នកស្នើសុំ ហៅថា **រដ្ឋដាក់សំណើ** ឬ **រដ្ឋធ្វើសំណើ** បានធ្វើការស្នើសុំទៅរដ្ឋមួយទៀត ដើម្បីបានធ្វើបត្យាប័នដែលរដ្ឋនោះហៅថា **រដ្ឋទទួលសំណើ**។ ជាក់ស្តែងនៅពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើង បានធ្វើបត្យាប័នជាមួយនឹងបណ្តាប្រទេសមួយចំនួនដូចជា៖ ប្រទេសបារាំង ប្រទេសឡាវ ប្រទេសកូរ៉េខាងត្បូង ប្រទេសចិន ប្រទេសវៀតណាម និងប្រទេសថៃ...។ ចំពោះការផ្ទេរជនល្មើសពីរដ្ឋមួយ ទៅរដ្ឋមួយ ត្រូវពឹងផ្អែកទៅលើសន្ធិសញ្ញា ក៏ប៉ុន្តែសន្ធិសញ្ញាពុំមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ការធ្វើបត្យាប័ននោះទេ។ វាគ្រាន់តែជាផ្នែកមួយដែលជួយសម្រួលដល់ការធ្វើបត្យាប័នប៉ុណ្ណោះ។

សម័យប្រជុំលើកទី ៦ នីតិកាលទី ៤ របស់ព្រឹទ្ធសភាដឹកនាំដោយកិត្តិនីតិកោសល បណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភាកាលពីព្រឹកថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២០ បានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ចំនួន ៥ [20]។

ដែលច្បាប់ទាំង **៥** នោះគឺ ៖

១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋកូរ៉េ ។

២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រម លើអនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ។

៣- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ។

៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត

៥- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្ម ពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

[20]ដកស្រង់ចេញពីគេហទំព័រ កម្ពុជាថ្មី រៀបរៀងដោយ៖ លោក សេម វាសនា

សូមជម្រាបថាៈ សេចក្តីព្រាងច្បាប់ទាំង ៥ នេះត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាល ទី៦ ។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យ ព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជានិង សាធារណរដ្ឋកូរ៉េតាក់តែងឡើងមានគោលបំណងបង្កើនប្រសិទ្ធភាព នៃប្រទេសទាំងពីរក្នុងការបង្ការការស៊ើបអង្កេតការចោទប្រកាន់និងការសេចក្តីព្រាងច្បាប់នេះមានសារៈសំខាន់ និងអត្ថប្រយោជន៍ដើម្បីជាការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋកូរ៉េក្នុងការ លុបបំបាត់ឧក្រិដ្ឋកម្មដោយឈរលើគោលការណ៍គោរពនូវ អធិបតេយ្យភាពសមភាព និង ផលប្រយោជន៍ទៅវិញទៅមកនិងជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែក យ៉ាងសកម្មក្នុងក្របខណ្ឌច្បាប់អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ បទឧក្រិដ្ឋកម្មឆ្លងដែនរួមមានការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ អំពើពុករលួយ ការប្រយុទ្ធប្រឆាំងនិងភេរវកម្ម និងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។ សន្ធិសញ្ញានេះនិងក្លាយជាមូលដ្ឋានគតិយុត្តសម្រាប់ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋកូរ៉េ ក្នុងការធ្វើសំណើនិងអនុវត្តសំណើសុំជំនួយទៅ[21]។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមទៅលើ អនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង គឺមានគោលបំណង ដើម្បីជាការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ នៅក្នុងការប្រឆាំងឧក្រិដ្ឋកម្ម ដោយគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាព និងរួមជាផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខណ្ឌច្បាប់អន្តរជាតិដើម្បី ប្រយុទ្ធប្រឆាំងទប់ស្កាត់ឧក្រិដ្ឋកម្ម ឆ្លងដែនរួមមានការជួញដូរ មនុស្សជាពិសេសស្ត្រី និង កុមារការប្រយុទ្ធប្រឆាំងនឹង ភេរវកម្ម ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង ការប្រឆាំងអំពើពុករលួយ ។ សេចក្តីព្រាងច្បាប់នេះបានផ្តល់សារៈសំខាន់ និង អត្ថប្រយោជន៍ដល់គូភាគីនៅក្នុងការ បង្កើតឱ្យមាននូវក្របខណ្ឌច្បាប់ ដើម្បីស្វែងរកជនល្មើសដែលទាមទារឱ្យមាន កិច្ចសហប្រតិបត្តិការ ក្នុងក្របខណ្ឌអន្តរជាតិក្នុងវិស័យព្រហ្មទណ្ឌ។

សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និង សហព័ន្ធរុស្ស៊ីមានគោលបំណងពង្រឹងមូលដ្ឋានច្បាប់នៃការផ្តល់ការជួយគ្នាទៅវិញទៅមក នៅក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីជាការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ដោយឈរនៅលើគោលការណ៍គោរពនូវអធិបតេយ្យភាពសមភាព

[21]ដកស្រង់ចេញពីគេហទំព័រ កម្ពុជាថ្មី រៀបរៀងតោយលោកៈ សេម វាសនា

សុចរិតភាព ដែនដីមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនិង ផលប្រយោជន៍គ្នាទៅវិញទៅមកព្រមទាំងជាផ្នែកមួយ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការរួមចំណែកយ៉ាងសកម្ម ក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ បទឧក្រិដ្ឋកម្មឆ្លងដែនរួមមានការជួញដូរមនុស្សជាពិសេសស្ត្រី និង កុមារអំពើពុករលួយការប្រយុទ្ធប្រឆាំងនឹង អំពើភេរវកម្ម និង ការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្មជាអាទិ៍ដោយអនុលោមតាមច្បាប់ជាតិរបស់គូភាគី និង គោរពគោលការណ៍នៃច្បាប់អន្តរជាតិ។ សេចក្តីព្រាងច្បាប់នេះផ្តល់សារៈសំខាន់ជាខ្លាំង និងអត្ថប្រយោជន៍ដល់គូភាគីក្នុងការបង្កើត អោយមានក្របខណ្ឌគតិយុត្ត សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ីក្នុងការផ្ញើសំណើ និងអនុវត្តសំណើសុំជំនួយទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដើម្បីជួយដល់ការស៊ើបអង្កេត និងនីតិវិធីតុលាការរបស់ភាគីនីមួយៗអោយមាន វិសាលភាពជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។ បង្ក្រាបបទល្មើសតាមរយៈសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកនៅក្នុងវិស័យព្រហ្មទណ្ឌ។

ឧទាហរណ៍ជាក់ស្តែងទី១៖ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ទីស្តីការក្រសួងយុត្តិធម៌ ស្តីអំពីសំណើសុំចាប់ខ្លួន និងធ្វើបត្យាប័នជនជាតិ រុស្ស៊ី ម្នាក់ភេទប្រុស អាយុ៣៦ (កើតនៅក្នុងទីក្រុង Zeya) ទៅអោយតុលាការរុស្ស៊ី ដោយហេតុថា បុគ្គលនេះបានប្រព្រឹត្តិបទល្មើសនៅក្នុងប្រទេស រុស្ស៊ី ហើយបានគេចខ្លួនមកប្រទេសកម្ពុជា ស្នាក់នៅខេត្តព្រះសីហនុ។ បានឃើញដីកាចាប់ខ្លួនចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ចេញដោយប្រធានចៅក្រមឈ្មោះ Petrou M.G the secretary of the court katashuikava E.S ឈ្មោះ Balatin Vladimir Vitalievitch ពីបទ៖ បោកលុយក្រុមហ៊ុន[22]។

ឧទាហរណ៍ជាក់ស្តែងទី២៖ នៅក្នុងសំណុំរឿងស្ត្រីខ្មែរដែលត្រូវតុលាការវៀតណាមកាត់ទោសប្រហារជីវិតលើរូបនាងពីបទជួញដូរគ្រឿងញៀនឆ្លងដែន មិនទាន់បញ្ចប់ត្រឹមនេះនៅឡើយទេ ពោលគឺនៅសល់ដំណាក់កាលជម្រះក្តីនៅថ្នាក់ឧទ្ធរណ៍បន្តទៀត។ ដំណាក់កាលឧទ្ធរណ៍ គឺមានជំនួយផ្នែកច្បាប់ពីក្រសួងយុត្តិធម៌កម្ពុជាដើម្បីប្តឹងជំទាស់សេចក្តីសម្រេចរបស់តុលាការថ្នាក់ដំបូងរបស់វៀតណាម ដែលកាត់ទោសប្រហារជីវិតពីបទជួញដូរគ្រឿងញៀន។

សំណុំរឿងស្ត្រីខ្មែរនេះ អាចប្រើយន្តការផ្នែកច្បាប់ដែលមានស្រាប់រវាងប្រទេសកម្ពុជា និងវៀតណាមគឺកិច្ចព្រមព្រៀងធ្វើបត្យាប័ន និងផ្ទេរទណ្ឌិត។ ចំពោះការធ្វើបត្យាប័ន នោះកម្ពុជានឹងស្នើសុំយកមកផ្តន្ទាទោស និងដំណើរការក្តីនៅកម្ពុជា។ ចំណែកការផ្ទេរទណ្ឌិតវិញ សំដៅដល់ការប្រព្រឹត្តបទល្មើសនៅវៀតណាម ហើយទទួលបានការកាត់ទោសរួចរាល់ កម្ពុជាអាចស្នើសុំផ្ទេរទណ្ឌិត មកអនុវត្តទោសនៅកម្ពុជា។ ដូច្នេះសំណុំរឿងស្ត្រីខ្មែរ

[22]ដីកាបញ្ជាអោយចាប់-ឃុំខ្លួន របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

ដែលត្រូវតុលាការវៀតណាម កាត់ទោសប្រហារជីវិតលើរូបនាងពីបទជួញដូរគ្រឿងញៀនឆ្លងដែន អាចស្ថិតនៅក្នុងកិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិត[23]។

សេចក្តីព្រាងច្បាប់ទាំងនេះនឹងផ្តល់ជាជំនួយបច្ចេកទេសជំនួយហិរញ្ញវត្ថុពី ប្រទេសអភិវឌ្ឍ និង អង្គការអន្តរជាតិ ពាក់ព័ន្ធសម្រាប់ការអនុវត្តវិធានចាំបាច់ដែលបញ្ញត្តិនៅក្នុងអនុសញ្ញានេះនិង បានរួមចំណែកបំពេញបន្ថែម ទៅដល់ ការអនុវត្តអនុសញ្ញាពហុភាគី ក្នុងវិស័យគាំពារបរិស្ថានដែលព្រះរាជាណាចក្រកម្ពុជាបានចូលជាភាគីព្រមទាំងបានរួម ចំណែកក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាល ទី៤ របស់រាជរដ្ឋាភិបាលគោលនយោបាយកាត់បន្ថយ ទៅលើភាពក្រីក្រលើកកម្ពស់កិច្ចគាំពារបរិស្ថាន សំដៅឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព[24]។

ដោយផ្អែកតាមបទបញ្ញត្តិទាក់ទងទៅនឹងការធ្វើបត្យាប័នទាំងនេះ យើងអាចកំណត់លក្ខខណ្ឌនៃការធ្វើបត្យាប័នមានពីរដូចជា៖ បត្យាប័នផ្អែកតាមសន្ធិសញ្ញា និងបត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា។

## ផ្នែកទី១. បត្យាប័នផ្អែកតាមសន្ធិសញ្ញា

ការបង្កើតសន្ធិសញ្ញា គឺជាការភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមករវាងប្រទេសនានានៅក្នុងសកលលោកក្នុងគោលបំណងរឹតចំណងកិច្ចសហប្រតិបត្តិការ និងទទួលបានអត្ថប្រយោជន៍ផ្សេងៗ។

សន្ធិសញ្ញាទាក់ទងនិងការធ្វើបត្យាប័ន ផ្តល់នូវភាពងាយស្រួលជាច្រើនដល់រដ្ឋជាភាគីដូចជាដឹងជាមុននូវនីតិវិធីក្នុងការធ្វើបត្យាប័ន ព្រមទាំងដែនអនុវត្តខ្លះដែលរដ្ឋភាគីបានធ្វើការព្រមព្រៀង។

ការបែងចែកសន្ធិសញ្ញាជាពីរផ្សេងគ្នា សន្ធិសញ្ញាទ្វេភាគី ជាសន្ធិសញ្ញាដែលកើតចេញពីការព្រមព្រៀងគ្នាតាមរយៈការចរចាគ្នារវាងរដ្ឋនិងរដ្ឋ ចំណែកឯសន្ធិសញ្ញាពហុភាគី ជាសន្ធិសញ្ញាដែលកើតចេញពីការព្រមព្រៀងរវាងរដ្ឋច្រើន។

### ១.១. សន្ធិសញ្ញាទ្វេភាគី

សន្ធិសញ្ញាទ្វេភាគី គឺជាសន្ធិសញ្ញាដែលកើតចេញឡើងតាមរយៈ ការចរចាគ្នា ឬព្រមព្រៀងរវាងរដ្ឋចំនួនពីរ។ ចំណែកឯសន្ធិសញ្ញាបត្យាប័ន គឺដូចគ្នាទៅនិងសន្ធិសញ្ញាផ្សេងទៀតដែល ដោយត្រូវធ្វើឡើងតាមរយៈការ

[23] ប្រសាសន៍អ្នកនាំពាក្យពីក្រសួងមហាផ្ទៃ លោក ជិន ម៉ាលីន កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

[24] ដកស្រង់ចេញពីគេហទំព័រ កម្ពុជាថ្មី រៀបរៀងដោយ៖ លោក សេម វាសនា

ចរចាគ្នាដើម្បីកំណត់បាននូវនីតិវិធីមួយសមស្រប និងកំណត់នូវបទល្មើសទាំងឡាយណា ដែលអនុញ្ញាតឲ្យធ្វើបត្យាប័នបាន ឬមិនបាន។

សន្ធិសញ្ញាទ្វេភាគី គឺជាច្បាប់ពិសេស ដែលមានលក្ខណៈច្បាស់លាស់ ហើយមានអានុភាពអនុវត្តលើច្បាប់ទូទៅ (សន្ធិសញ្ញាពហុភាគី) លើកលែងតែគូភាគីជាហត្ថលេខីនៃសន្ធិសញ្ញាព្រមព្រៀងគ្នាផ្សេងពីនេះ។ ជាទូទៅខ្លឹមសារនៃសន្ធិសញ្ញាបត្យាប័នត្រូវតែចែងអំពីកាតព្វកិច្ច នៃការធ្វើបត្យាប័នបទល្មើស ដែលអាចធ្វើបត្យាប័នបានដោយមូលហេតុដែលនាំឲ្យមានការបដិសេធ នៅក្នុងការធ្វើបត្យាប័ននីតិវិធីនៃការធ្វើបត្យាប័ន ការចាប់ខ្លួន ការប្រគល់ខ្លួនជនដែលស្នើសុំសោហ៊ុយចំណាយក្នុងការធ្វើបត្យាប័នមានដូចជា៖

### ក. អនុសញ្ញាទ្វេភាគីជាមួយប្រទេសបារាំង

អនុសញ្ញាស្តីពីបត្យាប័នរវាងរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៥។

អនុសញ្ញានេះមានគោលបំណង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរនៅក្នុងការប្រឆាំងឧក្រិដ្ឋកម្មដោយការគោរពគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន រួមមានការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ ការប្រយុទ្ធប្រឆាំងនិងភេរវកម្ម ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ។

អនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋបារាំងមាន ២៥មាត្រា។[25]

### ខ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសចិន

អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ជាពីរច្បាប់ ភាសាខ្មែរ និង ភាសាអង់គ្លេស។

គោលបំណងជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ នៅក្នុងការកំចាត់ឧក្រិដ្ឋកម្ម ដោយឈរនៅលើមូលដ្ឋានគោរពនូវអធិបតយ្យភាពគ្នាទៅវិញទៅមកសមភាព និងផលប្រយោជន៍

[25]អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង

ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន។ អនុសញ្ញាស្តីពីការធ្វើបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនមានប្រការចំនួន២២ ។[26]

### គ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសឡាវ

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ១៩៩០ ធ្វើឡើងជាបីច្បាប់ ជាភាសាខ្មែរ ភាសាឡាវ និងភាសាអង់គ្លេស។

គោលបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព ផលប្រយោជន៍ទាំងសងខាង និងផលប្រយោជន៍ទាំងសងខាងតាមការចុះសន្ធិសញ្ញាបត្យាប័ន ដែលបានព្រមព្រៀងគ្នា។

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ មានចំនួន២៤ ប្រការ[27]។

### ឃ. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសថៃ

សន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលបានអនុម័តកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩។

សន្ធិសញ្ញានេះមានទាំងអស់ចំនួន ២៤ប្រការ[28]។

### ង. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសវៀតណាម

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម អនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤។ នៅក្នុងសន្ធិសញ្ញានេះមានទាំងអស់ចំនួន ២២មាត្រា[29]។

### ច. សន្ធិសញ្ញាទ្វេភាគីជាមួយសហព័ន្ធរុស្ស៊ី

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និង គតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤។ នៅក្នុងសេចក្តីសម្រេចទាំងស្រុងនេះមានមាត្រាចំនួន៣[30]។

[26]សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

[27]សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ

[28]សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ

[29]សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម

[30]សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

### ឆ. កិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកូរ៉េ

កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េដែលត្រូវបានអនុម័ត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។ នៅក្នុងកិច្ចព្រមព្រៀងនេះ មានទាំងអស់សរុបចំនួន ២៣ប្រការ[31]។

### ជ. កិច្ចព្រមព្រៀងស្តីពីផ្ទេរទណ្ឌិតជាមួយប្រទេសឥណ្ឌា

កិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ដែលបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំលើកទី២ នីតិកាលទី៤។ នៅក្នុងកិច្ចព្រមព្រៀងនោះមានទាំងអស់ចំនួន១៩ មាត្រា។[32]

នៅក្នុងនោះប្រទេសកម្ពុជាយើង ក៏បានចុះហត្ថលេខា ជាមួយបណ្តាប្រទេសមួយចំនួនទៀតដែលស្តីពីកិច្ចព្រមព្រៀងការផ្ទេរទណ្ឌិតមានដូចជា៖ ប្រទេសសហរដ្ឋអាមេរិក ប្រទេសអូស្ត្រាលី ដើម្បីជាការជួយសម្រួលទៅដល់ការផ្ទេរទណ្ឌិត និងជួយសម្រួលផ្នែកច្បាប់ព្រហ្មទណ្ឌ។

សរុបសេចក្តីជារួមមក សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងដែលបានរៀបរាប់ខាងលើនេះ មានគោលបំណងជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្មឈរលើមូលដ្ឋានគោរពនូវ អធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងកិច្ចព្រមព្រៀងទាំងនេះសុទ្ធតែបានចែងអំពី កាតព្វកិច្ច បទល្មើសដែលអាចធ្វើបត្យាប័នបានមូលហេតុដែលនាំឲ្យបដិសេធក្នុងការធ្វើបត្យាប័ន ការចាប់ខ្លួន ការប្រគល់ខ្លួនជនដែលស្នើសុំ សោហ៊ុយចំណាយក្នុងការធ្វើបត្យាប័នជាដើម។

## ១.២. សន្ធិសញ្ញាពហុភាគី

សន្ធិសញ្ញាពហុភាគី គឺជាសន្ធិសញ្ញាដែលកើតឡើងតាមរយៈការព្រមព្រៀងរវាងរដ្ឋជាច្រើន។ នាពេលបច្ចុប្បន្ននេះ មានប្រទេសជាច្រើនបានព្យាយាមធ្វើការសហការគ្នាទាំងក្នុង និងក្រៅប្រទេសតាមតំបន់ ដើម្បីជួយសម្រួលនីតិវិធីក្នុងការអនុវត្តកិច្ចការនីមួយៗ ក្នុងគោលដៅបង្កើនទំនាក់ទំនងល្អជាមួយគ្នាតាមរយៈការបង្កើតឲ្យមានសន្ធិសញ្ញា។

ការចូលរួមសហការគ្នា ពីរដ្ឋជាច្រើនក្នុងការបង្កើតសន្ធិសញ្ញានេះគេឲ្យឈ្មោះថា **សន្ធិសញ្ញាពហុភាគី។** សន្ធិសញ្ញានេះបង្កើតឡើងក្នុងគោលបំណងដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងសង្គម ដើម្បីជូនដល់ប្រជាពលរដ្ឋជាសមាជិកទាំងអស់។

[31]កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋកូរ៉េ

[32]កិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិតរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋឥណ្ឌា

ព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានបានចុះសន្ធិសញ្ញាពហុភាគី ទាក់ទងទៅនឹងបត្យាប័នណាមួយទេ។ ប៉ុន្តែយើងឃើញថាសន្ធិសញ្ញាពហុភាគីទាក់ទងនឹងបត្យាប័ន មានដូចជា៖

- អនុសញ្ញាស្តីពីការលុបបំបាត់ចោល និងការប្រឆាំងអំពើភេរវកម្មឆ្នាំ ១៩៨០
- អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទោសរាល់បទឧក្រិដ្ឋប្រឆាំងនឹងអន្តរជាតិឆ្នាំ១៩៧៣[33]

ចំណុចសំខាន់ៗដែលសន្ធិសញ្ញាទ្វេភាគី ធ្វើឡើងតាមរយៈការចរចាគ្នាដើម្បីកំណត់នូវ៖

- កាតព្វកិច្ចនៃការធ្វើបត្យាប័ន
- កំណត់បទល្មើសទាំងឡាយណាដែលអនុញ្ញាតឲ្យធ្វើបត្យាប័នបាន ឬមិនបាន
- មូលហេតុដែលនាំឲ្យមានការបដិសេធក្នុងការធ្វើបត្យាប័ន
- នីតិវិធីនៃការធ្វើបត្យាប័ន
- ការចាប់ខ្លួន និងការប្រគល់ខ្លួនជនដែលស្នើសុំ
- សោហ៊ុយចំណាយក្នុងការធ្វើបត្យាប័ន។[34]

## ផ្នែកទី២. បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា

នៅក្នុងការធ្វើបត្យាប័ន គេត្រូវពិចារណាទៅលើ លក្ខខណ្ឌទាក់ទងទៅនិងបទល្មើស ដែលបទល្មើសណាខ្លះដែលអាចធ្វើទៅបាន និងខ្លះទៀតដែលមិនអាចធ្វើបត្យាប័នបាន។ ពុំមានច្បាប់ ឬគោលការណ៍ណាមួយហាមឃាត់មិនឲ្យធ្វើបត្យាប័នដោយគ្មានសន្ធិសញ្ញាទេ។ ការធ្វើបត្យាប័នគោលបំណងគឺផ្ទេរជនល្មើស ឬបណ្ដិតទៅកាន់ប្រទេសដាក់សំណើ។ ចំណុចសរុបសំខាន់ជារួមមក៖

- គោលការណ៍បដិកា (ការព្រមព្រៀងក្នុងការជួយគ្នាដោយពុំមានបញ្ញត្តិច្បាស់លាស់)
- ឆន្ទៈជួយគ្នាទៅវិញទៅមក និងមនោសញ្ចេតនាប្រទេសដៃគូ (ពុំមែនជាកាតព្វកិច្ចទេ)
- ដើម្បីបង្រ្កាបបទល្មើសដែលកើតមានលើទឹកដីរបស់ខ្លួន
- ធានាគុណភាពនៃការធ្វើបត្យាប័នប្រកបដោយភាតរភាព និងនិរន្តរភាព
- ឆន្ទៈធ្វើបត្យាប័នតាមច្បាប់ជាតិ (កម្ពុជា៖ ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ១០.កក្កដា.២០០៧)

លក្ខខណ្ឌមួយចំនួននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (**មាត្រា ៥៦៩,៥៧០,៥៧១,៥៧២,៥៧៣**)

[33]អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទោសឧក្រិដ្ឋកម្មប្រឆាំងនឹងអន្តរជាតិឆ្នាំ១៩៧៣

[34]អនុសញ្ញាស្តីពីការលប់បំបាត់ចោល នឹងការប្រឆាំងអំពើភេរវកម្មឆ្នាំ១៩៨០

យោងតាមបទបញ្ញត្តិមាត្រា**៥៦៩** ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "**លក្ខខណ្ឌនៃបត្យាប័នទាក់ទងនឹងអំពើ**" បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវបានចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា

- អំពើដែលជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ
- ឈ្មោះបទល្មើសការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លលក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ
- ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋដែលធ្វើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលបានកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើគឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាន[35]។

យោងតាមបញ្ញត្តិមាត្រា**៥៧០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "**ករណីនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការសមគំនិត**" បានចែងថា ប្រសិនបើអំពើដែលត្រូវចោទប្រកាន់តាមច្បាប់នៃរដ្ឋធ្វើសំណើជាការប៉ុនប៉ងប្រព្រឹត្តិបទល្មើសបត្យាប័ន អាចធ្វើទៅបានលុះត្រាតែ ការប៉ុនប៉ងនោះត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាដែរ[36]។

យោងតាមបញ្ញត្តិមាត្រា**៥៧១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "**លក្ខខណ្ឌទាក់ទងនិងទោសពន្ធនាគារ**" បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេឬទាមទារនោះ មានកម្រិតអតិបរមានៃទោសពន្ធនាគារ យ៉ាងតិចស្មើនិង២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋធ្វើសំណើ។ ប៉ុន្តែបត្យាប័នក៏អាចបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋធ្វើសំណើ ផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនិង ៦ខែ ហើយសេចក្តីសម្រេចនេះ បានចូលជាស្ថាពររួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថេរវេលាប៉ុន្មានក៏ដោយ[37]។

យោងតាមបញ្ញត្តិមាត្រា**៥៧២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "**លក្ខខណ្ឌទាក់ទងនឹងទីកន្លែងប្រព្រឹត្តិបទល្មើស**" បានចែងថា កាលណាអំពើដែលត្រូវបានចោទប្រកាន់លើបុគ្គល ដែលគេទាមទារត្រូវបានគេប្រព្រឹត្តិនៅលើដែនដីនៃរដ្ឋធ្វើសំណើ បត្យាប័នក៏អាចធ្វើបានដែរ ទោះបីជាបុគ្គលដែលគេទាមទារមិនមានសញ្ជាតិរបស់រដ្ឋធ្វើសំណើក៏ដោយ[38]។

---

[35]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៦៩

[36]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៧០

[37]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៧១

[38]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៧២

កាលណាអំពើដែលត្រូវបានគេចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ត្រូវបានប្រព្រឹត្តិនៅក្រៅដែនដីនៃរដ្ឋផ្ញើសំណើ បត្យាប័នអាចនិងត្រូវធ្វើបាន លុះត្រាតែបុគ្គលដែលគេទាមទារមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើ។

ការឆ្លងកាត់ដែនដីកម្ពុជា ដោយបុគ្គលណាម្នាក់ដែលស្ថិត នៅក្នុងក្របខណ្ឌនៃនីតិវិធីបត្យាប័នអាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាក់ទង នឹងបទល្មើសនយោបាយទេ។

យោងតាមមាត្រា**៥៧៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាត់ចែងមិនត្រូវបានចាត់ទុកថា ជាបទល្មើសនយោបាយទេចំពោះអំពើហិង្សា ដែលធ្វើអោយមានការគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាពដល់រូបកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល[39]។

ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើ ដែលត្រូវបានបង្ហាញដោយរដ្ឋផ្ញើសំណើ គឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមានរបស់កម្ពុជា។

បទល្មើសមួយចំនួន ដែលមិនអាចធ្វើបត្យាប័ន ដូចជា **បទល្មើសនយោបាយ** ទោះបីជាប្រទេសកម្ពុជា និងបណ្តាប្រទេសដែលបានលុះត្រាតែប្រទេសចុះសន្ធិសញ្ញាបត្យាប័នជាមួយគ្នា បានបញ្ញត្តិពីការមិនធ្វើបត្យាប័នចំពោះបទល្មើសនយោបាយក៏ពិតមែន។ ប៉ុន្តែនៅក្នុងសន្ធិសញ្ញាទាំងអស់នេះ ពុំមានបញ្ញត្តិណាមួយច្បាស់លាស់ចែងអំពីនិយមន័យបទល្មើសនយោបាយនោះទេ។

នៅក្នុងការធ្វើបត្យាប័ន គេត្រូវពិចារណាទៅលើ លក្ខខណ្ឌទក់ទងទៅនិងបទល្មើស ដែលបទល្មើសណាខ្លះដែលអាចធ្វើទៅបាន និងខ្លះទៀតដែលមិនអាចធ្វើបត្យាប័នបាន។

ចំពោះការធ្វើបត្យាប័ននៅកម្ពុជា ត្រូវបានអនុវត្តទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងសន្ធិសញ្ញាបត្យាប័នទ្វេភាគី។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីនៅកម្ពុជាមិនទាន់បានមានលក្ខណៈគ្រប់គ្រាន់នៅឡើយ និងមិនមានភាពជាក់លាក់នៅត្រង់ចំណុចមួយចំនួន និងមានភាពខ្វះចន្លោះ ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាសិទ្ធិមនុស្ស និងដោយភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍ច្បាប់។ ប្រទេសកម្ពុជាមានសន្ធិសញ្ញា បត្យាប័នជា មួយរដ្ឋមួយចំនួនដូចជា ចិន ឡាវ កូរ៉េខាងត្បូង និង វៀតណាម រួចមកហើយ។ កន្លងមកកម្ពុជាបានចុះកិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិត និងជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដូចជាការជួយប្រមូលភស្តុតាងជាដើម។[40]

ចំពោះវិវាទទាក់ទងនិងការអនុវត្តទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ តុលាការទទួលបណ្តឹងពីព្រះរាជអាជ្ញាតាមរយៈពាក្យសុំធម្មតា។ អយ្យការឲ្យដំណឹងអំពីកាលបរិច្ឆេទនៃសវនាកាដល់ភាគីពាក់ព័ន្ធ។

[39]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៧៣

[40]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សរុបសេចក្តីមក បត្យាប័នអាចត្រូវបានធ្វើឡើងបានតាមរយៈការបង្កើតឲ្យមានជាសន្ធិសញ្ញា ឬតាមឆន្ទៈរបស់រដ្ឋនីមួយៗ ដែលមានចែងក្នុងច្បាប់ជាតិ។ ប៉ុន្តែនៅក្នុងករណីបត្យាប័ន ដោយពុំមានសន្ធិសញ្ញាបត្យាប័នទេ រដ្ឋទទួលសំណើពុំមានកាតព្វកិច្ចត្រូវតែប្រគល់ជនល្មើសអោយទៅរដ្ឋដាក់សំណើដើម្បីអនុវត្តទោសនោះទេ ពោលគឺផ្អែកតាមឆន្ទៈព្រមព្រៀងគ្នារបស់ប្រទេសទាំងពីរ។ នេះជាចំណោទបញ្ហាមួយ ដែលតែងកើតមានឡើងក្នុងទំនាក់ទំនងរដ្ឋ និងរដ្ឋ ដោយសាររដ្ឋទទួលសំណើត្រូវធ្វើការសម្រេចចិត្ត ថាតើត្រូវប្រគល់ជនល្មើសតាមការស្នើសុំរបស់រដ្ឋដាក់សំណើដែរឬទេ។

# ជំពូកទី ៣
# នីតិវិធីក្នុងការធ្វើបត្យាប័ន និងការស្នើធ្វើបត្យាប័នដោយរដ្ឋកម្ពុជាចំពោះរដ្ឋបរទេស

# ជំពូកទី ៣
# នីតិវិធីក្នុងការធ្វើបត្យាប័ន និងការស្នើធ្វើបត្យាប័ន ដោយរដ្ឋកម្ពុជាចំពោះរដ្ឋបរទេស

## ផ្នែកទី១. នីតិវិធីនៃការធ្វើបត្យាប័ន

### ១. សមត្ថកិច្ចទទួលបន្ទុកទទួល និង បញ្ជូនពាក្យសុំឲ្យធ្វើបត្យាប័ន

យោងតាមមាត្រា៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) ដើម្បីឲ្យប្រទេសកម្ពុជាធ្វើបត្យាប័នឲ្យរដ្ឋបរទេសណាមួយបាន ទាមទារឲ្យរដ្ឋធ្វើសំណើនោះដាក់ពាក្យសុំធ្វើបត្យាប័ន ជូនមករដ្ឋាភិបាលកម្ពុជាតាមរយៈផ្លូវទូតដែលសំដៅទៅដល់ក្រសួងការបរទេសរបស់ព្រះរាជាណាចក្រកម្ពុជា។ ពាក្យសុំនោះត្រូវតែមានលិខិតបញ្ជាក់ភស្តុតាងដែលតម្រូវឲ្យមានចំណុចដូចខាងក្រោម៖

- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលគេអនុវត្តទៅលើអំពើនោះ និង ទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន (ចំណុចនេះដោយសារតែ ករណីខ្លះតុលាការនៃរដ្ឋធ្វើសំណើបានផ្តន្ទាទោសបុគ្គល ដែលគេទាមទារនៅរដ្ឋធ្វើសំណើរួចហើយ ដូច្នេះតម្រូវឲ្យរដ្ឋដែលគេទាមទារត្រូវតែបំពេញចំណុចដែលកំណត់នេះ តែប្រសិនបើពុំទាន់មានសេចក្តីសម្រេចផ្តន្ទាទោសទេ រដ្ឋធ្វើសំណើពុំចាំបាច់អនុលោម តាមចំណុចនេះឡើយ)។

បន្ថែមពីនេះ ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ នឹងបិទស្រោម ហើយប្រសិនបើឯកសារទាំងអស់នោះមិនមែនជាភាសាខ្មែរ បារាំង ឬអង់គ្លេសទេ ឯកសារនីមួយៗទាំងនោះត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែភាសាជាភាសាមួយក្នុងចំណោមភាសាទាំងបីនេះ (ភាសាខ្មែរ បារាំង ឬអង់គ្លេស) ដោយមានសេចក្តីបញ្ជាក់ផងដែរ[41]។

ក្រោយពីក្រសួងការបរទេសបានទទួលពាក្យសុំឲ្យធ្វើបត្យាប័ន នឹង លិខិតបញ្ជាក់ភស្តុតាងហើយ រដ្ឋមន្ត្រីក្រសួងការបរទេសត្រូវបញ្ជូនពាក្យសុំ និងលិខិតបញ្ជាក់ភស្តុតាងទាំងនោះ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យសុំនោះបន្តទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ដែលត្រូវរៀបចំសំណុំរឿងបញ្ជូនប្តឹងទៅឲ្យសភាស៊ើបសួរ[42]។

[41]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៧៩

[42]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨០

បុគ្គលដែលគេទាមទារ ត្រូវចូលបង្ហាញខ្លួនចំពោះយុត្តាធិការនៃសភាស៊ើបសួរ ជាអាទិ៍អមដោយមេធាវី ប្រសិនបើគ្មានតុលាការត្រូវចាត់តាំងមេធាវីជូន។ នីតិវិធីនៃការសួរដេញដោលរួច អគ្គព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងការណ៍ និងសេចក្តីថ្លែងការណ៍មេធាវីការពារសិទ្ធិ សភាស៊ើបសួរនិងផ្តល់យោបល់ជាសាលដីកា ដែលមានសំអាងហេតុពីពាក្យកុំបត្យាប័ននោះ។ យោបល់របស់សភាស៊ើបសួរជាយោបល់ព្រមធ្វើបត្យាប័ន និងយោបល់មិនឯកភាពធ្វើបត្យាប័ន។ ក្នុងករណីដែលយោបល់របស់សភាស៊ើបសួរឯកភាព កម្ពុជាត្រូវធ្វើបត្យាប័នបុគ្គលដែលគេទាមទារបញ្ជូនទៅរដ្ឋធ្វើសំណើ តែក្នុងករណីដែលយោបល់របស់សភាស៊ើបសួរជាយោបល់មិនឯកភាពបត្យាប័នមិនត្រូវធ្វើនោះទេ (ក្នុងករណីដែលមានការឃុំខ្លួនបុគ្គលដែលទាមទារ ត្រូវដោះលែងវិញ)។

នៅក្នុងអំឡុងពេល ១(មួយ) ខែ បន្ទាប់ពីទទួលដំណឹងអំពីការធ្វើបត្យាប័ន ឬអំឡុងពេល ២ (ពីរ)ខែ បានកន្លងផុតទៅដោយរដ្ឋស្នើសុំពុំបានបំពេញកិច្ចបត្យាប័ន បុគ្គលដែលគេទាមទារ អាចត្រូវបានដោះលែង វិញ ក៏ប៉ុន្តែនៅក្នុងករណីដែល តុលាការពិនិត្យឃើញថា អំពើរបស់បុគ្គលនោះបានបង្កើតជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌមានសមត្ថកិច្ច ហើយមិនទាន់ត្រូវបានតុលាការធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសនោះតុលាការកម្ពុជា និងអាចធ្វើការផ្តើមការចោទប្រកាន់លើបុគ្គលនោះតាមនីតិវិធីនៃច្បាប់កម្ពុជា។

រដ្ឋស្នើសុំត្រូវបំពេញលក្ខខណ្ឌក្នុងការធ្វើបត្យាប័ននៅក្នុងអំឡុងពេល ២(ពីរ)ខែ បន្ទាប់ពីការចាប់ខ្លួនបើពុំដូច្នេះទេបុគ្គលនោះត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ។

បុគ្គលដែលត្រូវបានគេធ្វើបត្យាប័ន ក៏មានសិទ្ធិក្នុងការប្តឹងតវ៉ាចំពោះការធ្វើបត្យាប័នផងដែរ ដើម្បីសុំឲ្យសភាស៊ើបសួរពិន័យអំពីនិយតភាពនៃការធ្វើបត្យាប័ន។

## ១.១. ករណីពិសេសចំពោះពាក្យសុំឲ្យចាប់ខ្លួនបណ្តោះអាសន្ន

ក្នុងករណីបន្ទាន់ រដ្ឋធ្វើសំណើឲ្យបត្យាប័ន អាចសុំឲ្យចាប់ខ្លួនបុគ្គលដែលគេទាមទារជាបណ្តោះអាសន្ន ក្នុងគោលបំណងដើម្បីកុំ អោយបុគ្គលដែលគេទាមទារ រត់គេចខ្លួនដោយមិនចាំបាច់គោរពនូវបែបបទដោយឡែកឡើយ។ ការសុំនេះអាចធ្វើមុនពាក្យសុំឲ្យធ្វើបត្យាប័ន[43]។

ក្រោយពីបានទទួលពាក្យសុំឲ្យចាប់ខ្លួន ជាបណ្តោះអាសន្នរបស់រដ្ឋ ដែលបានធ្វើសំណើឲ្យធ្វើបត្យាប័ន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ អាចចេញបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួនបុគ្គលដែលគេទាមទារហើយត្រូវបានបញ្ជាដោយអានុភាពអនុវត្តលើដែនដីកម្ពុជាទាំងមូល។ ការបញ្ជានោះត្រូវចុះនិទ្ទេសដូចខាងក្រោម៖

- អត្តសញ្ញាណនៃបុគ្គលដែលគេទាមទារ
- ការយោងនៃពាក្យសុំឲ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

[43]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨១

– ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ។

បន្ថែមពីនេះ បញ្ជានោះត្រូវមានការចុះកាលបរិច្ឆេទ ការចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រា[44]។

ក្រោយពីមានការចាប់ខ្លួនបុគ្គលដែលបានទាមទារ ដោយសមត្ថកិច្ចដែលទទួលបន្ទុកតាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញហើយ សមត្ថកិច្ចត្រូវនាំបុគ្គលនោះទៅបង្ហាញខ្លួនដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីក្នុងរយៈពេលដ៏ខ្លីបំផុត។ ព្រះរាជអាជ្ញានោះ ត្រូវឲ្យដំណឹងអំពីបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួនរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញដល់បុគ្គលដែលគេទាមទារ ព្រមទាំងទទួលចម្លើយពីបុគ្គលនេះវិញផងដែរ ប៉ុន្តែបុគ្គលដែលគេទាមទារ ក៏អាចស្នើសុំឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ស្តាប់ចម្លើយរបស់ខ្លួនផងដែរ។ នីតិវិធីបន្ទាប់មកទៀត ត្រូវផ្ទេរបុគ្គលដែលគេទាមទារនេះទៅពន្ធនាគារភ្នំពេញវិញម្តង[45]។

ទោះបីជាបុគ្គលដែលគេទាមទារត្រូវបានឃុំខ្លួនទៅតាមបញ្ជា របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ហើយក៏ដោយក៏ពុំបានន័យថាឃុំខ្លួនរហូតដល់តុលាការសម្រេចលើពាក្យសុំឲ្យធ្វើបត្យាប័ននោះទេ។ យោងតាមមាត្រា ៥៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលរដ្ឋាភិបាលកម្ពុជាពុំបានទទួលឯកសារទាំងឡាយដូចមានចែងក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) រដ្ឋធ្វើសំណើក្នុងរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃចាប់ខ្លួនបុគ្គលដែលគេទាមទារនោះទេ បុគ្គលដែលស្ថិតក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្តោះអាសន្ន និងត្រូវដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង[46]។

### ១.២ សមត្ថកិច្ចធ្វើពាក្យបណ្តឹងសុំឲ្យធ្វើបត្យាប័ន

ក្រោយពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានទទួលពាក្យសុំ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌រួចមកហើយ អគ្គព្រះរាជអាជ្ញា ត្រូវរៀបចំរៀបសំណុំរឿងដើម្បីប្តឹងអំពីការធ្វើជាពាក្យសុំឲ្យ ធ្វើបត្យាប័នទៅឲ្យសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ[47]។

### ១.៣ សមត្ថកិច្ចសម្រេចបត្យាប័ន

បត្យាប័នអាចត្រូវបានអនុញ្ញាត ឬមិនត្រូវបានអនុញ្ញាត គឺជាសមត្ថកិច្ចផ្តាច់មុខដែលត្រូវបានផ្តល់ទៅឲ្យសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ មានន័យថាសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ គ្មានសិទ្ធិអំណាចក្នុង

[44]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨២
[45]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៣
[46]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨១
[47]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៤

ការសម្រេចអំពីបត្យាប័នទេ ឬសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ក្រៅពីសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញក៏គ្មានសមត្ថកិច្ចនេះដែរ ដែលជាសមត្ថកិច្ចពិសេសរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។

## ១.៤ នីតិវិធីចំពោះមុខសភាស៊ើបសួរ

ជាក់ស្តែងចំពោះបុគ្គលដែលគេទាមទារ ត្រូវតែចូលបង្ហាញខ្លួនមុខសភាស៊ើបសួរ។ បុគ្គលដែលត្រូវបានគេទាមទារផ្ទាល់នោះអាច និងត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬ ចាត់តាំងដោយអ្នកអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ក្នុងនីតិវិធីចំពោះមុខសភាស៊ើបសួរ ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងបន្ទប់សម្ងាត់ ហើយនៅក្នុងករណីចាំបាច់សភាស៊ើបសួរអាចហៅរកអ្នកបកប្រែបាន។ [48]

ជាឧទាហរណ៍៖ ក្នុងករណីដែលបុគ្គលដែលគេទាមទារមិនចេះ ភាសាខ្មែរ ឬ គរថ្លង់ នេះអាចជាករណីចាំបាច់សម្រាប់សភាស៊ើបសួរហៅរកអ្នកបកប្រែ។ ខ្មែរ ឬ គរថ្លង់ នេះអាចជាករណីចាំបាច់សម្រាប់សភាស៊ើបសួរហៅរកអ្នកបកប្រែ។

### ក. សិទ្ធិ និង ភាតព្វកិច្ចបុគ្គលដែលគេទាមទារ

បុគ្គលដែលគេទាមទារ មានកាតព្វកិច្ចត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរ។ ប៉ុន្តែ បុគ្គលដែលគេទាមទារ ក៏អាចមានសិទ្ធិពឹងពាក់មេធាវីដែលខ្លួនជ្រើសរើស ឬមេធាវីដែលចាត់តាំងដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដើម្បីអមក្នុងនីតិវិធី ចំពោះមុខសភាស៊ើបសួរផងដែរ។ ម្យ៉ាងវិញទៀត បុគ្គលដែលគេទាមទារដែលត្រូវបានគេឃុំខ្លួន អាចសុំឲ្យគេដោះលែងនៅក្រៅឃុំ តាមរយៈការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរជូនសភាស៊ើបសួរ ដែលសម្រេចក្រោយពីបានស្តាប់ចម្លើយរបស់ខ្លួន (បុគ្គលដែលគេទាមទារ) សេចក្តីសន្និដ្ឋានការពាររបស់មេធាវី និងសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាផងដែរ[49]។

### ខ. ការសម្រេចបត្យាប័ន និងយោបល់ដោយសភាស៊ើបសួរ

ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានការពាររបស់មេធាវី និង សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញារួចហើយ សភាស៊ើបសួរត្រូវផ្តល់យោបល់ ជាសាលដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំឲ្យធ្វើបត្យាប័ននោះ។[50] ប្រសិនបើសភាស៊ើបសួរយល់ឃើញថា លក្ខខណ្ឌអនុញ្ញាតបត្យាប័នមិនត្រូវបានបំពេញទេ សភាស៊ើបសួរសម្រេចអាចបដិសេធការស្នើសុំបត្យាប័ននោះក្នុងសាលដីកា ឬ ដូចក្នុងច្បាប់បានបញ្ជាក់ថា "សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃ

[48]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៥
[49]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៧
[50]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៥

បត្យាប័នមិនត្រូវបានបំពេញ [51] "។ ម្យ៉ាងវិញទៀត ក្នុងករណីប្រសិនបើបុគ្គលដែលគេទាមទារបានយល់ឲ្យគេបញ្ជូនខ្លួនតាមពាក្យសុំរបស់រដ្ឋផ្ញើសំណើ ក្រោយពីខ្លួនបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន។

### គ. អានុភាពនៃយោបល់របស់សភាស៊ើបសួរ

ក្រោយពីសាលដីកាសភាស៊ើបសួរចូលជាស្ថាពរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវទទួលដំណឹងនេះភ្លាម។ រាជរដ្ឋាភិបាល មិនអាចធ្វើបត្យាប័នដោយឯកឯងបានទេ បើកាលណាសភាស៊ើបសួរបានផ្តល់យោបល់មិនព្រមឲ្យធ្វើបត្យាប័ន ហើយបុគ្គលដែលគេទាមទារ និងត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ លើកលែងតែជននេះ ត្រូវឃុំខ្លួនតាមសេចក្តីសម្រេចពីរឿងផ្សេងទៀត។ កាលបើសភាស៊ើបសួរយល់ព្រមឲ្យធ្វើបត្យាប័នវិញ ករណីនេះរដ្ឋមន្ត្រីខាងលើត្រូវបញ្ជូនរឿននេះ ទៅកាន់រាជរដ្ឋាភិបាលដើម្បីចេញអនុក្រឹត្យបង្គាប់ឲ្យធ្វើបត្យាប័នជននេះ។

ក្នុងករណីបន្ទាប់នៃនីតិវិធីបត្យាប័ន រដ្ឋផ្ញើសំណើត្រូវទទួលបន្ទុកលើសោហ៊ុយនៃការប្រគល់បុគ្គលដែលគេទាមទារ ហើយនៅពេលដែលបុគ្គលនេះចាកចេញពីកម្ពុជា រដ្ឋផ្ញើសំណើត្រូវធ្វើក្បួនការពារឲ្យមានសុវត្ថិភាព។ តែផ្ទុយទៅវិញបើរដ្ឋនេះ មិនមកទទួលបុគ្គលដែលខ្លួនទាមទារក្រោយពីភាគីកម្ពុជាបញ្ជូនដំណឹងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃទេនោះ បុគ្គលដែលគេទាមទារ និងត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ។

គួរបញ្ជាក់ផងដែរថា ប្រសិនបើជាសភាស៊ើបសួរមិនបានយល់ស្របចំពោះពាក្យសុំបត្យាប័នរបស់រដ្ឋផ្ញើសំណើក្នុងសាលដីការរបស់ខ្លួន រដ្ឋាភិបាលមិនអាចធ្វើបត្យាប័នបានឡើយ[52]។

## ផ្នែកទី២. បត្យាប័នស្នើដោយប្រទេសកម្ពុជាចំពោះរដ្ឋបរទេស

### ១. សិទ្ធិធ្វើបណ្តឹងមោឃភាពនៃបត្យាប័ន

ទាក់ទងទៅនិងនីតិវិធីនៃការធ្វើបត្យាប័ន ដោយរដ្ឋបរទេសតាមសំណើរបស់កម្ពុជាវិញ បុគ្គលដែលត្រូវបានធ្វើបត្យាប័នអាចប្តឹងសុំមោឃភាពកិច្ចនីតិវិធីនៃការធ្វើបត្យាប័នរបស់រដ្ឋបរទេសបាន។ ក៏ប៉ុន្តែនៅក្នុងបណ្តឹងនេះ (បណ្តឹងសុំមោឃភាពកិច្ចនីតិវិធីនៃការធ្វើបត្យាប័នរបស់រដ្ឋបរទេស) នេះគឺត្រូវតែប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញដែលជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចពិចារណាលើនិយតភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល និង ត្រូវតែប្តឹងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីពេលដែលខ្លួនមកដល់កម្ពុជា។

[51]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៨៦

[52]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៨៨

## ២. នីតិវិធីចំពោះមុខសភាស៊ើបសួរ

កាលណាទទួលពាក្យបណ្តឹងសុំមោឃភាពកិច្ចនីតិវិធី នៃការធ្វើបត្យាប័នដោយរដ្ឋបរទេស សភាស៊ើបសួរត្រូវសម្រេចសេចក្តីអំពីបណ្តឹងនេះ បន្ទាប់ពីបានស្តាប់ចម្លើយរបស់បុគ្គលដែលត្រូវបានគេធ្វើបត្យាប័ន សេចក្តីសន្និដ្ឋានការពាររបស់មេធាវី និង សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា[53]។

## ៣. អានុភាពនៃមោឃភាពបត្យាប័ន

### ៣.១. អានុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព

ជាទូទៅនៅពេលដែលសភាស៊ើបសួរ បានទទួលពាក្យបណ្តឹងសុំមោឃភាពកិច្ចនីតិវិធី ក្នុងសំណុំរឿងព្រហ្មទណ្ឌទោះនៅក្នុងដំណាក់កាលស៊ើបអង្កេត ដោយមន្ត្រីនគរបាលយុត្តិធម៌ក្តី ឬដំណាក់កាលចោទប្រកាន់ដោយព្រះរាជអាជ្ញាក្តី ឬដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរក្តី ឬនិយាយម្យ៉ាងទៀតក្នុងដំណាក់កាលណាក៏ដោយមុនដំណាក់កាលជំនុំជម្រះ សំណុំរឿងក្តីព្រហ្មទណ្ឌត្រូវបញ្ជូនមកសភាស៊ើបសួរ។ ដូច្នេះ នីតិវិធីនៃសំណុំរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាលណាមួយ បានរៀបរាប់ខាងលើនេះ និងត្រូវផ្អាកជាបណ្តោះអាសន្នសិនរហូតដល់សភាស៊ើបសួរបង្វិលសំណុំរឿងក្តី ទៅឲ្យខ្លួនវិញ ក្រោយពីសម្រេចលើបណ្តឹងសុំមោឃភាពជាដើម។ ផ្ទុយទៅវិញ ចំពោះបណ្តឹងសុំមោឃភាពបត្យាប័នវិញ នីតិវិធីនៃការចោទប្រកាន់ដែលកំពុងធ្វើលើជនដែលត្រូវបានគេបានធ្វើបត្យាប័នបែរជាមិនត្រូវផ្អាកទៅវិញ ទោះបីជាបណ្តឹងនេះ បានប្តឹងមកខាងសភាស៊ើបសួរហើយក៏ដោយ[54]។ ករណីនេះអាចដោយសារតែ បណ្តឹងមោឃភាពបត្យាប័ន គឺមានគោលបំណងដើម្បីធ្វើមោឃភាពនីតិវិធីនៃការធ្វើបត្យាប័នរបស់រដ្ឋបរទេស តែមិនពាក់ព័ន្ធនិងនីតិវិធីនៃការចោទប្រកាន់ទៅលើជន ដែលត្រូវបានធ្វើបត្យាប័នក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌដែលកំពុងដំណើរការដោយស្ថាប័នតុលាការកម្ពុជាឡើយ។ ដូច្នេះនេះជាការសមហេតុផល ដែលបណ្តឹងសុំមោឃភាពបត្យាប័ន ដែលមិនបានផ្អាកនីតិវិធីនៃការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌដែលកំពុងដំណើរការនោះ[55]។

### ៣.២. អានុភាពនៃមោឃកម្មចំពោះបត្យាប័ន

ទោះបីជាបណ្តឹងសុំមោឃភាពបត្យាប័ន ពុំបានផ្អាកនីតិវិធីនៃការចោទប្រកាន់ក៏ដោយ ប៉ុន្តែដោយតាមអំណាចសេចក្តីសម្រេចរបស់តុលាការ កាលណាបត្យាប័នត្រូវចាត់ទុកជាមោឃៈដោយសារដីការបស់សភាស៊ើបសួរបានចូលជាស្ថាពរហើយ នីតិវិធីនៃការចោទប្រកាន់ដែលកំពុងតែដំណើរការនោះត្រូវតែបញ្ចប់។ ចំណែកឯបុគ្គលដែលត្រូវបានធ្វើបត្យាប័នត្រូវដោះលែងឲ្យមានសេរីភាពវិញ និង មានលទ្ធភាពចាកចាញដោយសេរីពីដែន

[53]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៩១

[54]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៩១

[55]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា៥៩២

ដីកម្ពុជា។ ប៉ុន្តែផុតរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដោះលែងឲ្យមានសេរីភាព បុគ្គលដែលត្រូវបានធ្វើបត្យាប័ន អាចត្រូវបានគេចាប់ខ្លួនម្តងទៀត លើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឲ្យមានការធ្វើបត្យាប័នបុគ្គលនោះ[56]។

## ៤. ការយល់ព្រមរបស់រដ្ឋដែលបានផ្តល់អាណិកជនបរទេសដល់ប្រទេសកម្ពុជា

ប្រសិនបើមានការស្នើសុំធ្វើបត្យាប័នអាណិកជនបរទេសបន្ត ពីប្រទេសកម្ពុជាដោយរដ្ឋណាមួយផ្សេងទៀត ប្រទេសកម្ពុជាអាចយល់ព្រមចំពោះការស្នើសុំនោះបានផងដែរ ប៉ុន្តែទាមទារឲ្យមានការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជនបរទេសនេះឲ្យមកកម្ពុជាជាមុនសិន។ ក្រោយពីប្រទេសកម្ពុជាបានទទួលបត្យាប័ននៃអាណិកជនបរទេស ហើយបន្ទាប់មកកម្ពុជាបានទទួលពាក្យបណ្តឹងសុំធ្វើបត្យាប័ន ពីរដ្ឋបរទេសផ្សេងទៀត នោះភាគីកម្ពុជាអាចនឹងយល់ព្រមតាមសំណើ បើរដ្ឋដែលបានប្រគល់អាណិកជននោះ យល់ព្រមឲ្យប្រទេសកម្ពុជាធ្វើបត្យាប័នជននោះ។

ជាករណីលើកលែង ប្រទេសកម្ពុជាអាចយល់ព្រមចំពោះពាក្យសុំធ្វើបត្យាប័នអាណិកជនបរទេសដោយរដ្ឋណាមួយផ្សេងនោះបានដោយពុំមានការចាំបាច់មានការយល់ព្រមពីរដ្ឋប្រគល់អាណិកជនបរទេសដល់កម្ពុជាឡើយ កាលណាដែលអាណិកជនបរទេសនោះមានលទ្ធភាពចាកចេញដោយសេរី ពីដែនដីកម្ពុជារួចទៅហើយក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ[57]។

[56]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៩៣

[57]ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៥៩៤

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និងតាមរយៈបទបញ្ញត្តិ ឬឯកសារផ្សេងៗដែលបានពាក់ព័ន្ធជាមួយនិងខ្លឹមសារនៃប្រធានបទ បត្យាប័ន ក្នុងការធ្វើសន្ធិសញ្ញាជាមួយប្រទេសជិតខាងដែលពាក់ព័ន្ធនិងប្រទេសកម្ពុជា និងផ្ដោតសំខាន់ទៅលើការព្រមព្រៀងគ្នារវាងរដ្ឋ និងរដ្ឋ ដែលអាចធ្វើឡើងតាមរយៈសន្ធិសញ្ញា និងការព្រមព្រៀងរវាងរដ្ឋដាក់សំណើ និងរដ្ឋទទួលសំណើ។

សរុបសេចក្ដីមកជារួម បត្យាប័នជាកិច្ចនីតិវិធីលក្ខណៈអន្តរជាតិមួយ ដែលមានការប្រគល់ជនល្មើសមកឲ្យកម្ពុជា ឬកម្ពុជាប្រគល់បុគ្គលបុគ្គលដែលគេទាមទារតាមសំណើរដ្ឋធ្វើសំណើ ឬទៅកាន់រដ្ឋផ្សេងទៀត។ ក៏ប៉ុន្តែការធ្វើបត្យាប័នអាចធ្វើទៅរួច លុះត្រាតែមានការគោរពនូវលក្ខខណ្ឌដែលច្បាប់កម្ពុជាបានកំណត់ ជាឧទាហរណ៍អំពើដែលត្រូវចោទប្រកាន់លើជននោះ ដែលមានជាបទល្មើសព្រហ្មទណ្ឌតាមច្បាប់កម្ពុជាផង និងច្បាប់នៃរដ្ឋធ្វើសំណើផង។ លើសពីនេះទៅទៀតនោះ មានតែស្ថាប័នតុលាការ (សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ) តែប៉ុណ្ណោះ ដែលមានសមត្ថកិច្ចសម្រេចថា ត្រូវធ្វើបត្យាប័នឬអត់ ហើយរាជរដ្ឋាភិបាលកម្ពុជាពុំមានសិទ្ធិក្នុងការធ្វើបត្យាប័នដោយឯកឯងឡើយ ក្នុងករណីណាដែលមិនមានយោបល់យល់ព្រមឲ្យធ្វើបត្យាប័នពីសភាស៊ើបសួរ។

ជាក់ស្ដែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងវិញ ពុំទាន់មានច្បាស់លាស់ទាក់ទងទៅនឹងនីតិវិធីនៃការធ្វើបត្យាប័ននូវឡើយទេ ប៉ុន្តែទន្ទឹមនឹងនេះយើងក៏មាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលមានចែងអំពីនីតិវិធីមួយចំនួនផងដែរ និង មាននៅក្នុងច្បាប់ពិសេសមួយចំនួនទៀតដូចជា ច្បាប់ស្ដីពីការប្រឆាំងអំពីភេរវកម្ម ឆ្នាំ២០០៧ តែប៉ុណ្ណោះ។

ការធ្វើបត្យាប័នត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ក្រមនេះយកមកអនុវត្តក្នុងការស្នើសុំការធ្វើបត្យាប័ន នៅពេលអវត្តមាននៃសន្ធិសញ្ញានៃការធ្វើបត្យាប័ន រវាងប្រទេសកម្ពុជា និងរដ្ឋដែលស្នើសុំការធ្វើបត្យាប័ននិងបានរៀបរាប់យ៉ាងលម្អិតអំពីដែនកំណត់នៃការធ្វើបត្យាប័ន និងមូលហេតុដែលការធ្វើបត្យាប័នអាចត្រូវបានបដិសេធព្រមទាំងបានរួមបញ្ចូលបទបញ្ញាដែលមានការទទួលស្គាល់ក្នុងសន្ធិសញ្ញាអន្តរជាតិ។ ទោះបីជាប្រទេសកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាធ្វើបត្យាប័ន ជាមួយប្រទេសតែបី (ថៃ ចិន និងឡាវ) ក៏ដោយ បទបញ្ញត្តិនៃការធ្វើបត្យាប័នដែលមាននៅក្នុងក្រមនេះ បានផ្ដល់គោលដៅណែនាំដែលមានសារៈសំខាន់បំផុត អំពីនីតិវិធីបត្យាប័ននៅប្រទេសកម្ពុជា។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តនៃបត្យាប័ននេះ អាចធ្វើទៅបានអាស្រ័យទៅលើស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងយុត្តិធម៌ ក្រសួងការបរទេស ក្រសួងមហាផ្ទៃ ស្ថានទូត សាលាឧទ្ធរណ៍ តុលាការកំពូល និងសហប្រតិបត្តិការអន្តរជាតិផងដែរ។

ចំណែកឯការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ (រដ្ឋដែលត្រូវបានស្នើសុំ) ទៅអោយអាជ្ញាធររបស់រដ្ឋមួយទៀត(រដ្ឋដែលបានធ្វើការស្នើសុំ)ក្នុងគោលបំណងផ្តន្ទាទោសព្រហ្មទណ្ឌឬការអនុវត្តន៍នៃការកាត់ទោស។ ដូចជាពិសេសជាងនេះទៅទៀត ការធ្វើបត្យាប័នមិនមែនជាទស្សនៈថ្មីក៏ដោយ សកលភាវូបនីយកម្ម និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ឆ្លងកាត់ព្រំដែន និងយុត្តាធិការរដ្ឋ បានធ្វើឲ្យគោលការណ៍ណែនាំជាក់លាក់សម្រាប់ការធ្វើបត្យាប័ន ឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសក្លាយទៅជាភាពចាំបាច់បំផុត។

ដូច្នេះការធ្វើបត្យាប័នគឺជាទង្វើនៃការផ្តល់ជំនួយផ្នែកច្បាប់ រវាងប្រទេសទាំងពីរមានការព្រួយបារម្ភមួយគឺការផ្ទេររបស់មនុស្សដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ, និងដើម្បីបម្រើការកាត់ទោសឬដើម្បីនាំយកទណ្ឌិតទៅកាត់ទោស។ ធ្វើបត្យាប័ន ឬមិនធ្វើបត្យាប័នពលរដ្ឋនៃប្រទេសមួយផ្សេងទៀត, រដ្ឋមានសិទ្ធិក្នុងការសម្រេចចិត្តនេះ។ ប្រសិនបើមានការផ្ទេរដូចជាការត្រូវបានធ្វើឡើងជាប្រទេសដែលដាក់ជូនសំណើសម្រាប់ការធ្វើបត្យាប័នមួយដែល និងត្រូវបាននាំយកមកនូវការទទួលខុសត្រូវ មានកាតព្វកិច្ចរបស់ខ្លួនសម្រាប់តែជាតិបទល្មើសទាំងនោះដែលត្រូវបានរាយនៅក្នុងបញ្ញត្តិមួយសម្រាប់ការធ្វើបត្យាប័ននេះ។ សម្រាប់ឧក្រិដ្ឋកម្ម ផ្សេងទៀតដើម្បីដាក់ទោសមនុស្សដែលនៅក្រោមការធ្វើបត្យាប័ននេះមិនត្រូវបានអនុញ្ញាតដើម្បីដំណើរការ។ តាមក្បួនមួយអន្តរជាតិចង់ឱ្យឧក្រិដ្ឋជនបានប្រារព្ធឡើងដោយមានជំនួយពីប៉ូលិសអន្តរជាតិនេះ។ រដ្ឋជាច្រើនបដិសេធមិនធ្វើបត្យាប័នចំពោះជនជាតិបរទេសត្រូវបានគេចោទប្រកាន់ពីបទល្មើស ប្រសិនបើពួកគេប្រព្រឹត្តក្នុងប្រទេសកំណើតរបស់គាត់សម្រាប់ហេតុផលនយោបាយ។ លើសពីនេះទៀតក្នុងករណីមួយចំនួន, រដ្ឋផ្សេងទៀតអាចបដិសេធការផ្លាស់ប្តូរនៃចម្លែកនេះ, ប្រសិនបើច្បាប់របស់ខ្លួនមិនបានផ្តល់ការដាក់ទោសព្រហ្មទណ្ឌ ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់មនុស្សម្នាក់នៅក្នុងប្រទេសកំណើតរបស់គាត់។ ប្រសិនបើមានមនុស្សម្នាក់ ដែលចង់ប្រឈមមុខនិងការពិន័យការស្លាប់ឬមានហេតុផលល្អក្នុងការជឿថារដ្ឋដែលបានដាក់សំណើ មួយមិនអាចផ្តល់យុត្តិធម៌សមរម្យប្រទេសដែលមានដូចជាមនុស្សម្នាក់នេះគឺមានផងដែរ, មានសិទ្ធិបដិសេធមិនធ្វើបត្យាប័នជារៀងរាល់។ លើសពីនេះទៀតប្រសិនបើមានការសង្ស័យថាប្រទេសនេះ បានដាក់សំណើមួយសម្រាប់ធ្វើបត្យាប័នក្នុងគោលបំណងដើម្បីកាត់ទោសប្រជាពលរដ្ឋមួយនៅលើមូលដ្ឋាននៃការប្រណាំង, រួមភេទ, ឬប្រភពដើមរបស់ជាតិ, ការតម្រង់ទិសផ្លូវភេទរបស់គាត់និងដូច្នេះនៅលើ។

# អនុសាសន៍

# អនុសាសន៍

ក្រុមយើងខ្ញុំ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្ដីគាប់ប្រសើរ និងបានស្វែងយល់យ៉ាងច្បាស់អំពីប្រធានបទមួយនេះ យើងខ្ញុំទាំងពីរអ្នកក៏បានជួបឧបសគ្គជាច្រើននៅក្នុងការស្វែងរកនូវឯកសារ ជាពិសេសក្នុងការស្វែងរកឯកសារទៅតាមបណ្ដាស្ថាប័នរដ្ឋ ក្រសួង ឬទៅតាមស្ថាប័នគ្រប់ជាន់ថ្នាក់ និងតាមប្រព័ន្ធអ៊ិនធើណែត ឬវេបសាយមួយចំនួន មានការរអាក់រអួលនៅក្នុងការស្វែងរក តែទោះបីជាយ៉ាងនេះក្ដីក៏ក្រុមយើងខ្ញុំបានខិតខំអស់ពីកម្លាំងកាយចិត្តដើម្បីទៅស្វែងរក និងព្យាយាមប្រមូលឯកសារណាដែលពាក់ព័ន្ធដើម្បីជាការចងក្រងជាសៀវភៅសារណាបញ្ចប់ក្នុងឆ្នាំនេះ ។

ដោយសារតែប្រទេសកម្ពុជាពុំទាន់មានច្បាប់ស្ដីពីបត្យាប័ននៅឡើយទេ ពោលគឺមានត្រឹមតែក្រមនីតិវិធីព្រហ្មទណ្ឌនិងច្បាប់ពិសេសមួយចំនួនដែលពាក់ព័ន្ធទៅនិងការធ្វើបត្យាប័នតែប៉ុណ្ណោះ។ ចំណែកឯក្រមនីតិវិធីព្រហ្មទណ្ឌដែរបានបញ្ជាក់ពីនីតិវិធីធ្វើបត្យាប័ន ក៏ដោយក៏កំណែទម្រង់ក្របខណ្ឌច្បាប់របស់ប្រទេសកម្ពុជា ឲ្យបានឆាប់រហ័សពាក់ព័ន្ធនឹងការធ្វើបត្យាប័នដែលមានលក្ខណៈចាំបាច់ ត្រូវពិនិត្យឡើងវិញអោយបានសមស្របទៅតាមសន្ធិសញ្ញាគំរូរបស់ អ.ស.ប ។

ដើម្បីជាការរួមចំណែកក្នុងការធ្វើសេចក្ដីសម្រេចអោយបានល្អ គាប់ប្រសើរនិងមានសេចក្ដីយុត្តិធម៌នោះយើងខ្ញុំទាំងពីរនាក់សូមបញ្ចេញយោបល់ខ្លះចំពោះការបំពេញនូវការងាររបស់បត្យាប័ន៖

ក. នីតិវិធីបត្យាប័ននៅប្រទេសកម្ពុជា ត្រូវបានអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ (ក្រម) និងសន្ធិសញ្ញាធ្វើបត្យាប័នទ្វេភាគី។ ជាងនេះទៅទៀត មាត្រដ្ឋានអន្តរជាតិផ្ដល់គោលការណ៍ណែនាំ ដែលមានសារៈសំខាន់ ស្ដីពីនីតិវិធីធ្វើបត្យាប័នសមស្រប។ ទោះបីយ៉ាងណាក៏ដោយបទពិសោធន៍ថ្មីដែលបានបង្ហាញថា ការអនុវត្តន៍ការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា គួរតែត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីរួមបញ្ចូលសិទ្ធិមនុស្ស និងដើម្បីធានាថាការធ្វើបត្យាប័នត្រូវបានអនុវត្តដោយគ្មានការបង្អាក់។

ខ. ទោះបីជានីតិវិធីធ្វើបត្យាប័ននេះ ត្រូវបានបញ្ជាក់នៅចុងក្រោយនេះក៏ដោយ កំណែទម្រង់ក្របខណ្ឌដែលច្បាប់បានកំណត់របស់កម្ពុជាឲ្យបានឆាប់រហ័សពាក់ព័ន្ធនិងការធ្វើបត្យាប័ន ត្រូវមានលក្ខណៈចាំបាច់។

គ. មិនមានភាពស៊ីសង្វាក់គ្នាមួយចំនួនរវាងសន្ធិសញ្ញាគំរូរបស់ **អ.ស.ប** និងបទបញ្ញត្តិក្នុងច្បាប់ស្ដីពីការធ្វើបត្យាប័នរបស់កម្ពុជា ដូចជារយៈពេលនៃការឃុំខ្លួនជនសង្ស័យ ដែលត្រូវបានអនុញ្ញាត នៅពេលដែលពិចារណាលើសំណើធ្វើបត្យាប័ន៖ ពេលដែលសន្ធិសញ្ញាគំរូរបស់ **អ.ស.ប** អនុញ្ញាតឲ្យមានរយៈពេលត្រឹមតែ៤០ថ្ងៃ ក្រមនេះអនុញ្ញាតអោយមានរយៈពេល៦០ថ្ងៃ។

ឃ. នៅក្នុងក្រមនីតិវិធីធ្វើបត្យាប័ន មិនបានចែងឲ្យបានតែច្បាស់ថាការបដិសេធ នៅពេលដែលបុគ្គលដែលគេធ្វើបត្យាប័ន ត្រូវកាត់ទោសប្រហារជីវិតនៅក្នុងប្រទេសដែលស្នើសុំការធ្វើបត្យាប័ននៅឡើយ។

ង. ដោយហេតុតែក្រមនេះចូលជាធរមានចំពោះការស្នើសុំការធ្វើបត្យាប័ន នៅពេលមិនមានសន្ធិសញ្ញាដែលពាក់ព័ន្ធ និងទោះជាបីជាប្រទេសកម្ពុជាមិនមានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងធ្វើបត្យាប័នតិចតួចក៏ដោយភាពខ្វះចន្លោះនេះគឺជាបញ្ហាដែលគួរអោយបារម្ភ។

ច. ទោះបីជាប្រទេសកម្ពុជាបានចុះហត្ថលេខា លើសន្ធិសញ្ញាជាមួយ ប្រទេសតែ៣ (ថៃ ចិន និងឡាវ) ក៏ដោយក៏បទបញ្ញត្តិខ្លះនៃការធ្វើបត្យាប័ន ដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់គោលការណ៍ណែនាំដែលមានសារៈសំខាន់អំពីនីតិវិធីបត្យាប័ននៅប្រទេសកម្ពុជា។

ឆ. ខុសប្លែកពីសន្ធិសញ្ញាគម្រូរបស់ **អ.ស.ប** ក្រមនេះមិនបានចែងថា ការដាក់ទណ្ឌកម្មគឺជាមូលហេតុចាំបាច់ និងឬមានលក្ខណៈខុសប្លែក ដើម្បីបដិសេធការស្នើសុំការធ្វើបត្យាប័នឡើយ។

ជ. ក្រមនេះមិនបានចែងអំពីបញ្ហាសិទ្ធិមនុស្សសំខាន់ៗឡើយ។

# ឯកសារយោង

# ឯកសារយោង


1. រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣នៃព្រះរាជាណាចក្រ ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
2. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
3. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
4. ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងផ្នែកយុត្តិធម៌ និងផ្នែកព្រហ្មទណ្ឌ ប្រកាសនៅថ្ងៃ១៤ ខែមករា ឆ្នាំ២០១០
5. ច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម ប្រកាសនៅថ្ងៃទី១០ខែកក្កដាឆ្នាំ២០០៧
6. សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ អនុម័តថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩
7. សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន អនុម័តថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០
8. សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ អនុម័តថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥
9. សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម អនុម័តថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤
10. សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសហព័ន្ធរុស្ស៊ី អនុម័តថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨
11. អនុសញ្ញាទ្វេភាគីស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង អនុម័តថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥
12. កិច្ចព្រមព្រៀងទ្វេភាគីស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ អនុម័តថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០
13. សៀវភៅលោកសាស្រ្តចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌ
14. លោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត
15. សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារឆ្នាំ២០១៧។
16. ដកស្រង់ចេញពីគេហទំព័រ កម្ពុជាថ្មី រៀបរៀងដោយលោកៈ សេម វាសនា

17. ឯកសារជំនួយស្មារតី "ក្របខណ្ឌបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ រៀបរៀងដោយ និស្សិត ទាវ រដ្ឋា
18. ប្រសាសន៍អ្នកនាំពាក្យពីក្រសួងមហាផ្ទៃ លោក ជិន ម៉ាលីន

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ សន្ធិសញ្ញាទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ អនុម័តកាលពីថ្ងៃថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥
- ឧបសម្ព័ន្ធទី២ សន្ធិសញ្ញាទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ អនុម័តកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩
- ឧបសម្ព័ន្ធទី៣ សន្ធិសញ្ញាទ្វេភាគីរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋសង្គមរាស្ត្រនិយមវៀតណាម អនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤
- ឧបសម្ព័ន្ធទី៤ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន អនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០
- ឧបសម្ព័ន្ធទី៥ អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង អនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥
- ឧបសម្ព័ន្ធទី៦ កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ អនុម័តថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០
- ឧបសម្ព័ន្ធទី៧ កិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា អនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩
- ឧបសម្ព័ន្ធទី៨ សេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម
- ឧបសម្ព័ន្ធទី៩ នីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧
- ឧបសម្ព័ន្ធទី១០ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី អនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨
- ឧបសម្ព័ន្ធទី១១ ដីកាបញ្ជូនអោយចាប់ខ្លួន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

# ឧបសម្ព័ន្ធទី១

LA47

## សន្ធិសញ្ញា
## រវាង
## ព្រះរាជាណាចក្រកម្ពុជា
## និង
## សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
## ស្ដីពី បត្យាប័ន

******* * *******

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលតទៅនេះកំណត់ហៅថា " ភាគីចុះកិច្ចព្រមព្រៀង "

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នា ទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាងតាមតាមការចុះសន្ធិសញ្ញាបត្យាប័ន បានព្រមព្រៀងគ្នាដូចតទៅ :

### ប្រការទី ១
### កាតព្វកិច្ចត្រូវធ្វើបត្យាប័ន

ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដី នៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្ដី ឬ ដើម្បីអោយទទួលទោស ឬ អនុវត្តទណ្ឌកម្មតាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័ន បានណាមួយ ។

## ប្រការទី ២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១-ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោស តាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬ ដោយរូបភាពផ្សេងទៀត នៃការឃុំឃាំង សំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២-កាលណាមានសំណើបត្យាប័នពាក់ពន្ធ័ដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើស ដែល អាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួលដូចមានចែងក្នុង សាលក្រម នៅសល់យ៉ាងតិចបំផុត ៦ខែ ទៀត ។

៣-ក្នុងស្មារតីប្រការនេះ ការកំណត់ថាបទល្មើសណាមួយ ជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថា អង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទ ល្មើសដូចគ្នា ឬ កំណត់បទល្មើស ដោយពាក្យពេចន៍ដូចគ្នានោះទេ ។

៤-កាលណាបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្មារតីនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ន នេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័នដដែលនេះ ហើយដែលមានលក្ខណៈ គ្រប់គ្រាន់សំរាប់ធ្វើបត្យាប័ន លើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំង ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ និង ២ របស់ប្រការនេះ ។

## ប្រការទី ៣
## មូលដ្ឋាននៃការបដិសេធជាចំខាត

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតអោយធ្វើបានឡើយ ក្នុងករណីណាមួយ ដូចខាង ក្រោមនេះ :

១-ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ

ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃរូបជនទាំងនោះ ។

២-ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្មតថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថា បានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣-បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន គឺជាបទល្មើសចែងដោយច្បាប់អាជ្ញាសឹកសុទ្ធសាធរបស់ភាគីដាក់សំណើ ។

៤-ការចោទប្រកាន់ ឬ ការអនុវត្តន៍ការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នេះនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥-ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦-ប្រសិនបើ សាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយគ្មានបានផ្តល់ការជូនពត៌មានទាន់ពេលវេលា អំពីសវនាការកាត់ក្តីនេះ និង គ្មានឱកាសសំរាប់ជនជាប់ចោទចាត់ចែង ការការពារក្តី របស់ខ្លួន និង គ្មានឱកាសដើម្បីឱ្យសំណុំរឿងក្តីរបស់ខ្លួនបាន ត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័នអាចបដិសេធបានក្នុងករណីណាមួយ ដូចខាងក្រោមនេះ :

១-យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនិងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំដោយខ្លួនឯង ។

២-ភាគីទទួលសំណើ កំពុងតែធ្វើនីតិវិធីជំនុំជំរះក្តី លើជនដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះ ។

៣-ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមតិភាព និងទស្សនៈវិស័យផ្នែកមនុស្សធម៌ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាម៉ី

១-ភាគីចុះកិច្ចព្រមព្រៀងម្ខាង១ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២-ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់ឱ្យ ដោយយោងទៅលើកថាខណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង ភស្តុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣-ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះ បានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់ត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្តល់ពត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូតវៀវលែងតែមានបទបញ្ញាត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧

## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១-សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ :

ក-ឯកសារ សេចក្តីបញ្ជាក់ ឬ ភស្តុតាងដ៏ទៃទៀត មានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ.

ខ-សេចក្តីបញ្ជាក់ លើអង្គហេតុនៃបណ្តឹងក្តី

គ-រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន.

ឃ-រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង-រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តន៍ទណ្ឌកម្មចំពោះបទល្មើសប្រសិនបើមាន ។

២-សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំដើម្បីចោទប្រកាន់ ត្រូវជាមួយផងដែរនូវ :

ក-សេចក្តីចំលងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ភាគីដាក់សំណើ ។

ខ-ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ ខ្លួនមែន ។

៣-ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ កាលណាសំណើបត្យាប័នទាក់ទងទៅនឹងជនដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់មកជាមួយនូវ :

ក-សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ.

ខ-ភស្តុតាងបញ្ជាក់ថា ជនដែលត្រូវស្នើសុំ ពិតជាជនដែលកំណត់ក្នុងសាលក្រម.

គ-សេចក្តីបញ្ជាក់បង្ហាញអំពីកំរិតដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ-សេចក្តីបញ្ជាក់ទាក់ទងនិងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការ ការ-
ពារខ្លួនរបស់គេ ឬ ក៏ចាត់អោយការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ចំពោះករណីដែលជននោះត្រូវបានសំរេចកំបាំងមុខ អោយជាប់ទោស ចំពោះបទល្មើសរបស់គាត់ ។

៤-រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនអោយក្នុងក្របខណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និង ភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេស ។

## ប្រការទី ៨
## ពត៌មានបន្ថែម

ប្រសិន់បើភាគីទទួលសំណើយល់ឃើញថា ពតិមានដែលផ្តល់សំរាប់គាំទ្រសំណើបត្យាបន័ ពុំមានលក្ខណៈគ្រប់គ្រាន់ស្របតាមសន្ធិសញ្ញាដែលអនុញ្ញាតអោយធ្វើបត្យាបន័បាន ភាគីនោះអាចស្នើសុំផ្តល់ពិតមានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនពតិមានបន្ថែមតាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

## ប្រការទី ៩
## ការចាប់ខ្លួនបណ្តោះអាសន្ន

១-ក្នុងករណីបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្តោះអាសន្ននូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយលក្ខណ៍អក្សរតាមផ្លូវទូត ឬតាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល) ។

២-សំណើសុំខាងលើត្រូវមាន :

-ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ

## ប្រការទី ១១
## ការសំរេចចិត្តទៅលើការស្នើ

១-ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបត្យាប័ន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន និង ត្រូវជូនពត៌មានយ៉ាងឆាប់រហ័សតាមរយៈផ្លូវទូត ទៅភាគីដាក់សំណើអំពីសេចក្តីសំរេចចិត្តរបស់ខ្លួន ។

## ប្រការទី ១២
## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១-ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើត្រូវសំរេច អំពីការអនុវត្តន៍បត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។ ដើម្បីបំណងនេះភាគីទទួលសំណើ នឹងជូនពិតមានដល់ភាគីដាក់សំណើពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះ ត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២-ល្គីកណាកថាខ័ណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវ បានចាត់ទុកថា បានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល ១៥ថ្ងៃក្រោយពីកាលបរិច្ឆេទសំរាប់ការអនុវត្តន៍ធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះឱ្យមានសិរីភាពជាបន្ទាន់ ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣-ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយខកខានពុំបានប្រគល់ ឬ ទទួលជនដដែលត្រូវស្នើសុំ ក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀតត្រូវតែបានជូនពិតមានពីបញ្ហានេះ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវសំរេចជាថ្មីម្តងទៀត តាមការពិគ្រោះគ្នាអំពីការអនុវត្តន៍បត្យាប័នម្តងទៀត ហើយបទបញ្ញត្តិនៃកថាខ័ណ្ឌទី ២ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១៣
## ការពន្យាពេលនៃការប្រគល់ខ្លួន និង ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១-នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតនៅក្នុងនីតិវិធីជំនុំជំរះក្តី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បត្យាប័ន ភាគីទទួលសំណើអាច

ប្រគល់ ឬ ពន្យា ការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវផ្តល់ដំណឹងជូនភាគីដាក់សំណើ អំពីការពន្យាពេលនេះ ។

២-យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណីដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាបន័បាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខ័ណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពី ការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិ នៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៤
## សំណើបត្យាបន័ធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយឬច្រើនទៀតផងនោះ ភាគីទទួលសំណើអាចកំណត់ពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ ។

## ប្រការទី ១៥
## វិធានពិសេស

១-ជនដែលត្រូវធ្វើបត្យាបន័ អនុលោមតាមសន្ធិសញ្ញានេះ មិនត្រូវទទួលការឃុំឃាំងទទួលការកាត់ក្តី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងដែនដីភាគីដាក់សំណើសំរាប់បទល្មើសផ្សេងក្រៅពីបទល្មើសដែលបត្យាបន័បានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាប័នបញ្ជូនទៅរដ្ឋផ្សេងទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក-ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាបន័ហើយបាន ត្រឡប់មកដែនដីនេះវិញដោយស្ម័គ្រចិត្ត

ខ-ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលទុកឱ្យជននោះ មានសិទ្ធិចាកចេញ ឬ

គ-ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្ដី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើសដែលបានស្នើសុំឱ្យមានបត្យាប័ន ឬ យល់ព្រមឱ្យមានការធ្វើបត្យាប័នទៅរដ្ឋដទៃផ្សេងទៀត ។ ក្នុងស្ថានភាពនេះ ភាគីទទួលសំណើអាចទាមទារឱ្យផ្ដល់នូវឯកសារ ឬ សេចក្ដីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧ រួមទាំងសេចក្ដីបញ្ជាក់ដែលធ្វើឡើងដោយជនដែលត្រូវធ្វើបត្យាប័ន ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២-បទបញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តិក្រោយការធ្វើបត្យាប័នឡើយ ។

## ប្រការទី ១៦
## ការប្រគល់នូវទ្រព្យសម្បត្តិ

១-ក្នុងក្របខ័ណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្ដល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ :

ក-ដែលអាចតម្រូវឱ្យធ្វើជាភស្តុតាង ឬ

ខ-ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ។

២-ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃប្រការនេះត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខ័ណ្ឌខាងលើទោះបីជាបត្យាប័នដែលត្រូវបានផ្ដល់ឱ្យមិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃជនដែលត្រូវជាប់ចោទ ។

៣-កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើភាគីនេះអាចរក្សាទុកជាបណ្ដោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញក្នុងលក្ខខ័ណ្ឌដែលទ្រព្យសម្បត្តិទាំងនេះ ស្ថិតក្នុងការវង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤-រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួចទោះជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើតាមសំណូមពរនៃភាគីនេះភ្លាមដោយគ្មានបន្ទុកពន្ធ

អាករបន្ទាប់ពីការជំនុំជំរះក្តី ។

## ប្រការទី ១៧
## ដំណើរឆ្លងកាត់

១-នៅពេលដែលជនម្នាក់ត្រូវបានធ្វើបត្យាប័នបញ្ជូនពីរដ្ឋទីបីមកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការអនុញ្ញាតឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាតិបែបនេះ មិនត្រូវទាមទារទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២-ភាគីទទួលសំណើ ត្រូវផ្តល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើដោយភាគីនៃកិច្ចព្រម-ព្រៀងម្ខាងទៀត ល្គិកណាការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៨
## ការផ្តល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើ ឱ្យបានទាន់ពេលវេលានូវដំណឹងដែលពាក់ពន្ធ័ដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៍នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ពាក់ពន្ធ័ដល់ការធ្វើបត្យាប័នបន្ត ចំពោះជនរូបនោះទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៩
## ការឧបត្ថម្ភ និងការចំណាយ

១-ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និង អនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាប័ន ។

២-ចំណាយសំរាប់បត្យាប័ន ជាបន្ទុករបស់ភាគីដែលចំណាយនេះកើតឡើង ។ ចំណាយសំរាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាប័នជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ ។

## ប្រការទី ២០

## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានប៉ះពាល់ដល់សិទ្ធិ និង កាតព្វកិច្ចទាំងឡាយដែលគូភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខ័ណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២១

## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២២

## វិសាលភាពនៃការអនុវត្តន៍

សន្ធិសញ្ញានេះត្រូវអនុវត្តទៅលើគ្រប់បទល្មើសណា ដែលត្រូវបានប្រព្រឹត្តិឡើងក្រោយពីការចូលជាធរមាននៃសន្ធិសញ្ញានេះ ។

## ប្រការទី ២៣

## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងតាមរយៈការពិគ្រោះផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែកមួយ រួមជាមួយនិងកិច្ចព្រមព្រៀងនេះ ។

# ឧបសម្ព័ន្ធទី២

## ប្រការទី ២៤

## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១-សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័នត្រូវប្តូរគ្នានៅភ្នំពេញ ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាប័ន ។

២-ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបាន ដោយផ្តល់ដំណឹងជាលាយល័ក្ខអក្សរទៅភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត ។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមាន រហូតរយៈពេល ៦ខែ ក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្តល់ពត៌មានស្តីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលផ្តើមអនុវត្តមុន ការបញ្ចប់សន្ធិសញ្ញនេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋសាម៉ីរៀងៗខ្លួនបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅវៀងចន្ទ័. ថ្ងៃទី ២១ ខែ តុលា ឆ្នាំ មួយពាន់ប្រាំបួនរយ កៅសិបប្រាំបួន ជាភាសា ខ្មែរ ភាសាឡាវ និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នាអត្ថបទ ជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

តំណាងព្រះរាជាណាចក្រកម្ពុជា

ហោ ណាំហុង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស

និង សហប្រតិបត្តិការអន្តរជាតិ

តំណាងសាធារណរដ្ឋប្រជាធិបតេយ្យ

ប្រជាមានិតឡាវ

ស៊ុមសាវ៉ាត ឡេងសាវ៉ាត

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស

# សន្ធិសញ្ញា
# ស្ដីពី បត្យាប័ន
# រវាង
# ព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ

******************

ព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ [illegible]
ហៅថា "ភាគីចុះកិច្ចព្រមព្រៀង"

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការពីមានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន

បានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការទី ១
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១. ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើស ដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើស ដែលអាចផ្ដន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬ ដោយរូបភាពផ្សេងទៀតនៃការ ឃុំឃាំងសំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្ដន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២. កាលណាមានសំណើបត្យាប័នពាក់ព័ន្ធពលរបុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀតធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើស ដែលអាចធ្វើបត្យាប័នណាមួយ

បត្យាប័នអាចនឹងផ្តល់បានលុះត្រាតែទោសកំណត់ដែលត្រូវទទួលដូចមានចែងក្នុងសាលក្រមនៅសល់យ៉ាងតិចបំផុត ៦ ខែទៀត ។

៣. ក្នុងស្ថានភាពប្រការនេះការកំណត់ថា បទល្មើសណាមួយជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថាអង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬ កំណត់បទល្មើសដោយពាក្យពេចន៍ដូចគ្នានោះដែរឬទេឡើយ ។

៤. កាលណាបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្ថានភាពនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ននេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័នដដែលនេះហើយ ដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើបត្យាប័នលើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំងដែលមានចែងក្នុងកថាខ័ណ្ឌទី១ និង ២ របស់ប្រការនេះ ។

## ប្រការទី ២
## ការកាតព្វកិច្ចត្រូវធ្វើបត្យាប័ន

ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារៈកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្តី ឬ ដើម្បីអោយទទួលទោសឬអនុវត្តន៍ទណ្ឌកម្មតាមទោសកំណត់នៅលើទឹកដីរបស់ភាគីម្ខាង ទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ ។

## ប្រការទី ៣

## មូលដ្ឋាននៃការបដិសេធដាច់ខាត

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតិអោយធ្វើបានឡើយ ក្នុងករណី ណាមួយដូចខាងក្រោមនេះ :

១. ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើជាបទល្មើសនយោបាយ ។ ការយោងទៅលើ បទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូល នូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិក គ្រួសារនៃវរជនទាំងនោះ ។

២. ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និតថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះត្រូវបានគេចាត់ទុកថា បានធ្វើអោយប៉ះពាល់ការសំអាង ដែលពោលខាងលើ ។

៣. បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័នគឺ ជាបទល្មើសចែងដោយច្បាប់អាជ្ញាសឹកសុទ្ធសាធរបស់ភាគីដាក់សំណើ ហើយពុំមែនជាបទល្មើសនៃនីតិព្រហ្មទណ្ឌ របស់ភាគីដាក់សំណើនេះទេ ។

៤. ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះ ដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥. ភាគីទទួលសំណើបានចេញសាលក្រមកាត់ទោសជន ដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦. សាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខ ដោយ ពុំបានផ្តល់ការជូនពត៌មានទាន់ពេលវេលាអំពីសវនាការកាត់ក្តីនេះ និង គ្មានឱកាស សំរាប់ជនជាប់ចោទចាត់ចែងការការពារក្តីរបស់ខ្លួន និង គ្មានឱកាសដើម្បីអោយសំណុំ រឿងក្តីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤

## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បណ្តឹងអាចបដិសេធបានក្នុងករណីណាមួយ ដូចខាង ក្រោមនេះ :

១. យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទ ល្មើសដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនឹងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែល ត្រូវស្នើសុំដោយខ្លួនឯង ។

២. ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះ មានវិសមភាពទៅនឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ទាក់ទងទៅនឹង ចំណាស់ សុខភាព ឬ ស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

៣. ភាគីទទួលសំណើកំពុងតែធ្វើនីតិវិធីជំនុំជំរះក្តីលើជនដែលត្រូវស្នើសុំចំពោះ បទល្មើសដដែលនេះ ។

៤. បុគ្គល ដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោសឬក៏នឹងត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងប្រទេសនៃភាគីដាក់សំណើដោយតុលាការ ឬ សាលាជំរះក្តីពិសេស ឬ បណ្តោះអាសន្នណាមួយ ។ បទបញ្ញត្តិនេះមិនរារាំងដល់ការធ្វើបត្យាប័នណា ដែលកើតឡើងពីយុត្តាធិការផ្នែកឧក្រិដ្ឋកម្មតារបស់តុលាការសឹកអចិន្ត្រៃយ៍ឡើយ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាម៉ី

១. ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗមានសិទ្ធិបដិសេធ ការធ្វើបត្យាប័នពលរដ្ឋផ្ទាល់ របស់ខ្លួន ។

២. ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ ដោយយោងទៅលើកថាខ័ណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារនិងភស្តុតាង ដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះបានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើ ពុំចាំបាច់ត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្តល់ពត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូត វៀរលែងតែមានបទបញ្ញត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧

## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ :

ក. ឯកសារ,សេចក្តីបញ្ជាក់ ឬ ភស្តុតាងផ្សេងទៀតមានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែល ដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ,

ខ. សេចក្តីបញ្ជាក់ លើករណីហេតុនៃបណ្តឹងក្តី,

គ. រាល់បទបញ្ញត្តិនៃច្បាប់ដែលពិពណ៌នាអំពីធាតុសំខាន់ៗនិងការកំណត់នៃបទល្មើស ដែលជាកម្មវត្ថុនៃបត្យាប័ន,

ឃ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តន៍ទណ្ឌកម្ម ចំពោះបទល្មើសប្រសិនបើមាន ។

២. សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំ ដើម្បីចោទប្រកាន់ត្រូវភ្ជាប់ជាមួយផងដែរនូវ :

ក. សេចក្តីចំលងនៃដីការចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ច ផ្សេងទៀតរបស់ភាគីដាក់សំណើ ។

ខ. ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួន ដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជនគោះដោយរាប់បញ្ចូលទាំងភស្តុតាង ដែលបញ្ជាក់ថាជន ដែលត្រូវស្នើសុំពិតជាជន ដែលកំណត់ក្នុងដីការចាប់ខ្លួនមែន ។

៣. ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ កាលណាសំណើបត្យាប័នទាក់ទងទៅនឹងជន ដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់ មកជាមួយនូវ :

ក. សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ,

ខ. ការស្មុតាងបញ្ជាក់ថាជន ដែលត្រូវស្នើសុំពិតជាជន ដែលកំណត់ក្នុងសាលក្រម

គ. សេចក្តីបញ្ជាក់បង្ហាញអំពីកំរិត ដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ចាត់អោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ។

៤. ក្នុងករណីបុគ្គលម្នាក់ បានត្រូវតុលាការសំរេចថាមានទោសកំហុស តែមិនទាន់បាន ឧទ្ធរណ៍សាលក្រមកាត់ទោសនៅឡើយ ជាបន្ថែមលើឯកសារចាំបាច់កំណត់ក្នុងកថាខ័ណ្ឌទី១ និង ៣នៃមាត្រានេះសំណើនេះត្រូវភ្ជាប់មកជាមួយនូវសេចក្តីបញ្ជាក់អំពីបទល្មើសដែលត្រូវបាន ស្នើសុំធ្វើបត្យាប័ន និង ការពិពណ៌នាអំពីសកម្មភាព ឬ អសកម្មភាពដែលជាបទល្មើសនិងសេចក្តីបញ្ជាក់ថាមានបំណង ដាក់ទោសពិតៗ ។

៥. រាល់ឯកសារទាំងអស់ ដែលភាគីដាក់សំណើត្រូវបញ្ជូនអោយក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និងភ្ជាប់មកជាមួយនូវ អត្ថបទបញ្ជាក់ត្រឹមត្រូវជាភាសារអង់គ្លេស ។

## មាត្រាទី ៨
## ពត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថាពត៌មាន ដែលផ្តល់សំរាប់គាំទ្រសំណើបត្យាប័នពុំមានលក្ខណៈគ្រប់គ្រាន់ស្របតាមសន្ធិសញ្ញា ដែលអនុញ្ញាតអោយធ្វើបត្យាប័នបានភាគីនោះ អាចស្នើសុំផ្តល់ពត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនពត៌មានបន្ថែម តាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់

ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

## ប្រការទី ៩
## ការចាប់ខ្លួនបណ្តោះអាសន្ន

១. ក្នុងករណីបន្ទាន់ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្តោះអាសន្ន នូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនដោយលិខិតអក្សរតាមផ្លូវទូត ឬ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល )

២. សំណើសុំខាងលើត្រូវមាន :
- ការពិពណ៌នាអំពីជន ដែលត្រូវស្នើសុំ
- ទីកន្លែងដែលជននោះស្ថិតនៅ ប្រសិនបើដឹង
- សេចក្តីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្តឹងក្តី
- សេចក្តីបញ្ជាក់ថា មានដីការចាប់ខ្លួន ឬ សាលក្រមលើជននោះដូចមានចែងក្នុង ប្រការទី៧ និង
- សេចក្តីបញ្ជាក់ថា សំណើបញ្ជូនលើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនមកតាមក្រោយ ។

៣. ភាគីដាក់សំណើរនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើររបស់ខ្លួនដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបញ្ជូនជាផ្លូវការ និង រាល់ឯកសារសំអាងទាំងឡាយដូចដែលកំណត់ក្នុងប្រការទី៧ ក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជនដែលត្រូវសុំ ។

៥. ការបញ្ចប់នូវការចាប់ខ្លួនបណ្តោះអាសន្ន យោងតាមកថាខណ្ឌទី ៤ នៃប្រការនេះ មិនត្រូវមានផលប៉ះពាល់ដល់ការធ្វើបញ្ជូននូវជន ដែលត្រូវស្នើសុំ

នោះទេ ប្រសិនបើសំណើបញ្ជូន និងរាល់ឯកសារគាំទ្របញ្ជូនដូចមានចែងក្នុងប្រការទី៧ ត្រូវបានផ្ដល់អោយ ក្នុងកាលបរិច្ឆេទក្រោយទៀត ។

## ប្រការទី ១០
## នីតិវិធីបញ្ជូនសាមញ្ញ

ប្រសិនបើបុគ្គលដែលត្រូវបានគេស្នើសុំនោះបានយល់ព្រម ដោយស្ម័គ្រចិត្តជាលាយលក្ខណ៍អក្សរ ក្រោយពីត្រូវបានអាជ្ញាធរមានសមត្ថកិច្ចជំរាបសាម៉ីជននោះ អំពីសិទ្ធរបស់គេក្នុងការទទួលនីតិវិធីបញ្ជូនជាផ្លូវការនិងការការពារពីវិធីនេះ ភាគីទទួលសំណើអាចផ្ដល់បញ្ជូន ដោយមិនចាំបាច់អនុវត្តនីតិវិធីបញ្ជូនជាផ្លូវការ និងក្នុងករណីនេះ [illegible] បញ្ញត្តិនៃប្រការទី១២ ត្រូវយកមកអនុវត្ត [illegible]

## ប្រការទី ១១
## ការសំរេចចិត្តលើសំណើការស្នើ

១. ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបញ្ជូន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន និង ត្រូវជូនពត៌មានយ៉ាងឆាប់រហ័សទៅភាគីដាក់សំណើអំពីសេចក្ដីសំរេចចិត្ត របស់ខ្លួន ។

២. ការបញ្ជាក់ពីមូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយអន្លើណាមួយលើសំណើសុំបញ្ជូននោះត្រូវតែផ្ដល់ជូន ។

## ប្រការទី ១២
## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១. ភាគីទទួលសំណើត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីដាក់សំណើ ពីសេចក្ដីសំរេចរបស់គេទៅលើសំណើដើម្បីធ្វើបញ្ជូនតាមរយៈផ្លូវទូត និង ត្រូវជូនពត៌មានដល់ភាគីដាក់សំណើពីរយៈពេល ដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើ ត្រូវសំរេច អំពីការអនុវត្តន៍បត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។

៣. ល្មើកណាកថាខ័ណ្ឌ៤ នៃប្រការនេះ មិនមានចែងអ្វីផ្ទុយពីនេះ ភាគីដាក់សំណើ ត្រូវបានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួល យកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីកាលបរិច្ឆេទ សំរាប់ អនុវត្តការធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួល សំណើត្រូវដោះលែងជននោះឱ្យមានសេរីភាពជាបន្ទាន់ ហើយអាចបដិសេធការធ្វើ បត្យាប័នចំពោះបទល្មើសដដែលនេះ ។

៤. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយ ពុំបានប្រគល់ ឬ ទទួលជន ដែលត្រូវស្នើសុំក្នុងពេលវេលាដែលបានព្រមព្រៀងគ្នា ១ ដោយករណីប្រធានសក្តិ ភាគីម្ខាងទៀតត្រូវតែបានផ្ទនពត៌មានពីបញ្ហានេះ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវ សំរេចជាថ្មីម្តងទៀត តាមការពិគ្រោះអំពីការអនុវត្តន៍បត្យាប័នម្តងទៀត ហើយបទបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១៣
## ការពន្យារពេលនៃការប្រគល់ខ្លួន និង ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំកំពុងត្រូវស៊ើបក្នុងនីតិវិធីជំនុំជំរះក្តី ឬកំពុងទទួល ទោសក្នុងប្រទេសនៃភាគីទទួលសំណើអំពីបទល្មើសណាមួយផ្សេងពីបទល្មើស ជា កម្មវត្ថុរបស់បត្យាប័នភាគីទទួលសំណើអាចប្រគល់ ឬ ពន្យាការប្រគល់ជននោះ រហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយ ផ្នែកណានៃទោស ដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវ ផ្តល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យាពេលនេះ ។

២. យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណី ដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវ ស្នើសុំជាបណ្តោះអាសន្ន ទៅភាគីដាក់សំណើដើម្បីធ្វើការចោទប្រកាន់ស្របទៅតាម លក្ខខណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបាន

ប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពីការប្រគល់ខ្លួនបណ្ដោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៨
## សំណើបត្យាប់ធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើ ភាគីចុះកិច្ចព្រមព្រៀងម្ខាងទទួលសំណើច្រើនពីភាគីចុះកិច្ចព្រមព្រៀង ២ង រដ្ឋដែលស្នើបញ្ជូន ឬ ច្រើនទៀត ដើម្បីសុំធ្វើបត្យាប់ជនតែមួយ សំរាប់បទល្មើសតែមួយ ឬ ក៏បទល្មើសផ្សេងៗទៀត ភាគីទទួលសំណើត្រូវតែកំណត់ផ្ដល់អាទិភាព ដើម្បីធ្វើបត្យាប័ននៃជននោះជូនដល់រដ្ឋណាមួយ ។ នៅក្នុងការធ្វើសេចក្ដីសំរេចចិត្តរបស់ខ្លួន ភាគីទទួលសំណើត្រូវយកកត្តាដូចខាងក្រោម មកថ្លឹងថ្លែងជាអាទិ :

ក. រដ្ឋដែលបទល្មើសត្រូវបានគេប្រព្រឹត្ត

ខ. ក្នុងករណីពាក់ពន្ធ័បទល្មើសច្រើនខុសៗគ្នា រដ្ឋដែលស្វែងរកបុគ្គលនោះពីបទល្មើសដែលអាចត្រូវផ្ដន្ទាទោសធ្ងន់ជាងគេបំផុត ស្របតាមច្បាប់របស់ភាគីទទួលសំណើ

គ. លំដាប់លំដោយនៃពេលវេលា ដែលភាគីទទួលសំណើបានទទួលសំណើពីភាគីដាក់សំណើទាំងនោះក្នុងករណីដែលពាក់ពន្ធ័ដល់បទល្មើសច្រើនខុសៗគ្នា ហើយដែលភាគីទទួលសំណើបាត់ទុកថាមានកំរិតធ្ងន់ធ្ងរស្មើគ្នា

ឃ. សញ្ជាតិរបស់ជនល្មើស និង

ង. លទ្ធភាពធ្វើបត្យាបន៍បន្តរវាងរដ្ឋដាក់សំណើ ។

## ប្រការទី ១៥
## មិធានពិសេស

១. ជន ដែលត្រូវធ្វើបត្យាបន៍ អនុលោមតាមសន្ធិសញ្ញានេះមិនត្រូវទទួលការឃុំឃាំងទទួលការកាត់ក្តីឬការដាក់ទណ្ឌកម្មនៅក្នុងដែនដីភាគីដាក់សំណើ សំរាប់បទល្មើសផ្សេងក្រៅពីបទល្មើស ដែលបត្យាបន៍បានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាបន៍បញ្ជូនទៅរដ្ឋផ្សេងទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក. ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាបន៍ ហើយបានត្រឡប់មកដែនដីនេះវិញ ដោយស្ម័គ្រចិត្ត

ខ. ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលទុកឱ្យជននោះមានសិទ្ធិចាកចេញ ឬ

គ. ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្តី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើស ដែលបានស្នើសុំឱ្យមានបត្យាបន៍ ឬ យល់ព្រមឱ្យមានការធ្វើបត្យាបន៍ទៅរដ្ឋដទៃផ្សេងទៀត ។ ក្នុងស្មារតីនេះ ភាគីទទួលសំណើអាច ទាមទារឱ្យផ្តល់នូវឯកសារ ឬ សេចក្តីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧រួមទាំងសេចក្តីបញ្ជាក់ដែលធ្វើឡើងដោយជន ដែលត្រូវធ្វើបត្យាបន៍ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២. បទបញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តក្រោយការធ្វើបត្យាបន៍ឡើយ ។

## ប្រការទី ១៦
## ការប្រគល់ជូនទ្រព្យសម្បត្តិ

១. ក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្តល់បត្យាប័នត្រូវប្រគល់ ទ្រព្យសម្បត្តិ:

ក. ដែលអាចតំរូវឱ្យធ្វើជាភស្តុតាង ឬ

ខ. ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ហើយទ្រព្យសម្បត្តិនេះត្រូវបានរកឃើញថាបានកាន់កាប់ដោយជនជាប់ប្តឹង ក្នុងពេល ត្រូវចាប់ខ្លួន ឬ ក៏ ត្រូវគេរកឃើញនាពេលក្រោយបន្ទាប់ទៀត ។

២. ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខណ្ឌខាងលើ ទោះបីជាបញ្ជាបនដែលត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបាន ដោយមូលហេតុមកពីមរណភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃ ជនដែលត្រូវចាប់ខ្លួន ។

៣. កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មវត្ថុនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្ន ទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញក្នុងលក្ខខណ្ឌ ដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤. រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាម្នាក់ មាននៅលើទ្រព្យសម្បត្តិដូចពោលខាងលើ ត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួចរាល់ ក្នុងករណីសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ នៅមាននៅឡើយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើក្នុងកាលដ៏ឆាប់ តាមសំណូមពរនៃភាគីនេះ ដោយគ្មានបន្ទុកពន្ធអាករ ។

## ប្រការទី ១៧
## ដំណើរឆ្លងកាត់

១. នៅពេល ដែលជនម្នាក់ត្រូវបានធ្វើបត្យាប័នពីរដ្ឋទី៣ មកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការអនុញ្ញាតឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាតបែបនេះមិនត្រូវទាមទារទេក្នុងករណី ដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ភាគីទទួលសំណើ ត្រូវផ្ដល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើ ដោយភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ល្គឹកណាការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៨
## ការផ្ដល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើឱ្យបានទាន់ពេលវេលា នូវដំណឹងដែលទាក់ទងដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៍នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ទាក់ទងដល់ការធ្វើបត្យាប័ន្ន ចំពោះជនរូបនោះ ទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៩
## ការឧបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើ ដោយចាត់ចែង និង អនុវត្ត រាល់នីតិវិធីដែលចេញពីសំណើបត្យាប័ន ។

២. រាល់ការចំណាយទាំងឡាយលើដែនដីនៃភាគីទទួលសំណើ ដោយមូលហេតុនៃការធ្វើបត្យាប័ននេះ រហូតដល់ពេលប្រគល់ជនដែលត្រូវធ្វើបត្យាប័ន ត្រូវទទួលរ៉ាប់រងដោយភាគីនេះ ។

## ប្រការទី ២០
## ទំនាក់ទំនងជាមួយនឹងអន្តរសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានផលប៉ះពាល់ដល់សិទ្ធិ និង ភារកិច្ច ទាំងឡាយ ដែលភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២១
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២២
## វិសាលភាពនៃការអនុវត្តន៍

សន្ធិសញ្ញានេះត្រូវអនុវត្តតែលើបទល្មើសណា ដែលត្រូវបានប្រព្រឹត្តឡើងក្រោយ ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ ។

## ប្រការទី ២៣
## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្ម ដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមកនឹង ត្រូវបង្កើតជាផ្នែកមួយរួមជាមួយនឹង កិច្ចព្រមព្រៀងនេះ ។

## ប្រការទី ២៤
## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១.សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័នត្រូវប្តូរគ្នានៅភ្នំពេញ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាប័ន ។

២.ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបានដោយផ្ដល់ដំណឹងជាលាយល័ក្ខអក្សរទៅភាគីនៃកិច្ចកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមានរហូតរយៈពេល៦ខែ ក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្ដល់ព័ត៌មានស្ដីពីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលផ្ដើមអនុវត្តមុនការបញ្ចប់សន្ធិសញ្ញានេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅទីក្រុងបាងកកថ្ងៃទី ៦ ខែឧសភា ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបប្រាំបី ជា ភាសាខ្មែរ ភាសាថៃ និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

| | |
|---|---|
| តំណាងព្រះរាជាណាចក្រកម្ពុជា | តំណាងព្រះរាជាណាចក្រថៃ |
| អ៊ុច គឹមអន | សោរ៉ូជ ចារាវណាបីរ៉ាជ |
| រដ្ឋលេខាធិការ | លេខាធិការអចិន្ត្រៃយ៍ |
| ក្រសួងការបរទេស | ក្រសួងការបរទេស |
| និងសហប្រតិបត្តិការអន្តរជាតិ | |

# ឧបសម្ព័ន្ធទី៣

រដ្ឋសភា
ចុះបញ្ជី លេខ ៤៤១១ ថ្ងៃទី ២៤/៧/ឆ្នាំ២០១៤ ម៉ោង ៩:៣០
បញ្ជូនទៅ ក - ម

ព្រះរាជក្រម

នស/រកម/០៧១៤/០២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខា នៅរដ្ឋធានីហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តសន្ធិសញ្ញានេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស.រកម.១៤០៧.៩០៧ **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ ៩១៤ ស.ណ

**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៤

**អគ្គលេខាធិការ...រដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធទី៤

## សន្ធិសញ្ញា
## ស្តីពី បត្យាប័ន
## រវាង
## ព្រះរាជាណាចក្រកម្ពុជា
## និង
## សាធារណរដ្ឋប្រជាមានិតចិន

*****************

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ដែលតទៅនេះកំណត់ហៅថា "ភាគីចុះកិច្ចព្រមព្រៀង"

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន

បានព្រមព្រៀងគ្នាដូចតទៅ :

### ប្រការទី ១
### កាតព្វកិច្ចត្រូវធ្វើបត្យាប័ន

ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្តី ឬ ដើម្បីអោយទទួលទោស ឬ អនុវត្តន៍ទណ្ឌកម្ម តាមទោសកំណត់នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ ។

## ប្រការទី ២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១.ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២.កាលណាមានសំណើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួលដូចមានចែងក្នុងសាលក្រម នៅសល់យ៉ាងតិចបំផុត ៦ ខែទៀត ។

៣.ក្នុងស្មារតីប្រការនេះ ការកំណត់ថាបទល្មើសណាមួយ ជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថាអង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬ កំណត់បទល្មើសដោយពាក្យពេចន៍ដូចគ្នានោះទេ ។

៤.កាលណាបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្មារតីនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ននេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័នដដែលនេះ ហើយដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើបត្យាប័ន លើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំង ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ និង ២ របស់ប្រការនេះ ។

## ប្រការទី ៣
## មូលដ្ឋាននៃការបដិសេធដាច់ខាត

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតិអោយធ្វើបានឡើយ ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១.ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃរដ្ឋទាំងនោះ ។

២.ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្មតិថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣.បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន តាមច្បាប់របស់ភាគីដាក់សំណើ គឺជាបទល្មើសយោធាសុទ្ធសាធ ។

៤.ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរំងស្ងះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥.ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦.ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ទោសពុំបានទទួលពត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬ គ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬ គ្មានឱកាសដើម្បីអោយសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

១.ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃរដ្ឋទាំងនោះ ។

២.ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្ដឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្ដឹងក្នុងរឿងក្ដីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣.បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន តាមច្បាប់របស់ភាគីដាក់សំណើ គឺជាបទល្មើសយោធាសុទ្ធសាធ ។

៤.ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរំលងផុតដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយរាប់បញ្ចូលទាំងច្បាប់ស្ដីពីអាជ្ញាយុកាល ។

៥.ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦.ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ទោសពុំបានទទួលពត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្ដីនេះ ឬ គ្មានឱកាសចាត់ចែង ការការពារក្ដីរបស់ខ្លួន ឬ គ្មានឱកាសដើម្បីអោយសំណុំរឿងក្ដីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័នអាចបដិសេធបានក្នុងករណីណាមួយ ដូចខាងក្រោមនេះ :

១.យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនឹងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំដោយខ្លួនឯង ។

២.ភាគីទទួលសំណើ កំពុងតែធ្វើនីតិវិធីជំនុំជំរះក្តី លើជនដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះ ។

៣.ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាព នឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

៤.ប្រសិនបើបុគ្គលដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬក៏ និង ត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការ ឬ សាលាជំរះក្តីពិសេស ឬ បណ្តោះអាសន្នណាមួយ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាម្មី

១.ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២.ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ ដោយយោងទៅលើកថាខ័ណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង ភស្តុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះ បានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់ត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្តល់ពត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូតរៀវលែងតែមានបទបញ្ញាត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧
## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ :

ក. ឯកសារ, សេចក្តីបញ្ជាក់ ឬ ភស្តុតាងដទៃទៀត មានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ,

ខ. សេចក្តីបញ្ជាក់ លើកអង្គហេតុនៃបណ្តឹងក្តី,

គ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន,

ឃ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តន៍ទណ្ឌកម្ម ចំពោះបទល្មើសប្រសិនបើមាន ។

២. សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ :

ក. សេចក្តីចំលងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ភាគីដាក់សំណើ ។

ខ. ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន ។

៣. ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ កាលណាសំណើបញ្ជូនបន្តទាក់ទងទៅនឹងជនដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់មកជាមួយនូវ :

ក. សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ,

ខ. ភស្តុតាងបញ្ជាក់ថា ជនដែលត្រូវស្នើសុំ ពិតជាជនដែលកំណត់ក្នុងសាលក្រម,

គ. សេចក្តីបញ្ជាក់បង្ហាញអំពីកំរិតដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ.សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ចាត់អោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ចំពោះករណីដែលជននោះត្រូវបានសំរេចកំបាំងមុខ អោយជាប់ទោស ចំពោះបទល្មើសរបស់គាត់ ។

៤. រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនអោយក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និង ភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬ ជាភាសាអង់គ្លេស ។

## ប្រការទី ៨
## ពត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ពត៌មានដែលផ្តល់សំរាប់គាំទ្រសំណើបញ្ជូនបន្តពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមសន្ធិសញ្ញាដែលអនុញ្ញាតអោយធ្វើបញ្ជូនបន្តបាន ភាគីនោះអាចស្នើសុំផ្តល់ពត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនពត៌មានបន្ថែម តាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

# ប្រការទី ៩

## ការចាប់ខ្លួនបណ្ដោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយល័ក្ខអក្សរតាមផ្លូវទូត ឬ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល )។

២. សំណើសុំខាងលើត្រូវមាន :

- ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ
- ទីកន្លែងដែលជននោះស្ថិតនៅ ប្រសិនបើដឹង
- សេចក្ដីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្ដឹងក្ដី
- សេចក្ដីបញ្ជាក់ថា មានដីកាចាប់ខ្លួន ឬ សាលក្រមលើជននោះ ដូចមានចែងក្នុងប្រការទី៧ និង
- សេចក្ដីបញ្ជាក់ថា សំណើបញ្ជាប័នលើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនមក តាមក្រោយ ។

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបញ្ជាប័នជាផ្លូវការ និង រាល់ឯកសារសំអាងទាំងឡាយដូចដែលកំណត់ក្នុងប្រការទី៧ ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជនដែលត្រូវសុំ ។ កថាខណ្ឌនេះ មិនត្រូវបានរារាំងដល់លទ្ធភាពក្នុងការដោះលែងដោយមានលក្ខខ័ណ្ឌជនដែលត្រូវស្នើសុំមុនផុតរយៈពេល ៦០ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬ ក៏មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬក៏ ក្នុងករណីដែលភាគីដាក់សំណើលុបចោលនូវសំណើបញ្ជាប័នរបស់ខ្លួន។

៥. ការបញ្ចប់នូវការចាប់ខ្លួនបណ្ដោះអាសន្នយោងតាមកថាខ័ណ្ឌ៤នៃប្រការនេះ មិនត្រូវមានផលប៉ះពាល់ដល់ការធ្វើបញ្ជាប័ននូវជនដែលត្រូវស្នើសុំនោះទេប្រសិនបើសំណើបញ្ជាប័ន

និង រាល់ឯកសារគាំទ្របត្យាប័នដូចមានចែងក្នុងប្រការទី៧ ត្រូវបានផ្តល់អោយក្នុងកាលបរិច្ឆេទក្រោយទៀត ។

## ប្រការទី ១០
## ការសំរេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបត្យាប័ន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន នឹងត្រូវជូនពត៌មានយ៉ាងឆាប់រហ័សតាមរយៈផ្លូវទូត ទៅភាគីដាក់សំណើអំពីសេចក្តីសំរេចចិត្តរបស់ខ្លួន ។

២. ការបញ្ជាក់ពីមូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយអន្លើណាមួយលើសំណើសុំបត្យាប័ននោះត្រូវតែផ្តល់ជូន ។

## ប្រការទី ១១
## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើត្រូវសំរេច អំពីការអនុវត្តន៍បត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។ ដើម្បីបំណងនេះភាគីទទួលសំណើ នឹងជូនពត៌មានដល់ភាគីដាក់សំណើពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២. ល្មើកណាកថាខ័ណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះភាគីដាក់សំណើត្រូវ បានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃក្រោយពីកាលបរិច្ឆេទសំរាប់ការអនុវត្តធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងរួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះអោយមានសេរីភាពជាបន្ទាន់ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយខកខានពុំបានប្រគល់ ឬ ទទួលជនដែលត្រូវស្នើសុំ ក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀត

ត្រូវតែបានជូនពត៌មានពីបញ្ហានេះ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវសំរេចជាថ្មីម្តងទៀត តាមការពិគ្រោះគ្នាអំពីការអនុវត្តនីតិបញ្ញត្តិម្តងទៀត ហើយបទបញ្ញត្តិនៃកថាខណ្ឌទី ២ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១២
## ការពន្យារពេលនៃការប្រគល់ខ្លួន និង ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជំរះក្តី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បញ្ញាបន៍ ភាគីទទួលសំណើអាចប្រគល់ ឬ ពន្យារការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវផ្តល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យារពេលនេះ ។

២. យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណីដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពី ការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិ នៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៣
## សំណើបត្យាប័នធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយឬច្រើនទៀតផងនោះ ភាគីទទួលសំណើអាចកំនត់ពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ ។

## ប្រការទី ១៤
## វិធានពិសេស

១. ជនដែលត្រូវធ្វើបត្យាប័ន អនុលោមតាមសន្ធិសញ្ញានេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្តី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងដែនដីភាគីដាក់សំណើសំរាប់បទល្មើសផ្សេង ក្រៅពីបទល្មើសដែលបត្យាប័នបានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាប័នបញ្ជូនទៅរដ្ឋផ្សេងទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក. ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាប័ន ហើយបានត្រឡប់មកដែនដីនេះវិញដោយស្ម័គ្រចិត្ត

ខ. ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលទុកឱ្យជននោះមានសិទ្ធិចាកចេញ ឬ

គ. ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្តី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើសដែលបានស្នើសុំឱ្យមានបត្យាប័ន ឬ យល់ព្រមឱ្យមានការធ្វើបត្យាប័នទៅរដ្ឋដ៏ទៃផ្សេងទៀត ។ ក្នុងស្ថានភាពនេះ ភាគីទទួលសំណើអាចទាមទារឱ្យផ្តល់នូវឯកសារ ឬ សេចក្តីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧ រួមទាំងសេចក្តីបញ្ជាក់ដែលធ្វើឡើងដោយជនដែលត្រូវធ្វើបត្យាប័ន ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២. បទបញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តក្រោយការធ្វើបត្យាប័នឡើយ ។

## ប្រការទី ១៥
## ការប្រគល់ជូនទ្រព្យសម្បត្តិ

១. ក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ:

ក. ដែលអាចតំរូវឱ្យធ្វើជាភស្តុតាង ឬ

ខ. ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ។

២.ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខ័ណ្ឌខាងលើទោះបីជាបត្យាបន៍ដែលត្រូវបានផ្តល់ឱ្យមិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃជនដែលត្រូវជាប់ចោទ ។

៣. កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញ ក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤.រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួចទោះជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើតាមសំណូមពរនៃភាគីនេះភ្លាមដោយគ្មានបន្ទុកពន្ធអាករ បន្ទាប់ពីការជំនុំជំរះក្តី ។

## ប្រការទី ១៦
## ដំណើរឆ្លងកាត់

១. នៅពេលដែលជនម្នាក់ត្រូវបានធ្វើបត្យាបន៍បញ្ជូនពីរដ្ឋទីបីមកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការ

អនុញ្ញាត្តិឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាត្តិបែបនេះ មិនត្រូវទាមទារទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ភាគីទទួលសំណើ ត្រូវផ្តល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើដោយភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត លើកលែងការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៧
## ការផ្តល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើ ឱ្យបានទាន់ពេលវេលានូវដំណឹងដែលពាក់ពន្ធ័ដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៏នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ពាក់ពន្ធ័ដល់ការធ្វើបត្យាបន៍បន្ត ចំពោះជនរូបនោះទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៨
## ការធបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និង អនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាបន៍ ។

២.ចំណាយសំរាប់បត្យាបន៏ ជាបន្ទុករបស់ភាគីដែលចំណាយនេះកើតឡើង ។ ចំណាយសំរាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាបន៍ជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ ។

## ប្រការទី ១៩
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានប៉ះពាល់ផលដល់សិទ្ធិ និង កាតព្វកិច្ចទាំងឡាយដែលភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២០
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២១
## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងតាមរយៈការពិគ្រោះផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែកមួយ រួមជាមួយនឹងកិច្ចព្រមព្រៀងនេះ ។

## ប្រការទី ២២
## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១. សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័នត្រូវប្តូរគ្នានៅភ្នំពេញ ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាប័ន ។

២. ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបាន ដោយផ្ដល់ដំណឹងជាលាយល័ក្ខអក្សរ ទៅភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត ។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមាន រហូតរយៈពេល៦ខែក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្ដល់ពត៌មានស្ដីពីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលផ្ដើមអនុវត្តមុន ការបញ្ចប់សន្ធិសញ្ញានេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋសាម៉ីរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅ ប៉េកាំង ថ្ងៃទី ...០៩... ខែ កុម្ភៈ ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបប្រាំបួន ជាភាសាខ្មែរ ភាសាចិន និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នាអត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

| | |
|---|---|
| តំណាងព្រះរាជាណាចក្រកម្ពុជា | តំណាងសាធារណរដ្ឋប្រជាមានិតចិន |

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ សជណ.កបច

## សេចក្តីថ្លែងហេតុ
## អំពី
## សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

អនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដោយបានឆ្លងកាត់កិច្ចប្រជុំពិនិត្យនិងពិភាក្សាយ៉ាងល្អិតល្អន់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមច្បាប់ជាតិនៃភាគីនីមួយៗនិងតាមច្បាប់អន្តរជាតិ ដែលកិច្ចប្រជុំទាំងនេះបានប្រព្រឹត្តទៅលើកទី១ នៅថ្ងៃទី១០ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ និងលើកទី២ នៅខែមេសា ឆ្នាំ២០១៥ នៅរដ្ឋធានីប៉ារីសនៃសាធារណរដ្ឋបារាំង។ ភាគីទាំងពីរបានឯកភាពគ្នានិងបានចុះហត្ថលេខាជាផ្លូវការលើអនុសញ្ញានេះនៅរដ្ឋធានីប៉ារីសនៃសាធារណរដ្ឋបារាំង នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។

អនុសញ្ញានេះ មានគោលបំណងដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងការប្រឆាំងឧក្រិដ្ឋកម្មដោយគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន រួមមានការជួញដូរមនុស្សពិសេសស្ត្រីនិងកុមារ ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ។

អនុសញ្ញានេះផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍ដល់គូភាគីក្នុងការបង្កើតឱ្យមាននូវក្របខ័ណ្ឌច្បាប់ដើម្បីស្វែងរកជនល្មើសដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអន្តរជាតិក្នុងវិស័យព្រហ្មទណ្ឌ។

អនុសញ្ញាស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងមាន ២៥មាត្រា ដែលមានខ្លឹមសារសង្ខេបសំខាន់ៗដូចខាងក្រោម៖

- មាត្រា១ កំណត់អំពីកាតព្វកិច្ចធ្វើបត្យាប័ន
- មាត្រា២ កំណត់អំពីបទល្មើសដែលអាចធ្វើបត្យាប័នបាន
- មាត្រា៣ កំណត់អំពីមូលហេតុដាច់ខាតនៃការបដិសេធបត្យាប័ន
- មាត្រា៤ កំណត់អំពីមូលហេតុមិនដាច់ខាតនៃការបដិសេធបត្យាប័ន
- មាត្រា៥ កំណត់អំពីទោសប្រហារជីវិត

- មាត្រា៦ កំណត់អំពីការធ្វើបត្យាប័នចំពោះពលរដ្ឋសាមី
- មាត្រា៧ កំណត់អំពីនីតិវិធី
- មាត្រា៨ កំណត់អំពីការបញ្ជូនសំណើនិងឯកសារពាក់ព័ន្ធ
- មាត្រា៩ កំណត់អំពីព័ត៌មានបន្ថែម
- មាត្រា១០ កំណត់អំពីភាសាដែលប្រើប្រាស់និងសុពលភាពនៃឯកសារ
- មាត្រា១១ កំណត់អំពីសេចក្ដីសម្រេចនិងការប្រគល់ខ្លួន
- មាត្រា១២ កំណត់អំពីការលើកពេលនៃការប្រគល់ខ្លួននិងការប្រគល់ខ្លួនជាបណ្ដោះអាសន្ន
- មាត្រា១៣ កំណត់អំពីការប្រគល់វត្ថុ
- មាត្រា១៤ កំណត់អំពីវិធានពិសេស
- មាត្រា១៥ កំណត់អំពីការធ្វើបត្យាប័នបន្តទៅរដ្ឋទីបី
- មាត្រា១៦ កំណត់អំពីការយល់ព្រមរបស់បុគ្គលដែលត្រូវបានស្នើសុំធ្វើបត្យាប័ន
- មាត្រា១៧ កំណត់អំពីការចាប់ខ្លួនជាបណ្ដោះអាសន្ន
- មាត្រា១៨ កំណត់អំពីការជូនដំណឹងអំពីលទ្ធផល
- មាត្រា១៩ កំណត់អំពីការឆ្លងកាត់
- មាត្រា២០ កំណត់អំពីករណីពាក្យស្នើសុំបត្យាប័នច្រើនលើបុគ្គលតែម្នាក់
- មាត្រា២១ កំណត់អំពីការចំណាយ
- មាត្រា២២ កំណត់អំពីទំនាក់ទំនងជាមួយសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត
- មាត្រា២៣ កំណត់អំពីការដោះស្រាយវិវាទ
- មាត្រា២៤ កំណត់អំពីការអនុវត្តអនុសញ្ញានៅក្នុងកាល
- មាត្រា២៥ កំណត់អំពីការចូលជាធរមាននិងការបញ្ចប់អនុសញ្ញា។

សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន២មាត្រា។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តលើសេចក្ដីព្រាងច្បាប់នេះដោយក្ដីអនុគ្រោះ។

ថ្ងៃ សុក្រ ១០ រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ឧបសម្ព័ន្ធទី៦

## កិច្ចព្រមព្រៀង

## ស្តីពី បត្យាប័ន

## រវាង

## រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## និង

## រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ (ដែលអំណើះតទៅហៅថា "ភូភាគី")

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការលុបបំបាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសងខាង តាមការចុះកិច្ចព្រមព្រៀងស្តីពីបត្យាប័ន ។

បានព្រមព្រៀងគ្នាដូចតទៅ:

### មាត្រា ១
### ភាតព្វកិច្ចធ្វើបត្យាប័ន

ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀត នូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើទឹកដីនៃភាគីណាមួយ ហើយដែលកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ធ្វើការជំនុំជំរះក្តី ឬអនុវត្តន៍ទណ្ឌកម្ម តាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសណាមួយដែលអាចធ្វើបត្យាប័នបាន។

## មាត្រា ២

## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១. ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់ជាធរមានរបស់ភាគីទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សម្រាប់រយៈពេលយ៉ាងតិច ២ ឆ្នាំ ឬការផ្តន្ទាទោសដែលធ្ងន់ជាងនេះ ។

២. កាលណាមានសំណើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ដោយតុលាការរបស់ភាគីដាក់សំណើ ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួល ដូចមានចែងក្នុងសាលក្រមនៅសល់យ៉ាងតិចបំផុត ៦ ខែទៀត។

៣. ក្នុងស្មារតីនៃមាត្រានេះ ការកំណត់ថា បទល្មើសណាមួយជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថា អង្គច្បាប់នៃភាគី ចាត់ទុកជាអំពើ ឬការខកខាន ដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬកំណត់បទល្មើសដោយប្រើពាក្យពេចន៍ដូចគ្នានោះទេ ។

៤. ប្រសិនបើសំណើសុំបត្យាប័ននេះ យោងលើបទល្មើសជាច្រើនដាច់ដោយឡែកពីគ្នា ដែលបទល្មើសនីមួយៗគឺជាបទល្មើស ដែលអាចផ្តន្ទាទោសតាមច្បាប់ជាធរមានរបស់ភាគីទាំងពីរ ប៉ុន្តែបទល្មើសមួយចំនួនមិនបានបំពេញទៅនឹងលក្ខខ័ណ្ឌផ្សេងទៀត ដូចបានចែងនៅក្នុងកថាខណ្ឌ ១ និង ២ នៃមាត្រានេះ បត្យាប័នអាចនឹងត្រូវបានផ្តល់អោយចំពោះបទល្មើសក្រោយៗ ដរាបណាបុគ្គលនោះត្រូវបានធ្វើបត្យាប័ន យ៉ាងហោចណាស់ចំពោះបទល្មើសមួយដែលអាចធ្វើបត្យាប័នបាន។

៥. ក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្ត នៅក្រៅដែនដីនៃភាគីដាក់សំណើ បត្យាប័ននឹងត្រូវបានផ្តល់អោយ ក្នុងករណីដែលច្បាប់របស់ភាគីទទួលសំណើចែងអំពីការផ្តន្ទាទោសនៃបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីនៅក្នុងកាលទេសៈស្រដៀងគ្នា។ ករណីដែលច្បាប់នៃភាគីទទួលសំណើមិនមានចែងដូច្នេះ ភាគីទទួលសំណើអាចផ្តល់បត្យាប័ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

## មាត្រា ៣
## មូលដ្ឋានចំបាច់សំរាប់ធ្វើការបដិសេធ

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ បត្យាប័នមិនត្រូវអនុញ្ញាតអោយផ្តល់បានឡើយ ក្នុងករណីមួយចំនួនដូចខាងក្រោម:

១. ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវបទល្មើសមួយចំនួន ដូចខាងក្រោមនេះ:

(ក) ការធ្វើឃាត ឬ ការប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវរៈជនទាំងនោះ។

(ខ) ជាបទល្មើសមួយ ដែលភាគីមានកាតព្វកិច្ចបង្កើតយុត្តាធិការ ឬ ធ្វើបត្យាប័ន ដោយមូលហេតុកិច្ចព្រមព្រៀងអន្តរជាតិពហុភាគីដែលភាគីទាំងពីរជាភាគី រួមបញ្ចូលទាំងប៉ុន្តែមិនកំណត់ ចំពោះកិច្ចព្រមព្រៀងទាក់ទងនឹងបទប្រល័យពូជសាសន៍ ភេរវកម្ម ឬ ការចាប់ចំណាប់ខ្មាំង ។

២. ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថា សំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬអនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុ ពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬក៏គំនិតនយោបាយ ឬថា ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ នឹងត្រូវបានធ្វើអោយប៉ះពាល់ដោយសារហេតុផលពោលខាងលើ។

៣. បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន ត្រូវបានធ្វើឡើង ដោយមិនរួមបញ្ចូលចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់យោធារបស់ភាគីដាក់សំណើ ដែលមិនមែនជាបទល្មើសដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌធម្មតាឡើយ ។

៤. ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្ម ចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីនីមួយៗណាមួយ រាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល។

៥. ភាគីទទួលសំណើបានកាត់ទោស និង ផ្តន្ទាទោស ឬលើកលែងការចោទប្រកាន់លើបុគ្គលដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន។

៦. ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខ ជនជាប់ទោសពុំបាន ទទួលព័ត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬគ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬ គ្មានឱកាសដើម្បី អោយសំណុំរឿងក្តីរបស់ខ្លួនត្រូវបានជំនុំជំរះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន ។

## មាត្រា ៤

## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ បត្យាប័នអាចបដិសេធបាន ក្នុងករណីដូចខាងក្រោមនេះ :

១. យោងតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុនៃសំណើ បត្យាប័ន។ ក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ ត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំ ធ្វើបត្យាប័ន។

២. ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍របស់ភាគីដាក់ សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមាននិសមិតភាពទៅនឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ។

៣. ភាគីទទួលសំណើ កំពុងដំណើការរៀបចំនីតិវិធីជំនុំជំរះជន ដែលត្រូវស្នើសុំបត្យាប័ន ចំពោះបទល្មើស ដូចគ្នា។

៤. ប្រសិនបើបុគ្គលដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬក៏នឹងត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការពិសេសឬ សាលាជំរះក្តី ។

៥. ប្រសិនបើបុគ្គលដែលត្រូវស្នើសុំធ្វើបត្យាប័ន ត្រូវបានដោះលែងជាស្ថាពរ ឬ កាត់ទោសនៅក្នុងរដ្ឋទី ៣ ចំពោះបទល្មើសដូចគ្នាដែលបត្យាប័នត្រូវបានស្នើឡើង និង ប្រសិនបើត្រូវបានកាត់ទោស ទោសដែលត្រូវបានដាក់ ត្រូវបានអនុវត្តន៍ពេញលេញ ឬលែងអនុវត្តន៍ទៀតហើយ ។

## មាត្រា ៥

## ការធ្វើបត្យាប័នចំពោះពលរដ្ឋសាម៉ី

១. ភាគីនីមួយៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២. ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ អនុលោមតាមកថាខណ្ឌ ១ នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង ភស្តុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះ ទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខណ្ឌ ២ នៃមាត្រានេះបានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់បញ្ជូនបណ្តឹងក្តីនេះ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

៤. សញ្ជាតិត្រូវកំណត់នៅពេលដែលប្រព្រឹត្តបទល្មើស នៅពេលដែលបត្យាប័នត្រូវបានស្នើ ។

## មាត្រា ៦

## វិធីផ្តល់ព័ត៌មាន

ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ គូភាគីត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នា តាមរយៈផ្លូវទូត វៀរលែងតែមានបទប្បញ្ញាតិផ្សេងចែងក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៧

## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវភ្ជាប់មកជាមួយនូវៈ

ក. ឯកសារ សេចក្តីបញ្ជាក់ ឬ ព័ត៌មានផ្សេងទៀត ដែលពិពណ៌នាអំពីអត្តសញ្ញាណ ប្រសិនបើមាន រួមបញ្ចូលទាំង ការពិពណ៌នាអំពីប្រវត្តិសង្ខេប រូបថត និង ឬ ស្នាមមេដៃ សញ្ជាតិ និងទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនដែលត្រូវស្នើសុំ។

ខ. សេចក្តីបញ្ជាក់លើអង្គហេតុនៃបណ្តឹងក្តី រួមបញ្ចូលទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តបទល្មើស និងប្រវត្តិនីតិវិធីនៃបណ្តឹងក្តី ។

គ. សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីធាតុផ្សំសំខាន់ៗ និង ការកំណត់នៃបទល្មើស

ឃ. សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើស

ង. សេចក្តីបញ្ជាក់អំពីច្បាប់ ដែលទាក់ទងនឹងការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្តទណ្ឌកម្មចំពោះបទល្មើស និង

ច. ឯកសារ សេចក្តីបញ្ជាក់ ឬ ព័ត៌មានផ្សេងទៀតដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ ២ ឬ ៣ នៃមាត្រានេះ ប្រសិនបើមាន។

២. សំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវស្នើសុំ ដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ:

ក. សេចក្តីចម្លងនៃដីកាចាប់ខ្លួន ឬ ដីកាឃុំខ្លួន ចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចតុលាការដទៃទៀត របស់ភាគីដាក់សំណើ

ខ. ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើសុំបត្យាប័ន គឺជាបុគ្គលដែលមានដីការចាប់ខ្លួន ឬ ដីកាឃុំខ្លួន និង

គ. សេចក្តីបញ្ជាក់នៃអំពើ ឬការខកខាន ដែលបានចោទប្រកាន់ បង្កើតបានជាបទល្មើស និងភស្តុតាងគាំទ្រ ដែលអាចផ្តល់នូវមូលដ្ឋានត្រឹមត្រូវ គួរអោយសង្ស័យថា បុគ្គលដែលត្រូវធ្វើបត្យាប័នបានប្រព្រឹត្តបទល្មើសដែលបត្យាប័នត្រូវបានស្នើឡើង។

៣. កាលណាសំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវបានរកឃើញនូវពិរុទ្ធ សំណើនេះក៏ត្រូវភ្ជាប់មកជាមួយផងដែរនូវ:

ក. សេចក្តីចម្លងសាលក្រមចេញដោយតុលាការនៃភាគីដាក់សំណើ ដែលកំណត់អំពីការកាត់ទោស និងទោសដែលបានដាក់ អង្គហេតុដែលទោសអាចអនុវត្តបាន និង បរិបទដែលទោសនៅមិនទាន់ទទួល។

ខ. សេចក្តីចម្លងនៃដីកាចាប់ខ្លួន ឬ សេចក្តីបញ្ជាក់ថា បុគ្គលជាកម្មវត្ថុនៃការឃុំខ្លួន ផ្អែកលើមូលដ្ឋាននៃសាលក្រមកាត់ទោស

គ. ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើបត្យាប័ន គឺជាបុគ្គលដែលមានពិរុទ្ធ

ឃ. សេចក្តីបញ្ជាក់នៃអំពើ ឬការខកខានដែលអាចបង្កើតបានជាបទល្មើស ដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធ

ង. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលកើតមានចំពោះបុគ្គល ដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ចាត់អោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ប្រសិនបើបុគ្គលត្រូវផ្តន្ទាទោសចំពោះបទល្មើសណាមួយ ពុំមានវត្តមាន។

៤. រាល់ឯកសារទាំងឡាយដែលភាគីដាក់សំណើបញ្ជូនមក អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និងភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេស។

## មាត្រា ៨
## ព័ត៌មានបន្ថែម

១. ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ព័ត៌មានដែលផ្តល់ជូនសំរាប់គាំទ្រសំណើបត្យាប័ន ពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀង សំរាប់ផ្តល់ការយល់ព្រមលើបត្យាប័ន ភាគីនោះអាចស្នើសុំផ្តល់ព័ត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនព័ត៌មានបន្ថែមតាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ដោយស្ម័គ្រចិត្ត។ ប៉ុន្តែភាគីដាក់សំណើមិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ។

២. ក្នុងករណីដែលបុគ្គលនោះត្រូវបានគេដោះលែងពីការឃុំគ្រង យោងតាមកថាខណ្ឌ ១ នៃមាត្រានេះ ភាគីទទួលសំណើត្រូវតែជូនដំណឹងដល់ភាគីដាក់សំណើ កាន់តែឆាប់កាន់តែប្រសើរ។

## មាត្រា ៩
## ការចាប់ខ្លួនបណ្ដោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីមួយអាចស្នើទៅភាគីម្ខាងទៀត អោយធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវបុគ្គល ដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយល័ក្ខអក្សរតាមផ្លូវទូត ។

២. សំណើសុំចាប់ខ្លួនបណ្ដោះអាសន្ន ត្រូវធ្វើជាលាយល័ក្ខអក្សរ និងមាន:

(ក) ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ រួមទាំងព័ត៌មានអំពីសញ្ជាតិនៃបុគ្គលនោះ

(ខ) សេចក្ដីបញ្ជាក់អំពីទីកន្លែង ដែលជននោះស្ថិតនៅ ប្រសិនបើដឹង

(គ) សេចក្ដីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្ដឹងក្ដី ប្រសិនបើមាន ពេលពេល និង ទីកន្លែង ប្រព្រឹត្តបទល្មើស

(ឃ) ការពិពណ៌នាអំពីច្បាប់ដែលបានរំលោភ

(ង) សេចក្ដីបញ្ជាក់ថា មានដីកាចាប់ខ្លួន ឬ សាលក្រមនៃការកាត់ទោសលើជននោះ និង

(ច) សេចក្ដីបញ្ជាក់អំពីសំណើបត្យាប័នលើជនដែលត្រូវស្នើសុំ នឹងត្រូវបញ្ជូនតាមក្រោយ

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបត្យាប័នជាផ្លូវការ និងឯកសារសំអាងនានា ដូចដែលកំណត់ក្នុងមាត្រា ៧ ក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជននោះ ។ កថាខណ្ឌនោះ មិនត្រូវរាំងលទ្ធភាពនៃការដោះលែង ដោយមានលក្ខខណ្ឌ នូវជន ដែលត្រូវស្នើសុំ មុនផុតរយៈពេល ៦០ ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬ ក៏មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬប្រសិនបើភាគីដាក់សំណើលុបចោលនូវសំណើបត្យាប័នរបស់ខ្លួន ។

៥. ការដោះលែងជនដែលស្នើសុំពីការឃុំគ្រង អនុលោមតាមកថាខណ្ឌ ៤ នៃមាត្រានេះ មិនត្រូវធ្វើឱ្យ ផលប៉ះពាល់ដល់ការចាប់ខ្លួនឡើងជាបន្តបន្ទាប់ និងការធ្វើបត្យាប័នជននោះទេ ប្រសិនបើសំណើបត្យាប័ន និងរាល់ ឯកសារសំអាងនានា ត្រូវបានផ្ដល់ជូននាពេលក្រោយ ។

## មាត្រា ១០

## ភាពងាយស្រួលក្នុងការធ្វើបត្យាប័ន

នៅពេលដែលបុគ្គលដែលស្នើសុំបត្យាប័នប្រាប់តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃភាគីទទួលសំណើ ថាបុគ្គលនោះយល់ព្រមឱ្យមានការធ្វើបត្យាប័ន ដែលកំពុងស្នើឡើង ភាគីទទួលសំណើអាចចាត់វិធានការណ៍ចាំបាច់នានា ដើម្បីពន្លឿនការធ្វើបត្យាប័ន ក្នុងកម្រិតដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ ។

## មាត្រា ១១

## ការសំរេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវពិនិត្យសំណើសុំបត្យាប័ន ស្របតាមនីតិវិធដែលច្បាប់របស់ខ្លួនកំណត់ឱ្យ និងត្រូវផ្តល់សេចក្តីសំរេចរបស់ខ្លួនទៅភាគីដាក់សំណើ ។

២. មូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយអន្លើណាមួយ លើសំណើសុំបត្យាប័ននោះ ត្រូវតែផ្តល់ជូន ។

## មាត្រា ១២

## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់អោយ ភាគីទទួលសំណើ និងភាគីដាក់សំណើ ត្រូវសំរេចអំពីការអនុវត្តន៍បត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា។ សំរាប់គោលបំណងនេះ ភាគីទទួលសំណើត្រូវជូនព័ត៌មានដល់ភាគីដាក់សំណើ អំពីរយៈពេល ដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំង មុនពេលប្រគល់ខ្លួន ។

២. លើកលែងតែករណីខណ្ឌ ៣ នៃមាត្រានេះមិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវបានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល ១៥ ថ្ងៃក្រោយពីថ្ងៃដែលការអនុវត្តន៍បត្យាប័នត្រូវបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះ អោយមានសេរីភាពជាបន្ទាន់ ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣. ប្រសិនបើភាគីណាមួយខកខានពុំបានប្រគល់ ឬទទួលយកជនដែលត្រូវស្នើសុំ ក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិ ភាគីម្ខាងទៀតត្រូវបានគេជូនដំណឹងពីបញ្ហានេះ។ គូភាគីត្រូវសំរេចជាថ្មីម្តងទៀត តាមការពិគ្រោះយោបល់គ្នា អំពីការអនុវត្តន៍បត្យាប័ន ហើយបទប្បញ្ញត្តិនៃកថាខណ្ឌ ២ នៃ មាត្រានេះនឹងត្រូវអនុវត្ត។

## មាត្រា ១៣
## ការពន្យារពេលនៃការប្រគល់ខ្លួន ឬ ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជំរះក្តី ឬ កំពុងទទួលទោសក្នុងទឹកដីនៃភាគីទទួលសំណើ ចំពោះបទល្មើសណាមួយផ្សេងពីបទល្មើសដែលជាកម្មវត្ថុបត្យាប័ន ភាគីទទួលសំណើអាចប្រគល់ ឬពន្យារការប្រគល់ជននោះ រហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវជូនដំណឹងទៅភាគីដាក់សំណើ អំពីការពន្យារពេលនេះ។

២. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ នៅពេលដែលជនម្នាក់ត្រូវបានរកឃើញថា អាចធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្ន ទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ ស្របទៅតាមលក្ខខ័ណ្ឌដែលបានកំណត់រវាងគូភាគី។ ជនណាម្នាក់ ដែលត្រូវបានប្រគល់ទៅភាគីទទួលសំណើ បន្ទាប់ពីការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ ស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៤
## សំណើបត្យាប័នធ្វើឡើងដោយរដ្ឋច្រើន

១. ក្នុងករណីដែលសំណើត្រូវបានទទួលពីរដ្ឋពីរ ឬច្រើន រួមទាំងភាគីដទៃទៀត សំរាប់ការធ្វើបត្យាប័នបុគ្គលដដែល ទោះបីជាបទល្មើសដូចគ្នាក្តី ឬ ខុសគ្នាក្តី ភាគីទទួលសំណើត្រូវកំណត់ថាតើត្រូវធ្វើបត្យាប័នបុគ្គលនោះទៅឱ្យរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះ ហើយត្រូវតែជូនដំណឹងទៅរដ្ឋទាំងនោះពីការសំរេចចិត្តរបស់ខ្លួន ។

២. ការកំណត់រដ្ឋណាមួយដែលបុគ្គលនោះត្រូវធ្វើបត្យាប័ន រដ្ឋទទួលសំណើត្រូវពិចារណាលើកត្តាពាក់ព័ន្ធទាំងអស់ រួមមានជាអាទិ៍ :

(ក) សញ្ជាតិ និង ទីលំនៅរបស់ជនដែលត្រូវធ្វើបត្យាប័ន

(ខ) សំណើធ្វើឡើងថាតើស្របតាមកិច្ចព្រមព្រៀងឬទេ

(គ) ពេលវេលា និង ទីកន្លែងនៃការប្រព្រឹត្តបទល្មើសនីមួយៗ

(ឃ) ផលប្រយោជន៍ដាច់ដោយឡែករបស់រដ្ឋដាក់សំណើ

(ង) ស្ថានទំនង់ទោស

(ច) សញ្ជាតិនៃជនរងគ្រោះ

(ឆ) លទ្ធភាពនៃការធ្វើបត្យាប័នបន្ថែមទៀតរវាងភាគីដាក់សំណើនានា និង

(ជ) កាលបរិច្ឆេទខុសគ្នានៃសំណើ ។

## មាត្រា ១៥
## វិធានពិសេស

១. បុគ្គលដែលត្រូវធ្វើបត្យាប័ន អនុលោមតាមកិច្ចព្រមព្រៀងនេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្តី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងទឹកដីនៃភាគីដាក់សំណើ សំរាប់បទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលបត្យាប័នត្រូវបានផ្តល់ជូន វៀរលែងតែភាគីទទួលសំណើយល់ព្រមឱ្យមានការឃុំខ្លួនបុគ្គល ការកាត់ទោស ឬ ការផ្តន្ទាទោស ។ សម្រាប់ការយល់ព្រមនេះមានយោងក្នុងកថាខណ្ឌនេះ :

ក. ភាគីទទួលសំណើអាចតំរូវអោយដាក់ជូនឯកសារដែលមានចែងក្នុងមាត្រា ៧

ខ. សេចក្តីបញ្ជាក់ដែលធ្វើឡើងដោយបុគ្គល ដែលត្រូវធ្វើបត្យាប័ន ទាក់ទងនឹងបទល្មើស ប្រសិនបើមាន ត្រូវដាក់ជូនទៅភាគីទទួលសំណើ និង

គ. បុគ្គលដែលត្រូវធ្វើបត្យាប័នអាចត្រូវបានឃុំខ្លួន ដោយភាគីដាក់សំណើ សំរាប់រយៈពេល ដូចដែលភាគីទទួលសំណើអាចអនុញ្ញាតឱ្យ ខណៈពេលដែលសំណើសុំការព្រមព្រៀងយោងមាត្រានេះ កំពុងតែដំណើរការ ។

២. បុគ្គលដែលត្រូវធ្វើបត្យាប័ន ក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវបានធ្វើបត្យាប័នឡើងវិញ ដោយភាគីដាក់សំណើទៅរដ្ឋទី ៣ សំរាប់បទល្មើសដែលបានប្រព្រឹត្ត មុនពេលធ្វើបត្យាប័នជននោះទេ វៀរលែងតែភាគីទទួលសំណើយល់ព្រម ។

៣. បុគ្គលដែលត្រូវធ្វើបត្យាប័ន ក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវបានឃុំខ្លួន មិនត្រូវបានកាត់ទោស និង មិនត្រូវបានផ្តន្ទាទោស នៅក្នុងភាគីដាក់សំណើ សំរាប់បទល្មើសណាមួយក្រៅពីបទល្មើសដែលបត្យាប័នត្រូវបាន យល់ព្រម ហើយមិនត្រូវបានធ្វើបត្យាប័នឡើងវិញទៅរដ្ឋទី ៣ វៀរលែងតែបុគ្គលដែលត្រូវធ្វើបត្យាប័ន :

(ក) បានវិលត្រឡប់មកដែនដីភាគីដាក់សំណើដោយស្ម័គ្រចិត្ត បន្ទាប់ពីបានចាកចេញ ឬ

(ខ) មិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងអំឡុងពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃដែលបុគ្គលនោះ ត្រូវបានផ្តល់សិទ្ធិឱ្យចាកចេញ លើកលែងតែនៅក្រោមលក្ខខ័ណ្ឌហួសពីការត្រួតពិនិត្យរបស់ខ្លួន។

៤. បទប្បញ្ញត្តិទាំងនេះមិនត្រូវអនុវត្តទេ ចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្ត ក្រោយការធ្វើ បត្យាប័ន។

## មាត្រា ១៦
## ការប្រគល់ទ្រព្យសម្បត្តិ

១. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ និងយោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួល សំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និងក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ:

(ក) ដែលអាចតម្រូវអោយធ្វើជាភស្តុតាង ឬ

(ខ) ដែលត្រូវបានទទួល ដោយសារលទ្ធផលនៃបទល្មើស។

២. ទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវប្រគល់ជូន ទោះបីការធ្វើបត្យាប័នដែល ត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបាន ដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬការគេចខ្លួននៃជនដែលត្រូវ ជាប់ចោទ។

៣. កាលណាទ្រព្យសម្បត្តិខាងលើនេះ ជាកម្មវត្ថុនៃការដកហូត ឬរឹបអូសនៅក្នុងទឹកដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬបញ្ជូនត្រឡប់ទៅវិញ ក្នុងលក្ខខ័ណ្ឌដែលទ្រព្យសម្បត្តិ ទាំងនោះស្ថិតក្នុងការវង់ចាំនីតិវិធីព្រហ្មទណ្ឌ។

៤. រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើនៃរដ្ឋណាមួយ ឬ បុគ្គលណាមួយ អាចទទួលបានលើ ទ្រព្យសម្បត្តិ ដូចពេលខាងលើ ត្រូវរក្សាទុក។ នៅពេលសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះអស់មានហើយ ទ្រព្យសម្បត្តិ

ទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើ តាមសំណូមពររបស់ខ្លួន ដោយគ្មានបន្ទុកពន្ធអាករ ឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន បន្ទាប់ពីការជំនុំជំរះក្តី។

## មាត្រា ១៧
## ដំណើរឆ្លងកាត់

១. ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ ការដឹកជញ្ជូនបុគ្គលដែលត្រូវបត្យាប័ន ពីរដ្ឋទី ៣ ទៅកាន់ភាគីណាមួយ ឆ្លងកាត់ទឹកដីនៃភាគីផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យ ទៅតាមសំណើជាលាយលក្ខណ៍អក្សរធ្វើឡើងតាមរយៈផ្លូវទូត។ សំណើនេះត្រូវពិពណ៌នាអំពីបុគ្គលដែលត្រូវបានដឹកជញ្ជូន រួមបញ្ចូលទាំងសញ្ជាតិរបស់គេ និងសេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុនៃបណ្តឹងក្តី។ បុគ្គលដែលត្រូវឆ្លងកាត់ អាចត្រូវបានឃុំគ្រង ក្នុងអំឡុងពេលធ្វើដំណើរឆ្លងកាត់។

២. ការអនុញ្ញាតឱ្យឆ្លងកាត់ មិនតម្រូវឱ្យមានទេ ក្នុងករណីដែលការដឹកជញ្ជូនតាមផ្លូវអាកាស គ្មានការចុះចតគ្រោងទុកជាមុន នៅលើទឹកដីរបស់ភាគីដែលត្រូវគេឆ្លងកាត់។ ប្រសិនបើការចុះចត ដែលមិនបានគ្រោងទុកជាមុនកើតមានឡើងនៅលើទឹកដីនៃភាគីនោះ រដ្ឋនោះអាចតម្រូវឱ្យភាគីផ្សេងទៀត ផ្តល់នូវសំណើសុំការឆ្លងកាត់ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។ ភាគីដែលត្រូវគេឆ្លងកាត់ ត្រូវធ្វើការឃុំខ្លួនបុគ្គលដែលបានដឹកជញ្ជូន រហូតដល់ការដឹកជញ្ជូនត្រូវធ្វើបន្ត ប្រសិនបើទទួលបានសំណើ ក្នុងរយៈពេល ៩៦ ម៉ោង ចំពោះការចុះចតដែលមិនបានគ្រោងទុកជាមុន។

៣. ការអនុញ្ញាតឱ្យឆ្លងកាត់ ត្រូវរួមបញ្ចូលទាំងការអនុញ្ញាតឱ្យមន្ត្រីអមដំណើរ ទទួលបានកិច្ចឧបត្ថម្ភពីអាជ្ញាធរនៃភាគីដែលត្រូវគេឆ្លងកាត់ ក្នុងការថែរក្សាការឃុំគ្រង។

## មាត្រា ១៨
## ការជូនដំណឹងអំពីលទ្ធផល

ភាគីដាក់សំណើត្រូវជូនដំណឹងទៅភាគីទទួលសំណើ ឱ្យទាន់ពេលវេលា នូវព័ត៌មានទាក់ទងនឹងការចោទប្រកាន់ ការជំនុំជំរះ និងការអនុវត្តន៍នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬការធ្វើបត្យាប័នឡើងវិញនូវជននោះ ទៅរដ្ឋទី ៣។

## មាត្រា ១៩
## ការខូបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើ និងចាត់ចែង ព្រមទាំងអនុវត្តរាល់នីតិវិធី ដែលកើតឡើងពីសំណើបត្យាប័ន ។

២. ភាគីទទួលសំណើត្រូវចេញសោហ៊ុយនៃដំណើរការនីតិវិធីណាមួយ នៅក្នុងយុត្តាធិការរបស់ខ្លួន ដែលកើតឡើងពីសំណើបត្យាប័ន ។ ភាគីទទួលសំណើ ត្រូវចេញសោហ៊ុយដែលកើតឡើងនៅក្នុងទឹកដីរបស់ខ្លួន ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួននៃជនដែលស្នើសុំបត្យាប័ន ឬ ការដកហូត និង ការប្រគល់ទ្រព្យសម្បត្តិ ។

៣. ភាគីដាក់សំណើត្រូវចេញសោហ៊ុយដែលកើតឡើងពីការដឹកជញ្ជូនបុគ្គល ដែលបត្យាប័នត្រូវផ្តល់ជូនពីទឹកដីនៃភាគីទទួលសំណើ រួមទាំងសោហ៊ុយធ្វើដំណើរឆ្លងកាត់ ។

## មាត្រា ២០
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

កិច្ចព្រមព្រៀងនេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដែលគូភាគីទទួលបាន និងគោរពក្រោមអនុសញ្ញាពហុភាគីណាមួយឡើយ ។

## មាត្រា ២១
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## មាត្រា ២២
## ការធ្វើវិសោធនកម្ម

កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីណាមួយ ។ រាល់វិសោធនកម្ម ដែលបានយល់ព្រមដោយគូភាគី តាមរយៈផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែករួមមួយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២៣
## ការចូលជាធរមាន និង ការបញ្ចប់កិច្ចព្រមព្រៀង

១. កិច្ចព្រមព្យៀងនេះចូលជាធរមាន ៣០ ថ្ងៃបន្ទាប់ពីថ្ងៃដែលគូភាគីបានជូនដំណឹងឱ្យគ្នាទៅវិញទៅមកជាលាយលក្ខ័អក្សរថា ខ្លួនបានបំពេញបែបបទផ្លូវច្បាប់ផ្ទៃក្នុងចប់សព្វគ្រប់ហើយ សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្យៀងនេះ ។

២. កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះសំណើដែលធ្វើឡើង បន្ទាប់ពីការចូលជាធរមាន សូម្បីតែបទល្មើសពាក់ព័ន្ធបានប្រព្រឹត្ត នៅមុនកាលបរិច្ឆេទនៃការចូលជាធរមានក៏ដោយ ។

៣. ភាគីនីមួយៗអាចបញ្ចប់កិច្ចព្រមព្រៀងនេះបាន ដោយជូនដំណឹងជាលាយល័ក្ខអក្សរ តាមរយៈផ្លូវទូតនៅពេលណាមួយក៏បាន ។ ការបញ្ចប់ត្រូវមានអានុភាពប្រាំមួយ (៦) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលសាម៉ីរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើជាពីរច្បាប់ នៅភ្នំពេញ ថ្ងៃទី...២៦.....ខែ តុលា ឆ្នាំ ពីពាន់ប្រាំបួន ជាភាសាខ្មែរ ភាសាកូរ៉េ និងភាសារអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

| **តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** | **តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ** |
|---|---|
| (signature) | (signature) |

# ឧបសម្ព័ន្ធទី៧

ឆ្នាំទី ៥ លេខ ២៨ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៥ រាជកិច្ច ទំព័រ ៤៦២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៧៥...អនក្រ.សរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការជាតដឹកនាំបញ្ហាការប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៥ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- តាមសំណើររបស់ប្រធានគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** បង្កើត លេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ហៅកាត់ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម និងមានអក្សរកាត់ លេខាធិការដ្ឋាន គជបភ ។

**ប្រការ ២:** លេខាធិការដ្ឋាន គជបភ ជួយការងារប្រធាន គជបភ និង គជបភ អំពីការងារទាំងឡាយសំដៅបង្កើនប្រសិទ្ធភាពការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្មដែលរួមមាន ៖

-កសាង ត្រួតពិនិត្យការអនុវត្តន៍ និងកែសំរួលយុទ្ធសាស្ត្រជាតិនៃការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ភេរវកម្ម

-ប្រមូល និងសរុបពត៌មានចារកម្មពីគ្រប់ស្ថាប័ន និងពត៌មានផ្សេងៗ - វិភាគវាយតំលៃ និងស្នើសុំវិធានការ

-ស្រាវជ្រាវអំពើភេរវកម្ម (ប្រមូលឯកសារ និងពត៌មាន - ចងក្រងឯកសារ និងពត៌មាន រាប់ទាំងឯកសារពត៌មានដែលបានពីបរទេសផង - សួរចម្លើយឈ្លបយកពត៌មានបន្ថែមទៀតពីមុខសញ្ញា ក្នុង និងក្រៅប្រទេស)

-សិក្សារកចំណុចខ្សោយដែលត្រូវបំពេញ និងអ្វីដែលភេរវករអាចធ្វើបានដោយយើងនឹកគិតមិនដល់

-សិក្សាពង្រឹងសមត្ថភាព និងជំនាញក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ភេរវកម្ម

-បណ្តុះបណ្តាលជំនាញនានា និងបំពាក់បំប៉ន វិធីសាស្ត្រ ការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

-រៀបចំផែនការការពារគោលដៅ (ការពារហេដ្ឋារចនាសម្ព័ន្ធ)- ផែនការសង្គ្រោះ - និងផែនការឃោសនាអប់រំមហាជន - ដឹកនាំការផ្សព្វផ្សាយពត៌មានពេលមានគ្រោះ និងវិបត្តិកើតឡើង

-ជួយរៀបចំកម្លាំងពិសេស កម្លាំងអន្តរាគមន៍ និងកម្លាំងសង្គ្រោះបន្ទាន់ និងបណ្តាញ (ដូចជាបណ្តាញសង្គ្រោះបឋមជាមួយកាកបាទក្រហម) និងការងារជំនាញគាំទ្រនានាផ្សេងទៀត ដូចជាការងារគោសលវិច័យ - ការងារវិភាគគ្រឿងផ្ទុះ - ជាតិគីមី - ជីវសាស្ត្រ - វិទ្យុសកម្ម - នុយក្លេអ៊ែរ - និងមូលដ្ឋានបច្ចេកទេសសំងាត់ឬចំហរនានា

-កសាងធនាគារពត៌មានដោយប្រព័ន្ធកុំព្យូទ័រ និងកសាងមូលដ្ឋានបច្ចេកទេសកុំព្យូទ័រតភ្ជាប់ពត៌មាន ឯកសារ ពីច្រកទ្វារអន្តរជាតិ - ពីស្ថាប័ននានា មកលេខាធិការដ្ឋាន គជបភ

-សិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្ម និងធ្វើរបាយកាណ៍នូវការអនុវត្តន៍ អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិទាំងនោះ ជូនអង្គការសហប្រជាជាតិតាមពេលកំណត់

-ទំនាក់ទំនង និងសហការជាមួយប្រទេសនានាជាទ្វេភាគី និងពហុភាគី ផ្លាស់ប្តូរពត៌មាននិងការវិភាគព្រមទាំងបទពិសោធន៍ និងសំរបសំរួលប្រតិបត្តិការរួមទៅវិញទៅមក

-បំពេញការងារមួយចំនួនទៀត ដែលប្រធាន គជបភ និង គជបភ ប្រគល់ឱ្យ

**ប្រការ ៣:** លេខាធិការដ្ឋាន គជបភ ធ្វើសេចក្តីណែនាំលំអិតអំពីរបៀបរបប និងដំណើរការនៃការងារនិមួយៗខាងលើនេះថែមទៀត ដោយមានការពិនិត្យ និងបានការយល់ព្រមពីប្រធាន គជបភ ជាមុនសិន ។

**ប្រការ ៤:** សមាសភាពលេខាធិការដ្ឋាន គជបភ ៖

១- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ - សមាជិក គជបភ .......................... ប្រធាន
(ទទួលបន្ទុករួម និងទទួលផ្ទាល់ទំនាក់ទំនងសំរបសំរួលការងារស្ថាប័នស៊ីវិល និងឯកជន)

២- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ - សមាជិក គជបភ ..........................អនុប្រធាន
(ទទួលបន្ទុករួមលើរាល់កិច្ចការពារហេដ្ឋារចនាសម្ព័ន្ធ)

២- ឯកឧត្តម **ឱម យ៉ិនទៀង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ ................អនុប្រធាន
(ទទួលបន្ទុកពត៌មាន ស្រាវជ្រាវ បណ្តុះបណ្តាល សំភារៈ បច្ចេកទេស ទំនាក់ទំនង និងសហប្រតិបត្តិការជាតិ អន្តរជាតិ ទ្វេភាគី និងពហុភាគី)

៣- ឯកឧត្តម **មល់ រៀម** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គញាការដ្ឋានកងយោធពលខេមរភូមិន្ទ ..............................................អនុប្រធាន
(ទទួលបន្ទុកសំរបសំរួលទំនាក់ទំនងការងារយោធា)

៤- ឯកឧត្តម យុ ស៊ិនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - អគ្គស្នងការរងនគរបាលជាតិ ......អនុប្រធាន

៥-ឧត្តមសេនីយ៍ឯក សៅ **សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ........................អនុប្រធាន

៦- ឯកឧត្តម **ញៀម សុខារ័ត្ន** ..............................................................អនុប្រធានប្រចាំការ

៧- ឧត្តមសេនីយ៍ឯក **ស្វ ផន** អគ្គស្នងការរងនគរបាលជាតិ ...............................................សមាជិក

៨- ឧត្តមសេនីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ..................................សមាជិក

៩- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ...........................................សមាជិក

១០- ឧត្តមសេនីយ៍ឯក **ជា សារ៉ន** មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក ...........សមាជិក

១១- ឧត្តមសេនីយ៍ឯក **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី .................សមាជិក

១២- ឧត្តមសេនីយ៍ទោ **ព្រហ្ម ឌិន** មេបញ្ជាការយោធភូមិភាគពិសេស ...................................សមាជិក

១៣- ឧត្តមសេនីយ៍ទោ **កែវ សាម្ងួន** មេបញ្ជាការយោធភូមិភាគទី ៣......................................សមាជិក

១៤- ឧត្តមសេនីយ៍ទោ **ជា ម៉ន** មេបញ្ជាការយោធភូមិភាគទី ៤............................................សមាជិក

១៥- ឯកឧត្តម **ហេង ពៅ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាស្នងការនគរបាលក្រុងភ្នំពេញ......សមាជិក

១៦- ឧត្តមសេនីយ៍ទោ **ម៉ៅ សុផាន់** មេបញ្ជាការកងពលតូចលេខ ៧០ ....................................សមាជិក

១៧- ឧត្តមសេនីយ៍ត្រី **ចាប ភក្តី** មេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ....................សមាជិក

១៨-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារជាតិនៃកម្ពុជា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងយុត្តិធម៌ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រសួងពាណិជ្ជកម្ម - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងសុខាភិបាល - ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល - គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា - គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ - អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន........................................................................សមាជិក

**ប្រការ ៥:** លេខាធិការដ្ឋានរៀបចំបញ្ជីឈ្មោះជាក់ស្តែងឱ្យតំណាងក្រសួង ស្ថាប័ន ដោយស្នើសុំឱ្យរដ្ឋមន្ត្រី ឬប្រធានស្ថាប័នចាត់ឈ្មោះអ្នកមានសមត្ថកិច្ចមកឱ្យខ្លួន ហើយរៀបចំទាំងតំណាងស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតចូលមកក្នុងក្រុមគាំទ្រការងារ ដើម្បីបំរើឱ្យការធ្វើសៀវភៅផែនការការពារហេដ្ឋារចនាសម្ព័ន្ធ និងការងារវិភាគ ការងារប្រមូលពត៌មាន និងការងារជំនាញផ្សេងៗទៀតដែលចាំបាច់ ។ បញ្ជីឈ្មោះក្រុមគាំទ្រការងារនេះ ត្រូវដាក់ជូនប្រធាន គជបភ ពិនិត្យ និងសំរេច ។

**ប្រការ ៦:** ក្នុងការរៀបចំធ្វើសៀវភៅផែនការតាមគោលដៅដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធត្រូវបានចែកចេញជា ៣ ក្រុម:

១-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ១ ហៅកាត់ហេដ្ឋា ១ ប្រគល់ជូនឯកឧត្តម **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ១ ដឹកនាំការងាររៀបចំសៀវភៅផែនការការពារសំរាប់គោលដៅ ៖

-អគ្គិសនី

-រដ្ឋាករទឹក

-ផ្លូវជាតិ

-ផ្លូវដែក

-អគាររដ្ឋ

-អគារឯកជន

២-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ២ ហៅកាត់ហេដ្ឋា ២ ប្រគល់ជូនឯកឧត្តម **ឃួ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាអគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ២ ដឹកនាំការងាររៀបចំសៀវភៅផែនការសំរាប់គោលដៅ ៖

-ព្រលានយន្តហោះ

-កំពង់ផែ

-នាវាចរ (សមុទ្រ និងទន្លេ)

-ពិធីបុណ្យ-អង្គប្រជុំជាតិ-អន្តរជាតិ-គណៈប្រតិភូ

-ស្ថានទូត-កុងសុល-និវេសនដ្ឋានឯកអគ្គរដ្ឋទូត

-សាលាអន្តរជាតិ (ដែលមានកូនសិស្សបរទេសសិក្សា)

៣-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ៣ ហៅកាត់ហេដ្ឋា ៣ ប្រគល់ភារកិច្ចជូនឯកឧត្តម **នេត្រ សាវឿន** ជាប្រធានក្រុមហេដ្ឋា ៣ ដឹកនាំការងារសិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្មនិងធ្វើរបាយកាណ៍នូវការអនុវត្តន៍អនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិទាំងនោះជូនអង្គការសហប្រជាជាតិតាមពេលកំណត់និងទទួលការងាររៀបចំសៀវភៅផែនការ សំរាប់ ៖

-ការប្រឆាំងការលាងលុយកខ្វក់

-ការប្រឆាំងការធ្វើលិខិត ឯកសារក្លែងក្លាយ ការជួញដូរមនុស្ស

-ការប្រឆាំងបទឧក្រិដ្ឋផ្សេងៗទៀត រាប់ទាំងគ្រឿងញៀន

-គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ CBRN និងផែនការអន្តរាគមន៍សង្គ្រោះ រាប់ទាំងផែនការអន្តរាគមន៍សង្គ្រោះក្នុងករណី គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ ទៀតផង

**ប្រការ ៧:**ក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ខិម យ៉ិនឡេង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ ជាប្រធានក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ហើយមានសមាសភាព:

-ក្រុមវិភាគរួមមាន:

១- ឯកឧត្តម ប្រាក់ សុខុន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក គជបភ ..........................................................................................សមាជិក

២- ឧត្តមសេនីយ៍ឯក ម៉ល់ ធឿម ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ....................................សមាជិក

៣- ឧត្តមសេនីយ៍ឯក **យូ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី-អគ្គស្នងការរងនគរបាលជាតិ.សមាជិក

៤- ឯកឧត្តម **អ៊ុច បូរិទ្ធិ** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ .............សមាជិក

៥- ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស-សមាជិក គជបក ......សមាជិក

៦- ឧត្តមសេនីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ................................សមាជិក

៧- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ..........................................សមាជិក

៨ - ឧត្តមសេនីយ៍ឯក **ជុម ចាក់** មេបញ្ជាការរង កងទ័ពជើងគោក ..................................សមាជិក

៩ - ឯកឧត្តម **ហេង ពៅ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - ស្នងការនគរបាលក្រុងភ្នំពេញ ........សមាជិក

១០ - ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ...........................សមាជិក

១១- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ....................................................................សមាជិក

១២- ឧត្តមសេនីយ៍ត្រី **យ៉ា គីមអ៊ី** មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ ..........................សមាជិក

-ក្រុមចារកម្មរួមមាន:

១- ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ............................សមាជិក

២- ឧត្តមសេនីយ៍ទោ **មិត គីមហុង** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ..............................សមាជិក

៣- ឧត្តមសេនីយ៍ទោ **សិរិត ហ៊ុន** នាយការិយាល័យទី ២ កងទ័ពជើងគោក .........................សមាជិក

៤- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ....................................................................សមាជិក

៥- ឧត្តមសេនីយ៍ត្រី **ឆែ ស៊ីណារិទ្ធ** ប្រធាននាយកដ្ឋានព័ត៌មានទូទៅ ...................................សមាជិក

៦- ឧត្តមសេនីយ៍ត្រី **គៀត ច័ន្ទថារិទ្ធ** ប្រធាននាយកដ្ឋានជនបរទេស ..................................សមាជិក

៧- ឧត្តមសេនីយ៍ត្រី **មាស អ៊ន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..........................................................................................សមាជិក

៨- ឧត្តមសេនីយ៍ត្រី **សិទ្ធិ សាវឿន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..........................................................................................សមាជិក

៩- ឧត្តមសេនីយ៍ត្រី **គីម នាន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី .......................................សមាជិក

១០- វរៈសេនិយ៍ឯក **ហ៊ី ព្រូ** ស្នងការរងនគរបាលក្រុងភ្នំពេញ ..........................................សមាជិក

១១- វរៈនារីឯក **មី ឪណា** នាយការិយាល័យទី ២ កងទ័ពជើងទឹក ....................................សមាជិក

១២-វរៈសេនិយ៍ឯក **ពៅ ពិចិត្រ** នាយក្រុមប្រតិបត្តិការក្នុងប្រទេសនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..........................................................................សមាជិក

១៣-វរៈសេនិយ៍ឯក **ស៊ុម ហុង** មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងភ្នំពេញ ..........................សមាជិក



ш

១៤-វរៈសេនិយត្រី ម៉ាត់ សុជារី សមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី ...........................សមាជិក

ប្រការ៨:មន្ត្រី បុគ្គលិកបំរើការក្នុងលេខាធិការដ្ឋាន សុទ្ធតែជាអ្នកដែលមានក្របខ័ណ្ឌស្រាប់ លើកលែងតែមានតំរូវការអ្នកជំនាញ ដូចជាកុំព្យូទ័រ ឬជំនាញផ្សេងៗ ទើបអនុញ្ញាតស្នើសុំក្របខ័ណ្ឌថ្មី ដោយបញ្ចូលមកក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ៩:លេខាធិការដ្ឋាន គជបក មានត្រា និងថវិកាដោយឡែករបស់ខ្លួន ។ ក្នុងពេលថវិកាដោយឡែករបស់លេខាធិការដ្ឋាន គជបក មិនទាន់បានទទួលការអនុម័ត រាល់ចំណាយដំណើរការនៃលេខាធិការដ្ឋាន គជបក ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំអគារសំរាប់ធ្វើជាលេខាធិការដ្ឋាន និងសំរាប់ធ្វើជាមូលដ្ឋាននានារបស់លេខាធិការដ្ឋាន ។

ប្រការ ១០: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះនៅក្នុងប្រការ ៤ - ប្រការ ៦ និងប្រការ ៧ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងការពារជាតិ
-ក្រសួងមហាផ្ទៃ
-អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ១០
-កាលប្បវត្តិ - ឯកសារ

# ឧបសម្ព័ន្ធទី៨



## ព្រះរាជក្រម

នស/រកម/០៨០៩/០១៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ : -

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
## រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីការផ្ទេរទណ្ឌិត ដែលធ្វើនៅញូវដែលី នាថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកម.០៩០៨.៧៣៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ : ៧៦៤ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនគេន

# ឧបសម្ព័ន្ធទី៩


នីតិវិធីនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលស្នើដោយរដ្ឋបរទេស
(ចងក្រងដោយៈ ស៊ាង សំភស់)
ពាក្យសុំធ្វើបត្យាប័ន
លិខិតបញ្ជាក់គស្តូពាង
- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- របាយការណ៍អំពីអង្គហេតុ ដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និង ទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្ដីសម្រេចផ្ដន្ទាទោសប្រសិនបើមាន
រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ភ្នំពេញ
សាលដីកាដែលចូលជាស្ថាពរ រួចហើយត្រូវជូនដំណឹងភ្លាម ដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
យោបល់សភាស៊ើបសួរក្រោយពីពិភាក្សាដេញដោល (ចេញជាសាលដីកា)
-ក្រោយពីស្ដាប់ចម្លើយបុគ្គលដែលគេទាមទារ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី
ករណីយល់ព្រម
ករណីមិនយល់ព្រមៈបត្យាប័នមិនអាចធ្វើបានដោយរាជរដ្ឋាភិបាលកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល
រាជរដ្ឋាភិបាលចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន
ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន ប្រសិនបើរដ្ឋផ្ញើសំណើមិនបានចាប់ផ្ដើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍ នោះបុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។


រដ្ឋផ្ញើសំណើ (ភស្តុតាង អត្តសញ្ញាបុគ្គលដែលទាមទារ...)
ទី (១) តាមផ្លូវទូត
រដ្ឋាភិបាល (រដ្ឋមន្ត្រីក្រសួងការបរទេស)
រដ្ឋមន្ត្រីក្រសួងការបរទេសត្រូវបញ្ជូនពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បី៖ ទី១-ពិនិត្យផ្ទៀងផ្ទាត់ ទី២-និយតភាពនៃការស្នើសុំធ្វើបត្យាប័ន
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រៀបចំឯកសារប្តឹងទៅសភាស៊ើបសួរ
សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
ទី (២)
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវជូនរឿងនេះទៅរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឲ្យធ្វើបត្យាប័ន
ប្រសិនបើយល់ព្រមចំពោះការធ្វើបត្យាប័ន សភាស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-មិនយល់ព្រម ឬ យល់ព្រម ចំពោះការស្នើសុំធ្វើបត្យាប័ន
-មិនយល់ព្រមបុគ្គលដែលទាមទារត្រូវដោះលែង
ឧទ្ទេសនាមដោយ៖ លោក ជុំ គីរី
១១

# ឧបសម្ព័ន្ធទី១០

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២៥៤
ថ្ងៃ:សុក្រទី១៤ ខែធ្នូ ឆ្នាំ២០១៨
ម៉ោង: ១៥:៤០ នាទី

**ព្រះរាជក្រម**

នស/រកម/១២១៨/០១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឲ្យប្រើ**

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្ដីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

**មាត្រា១.–**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ីដែលបានចុះហត្ថលេខា នៅរដ្ឋធានីមូស្គូ នៃសហព័ន្ធរុស្ស៊ី នាថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

**មាត្រា៣.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ ពុធ ៥កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៨

នស/រកម.១២១៨.០៥៤

នរោត្ដម សីហមុនី

**នរោត្ដម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ឧបសម្ព័ន្ធទី១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍

លេខ...[illegible]

ភ្នំពេញ, ថ្ងៃទី [illegible]

## ដីកាបង្គាប់អោយចាប់-ឃុំខ្លួន

យើងអគ្គព្រះរាជអាជ្ញានៃអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញមាត្រា ៥៧៩ និង ៥៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញលិខិតលេខ ២០៨៧ កយ ព្រទ/បឱ១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ ស្តីអំពីសំណើសុំចាប់ខ្លួន និងធ្វើបត្យាប័នជនជាតិ រុស្ស៊ី ឈ្មោះ Balatin Vladimir Vitalievitch ភេទប្រុស អាយុ ៣៦ឆ្នាំ (កើតនៅទីក្រុង Zёya) ទៅតាមតុលាការ រុស្ស៊ី ដោយហេតុថា បុគ្គលនេះបានប្រព្រឹត្តបទល្មើសនៅប្រទេស រុស្ស៊ី ហើយគេចខ្លួនមកប្រទេសកម្ពុជា បច្ចុប្បន្នស្នាក់នៅខេត្តព្រះសីហនុ ។

បានឃើញដីកាចាប់ខ្លួនចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ចេញដោយប្រធានចៅក្រមឈ្មោះ Petrov M.G the secretary of the court Kalashnikava E.S ស្នើសុំឱ្យចាប់ខ្លួនបុគ្គលឈ្មោះ Balatin Vladimir Vitalievitch ពីបទៈ បោកលុយក្រុមហ៊ុន ។

### បង្គាប់មក

ភ្នាក់ងារមានសមត្ថកិច្ចស្វែងរកចាប់ខ្លួនលើបុគ្គលឈ្មោះ Balatin Vladimir Vitalievitch ជនជាតិរុស្ស៊ី កើតនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៨ ជាប់ចោទពីបទៈ បោកលុយក្រុមហ៊ុន ប្រព្រឹត្តនៅចន្លោះឆ្នាំ ២០០៧-២០០៨ ហើយត្រូវនាំខ្លួនបុគ្គលនេះ ក្នុងរយៈពេលឆាប់បំផុតជូនព្រះរាជអាជ្ញាដែនដី ដើម្បីធ្វើការឃុំខ្លួនបុគ្គលនេះ ដោយអនុវត្តតាមមាត្រា ៥៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

តប.- អគ្គព្រះរាជអាជ្ញា

[illegible]